ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ផែនទីចិន្តន័យគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា
- បណ្ណាល័យកុមារនៅតាមសហគមន៍ជាច់ស្រយាល

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៩៥ ខែកក្កដា ឆ្នាំ២០២៤

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

### សំបុត្រ

◆ ដែនទីទិន្នន័យគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាព .... ១

### ផ្នែកឯកសារ

◆ ព្រំ ឡោ ហៅ ឡុន៖ ប្រធានកងធំ កាត់ដេរ.....៤

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ បណ្ណាល័យកុមារនៅតាមសហគមន៍............ ៨
◆ ពិព័រណ៍រុក្ខជាតិ និងសួនច្បារភ្នំពេញ .......... ១០
◆ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ដឹកនាំយុវជនទស្សនកិច្ចសិក្សាតំបន់ប្រវត្តិសាស្ត្រយោធាគេជោ ភ្នំមាន់ (A4) វាលវែង....................... ១២
◆ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមាន...... ១៦
◆ មជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់រទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែល ..... ១៩
◆ មជ្ឈមណ្ឌលឯកសារកោះថ្ម ផ្តល់រទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជី ... ២២
◆ មជ្ឈមណ្ឌលឯកសារកោះថ្មផ្តល់រទេះរុញ និងកាសជំនួយត្រចៀក ដល់អង្គការជនពិការ ........ ២៦
◆ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ផ្តល់រទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ... ២៩
◆ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ ផ្តល់រទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ........ ៣១
◆ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ផ្តល់រទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ... ៣៤
◆ មជ្ឈមណ្ឌលឯកសារកោះថ្ម ផ្តល់រទេះរុញសម្រាប់ជនពិការ តាមការស្នើសុំរបស់រដ្ឋបាល ....... ៣៦
◆ អ្នកតម្បាញជនជាតិចាមមកពីស្រុកកោះសូទិន ចូលរួមដំណើរទស្សនកិច្ចសិក្សា ............. ៣៨
◆ អន ពន៖ ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅឃុំ ......៤១



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត អានសៀវភៅ «ព័ត៌មានអំពីការថែទាំសុខភាព» ដែលបោះពុម្ពដោយគម្រោងស្តីអំពី «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

### ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ វេទិកាថ្នាក់រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហម៖ ការលើកយកប្រធានបទតូចៗនៃព្រឹត្តិការណ៍ .. ៤៤
◆ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកាថ្នាក់រៀនស្តីពី សារសំខាន់នៃការសិក្សា........... ៤៧
◆ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជា............. ៥០
◆ មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាថ្នាក់រៀនស្តីអំពី ប្រវត្តិសាស្ត្ររបបកម្ពុជា............... ៥៣

### ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ ជីវិតកូនប្រុសពុកក្នុងគុកខ្មែរក្រហម (ត) ... ៥៩

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្មេរលេខនេះ៖** គាត និត, ឡុង ដានី, ឡាំ ស្រីនិត, ចាន់ ណារិទ្ធ, ស៊ាង ចិន្តា, ឈុំ រ៉ា, ទូច វណ្ណេត, ជឹម សុខគា, ភា រស្មី, ជេង ពង្សរ៉ាស៊ី, សួត វិចិត្រ, សាំង ចាន់ធូ, វី ស៊ីថា, វន បុប្ផា, ម៉ាប់ ស៊ីណា, និង ហង្ស ឆាំឆាន
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លីម អ៊ីគីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនី ឡា **គ្រប់គ្រងការចែកផ្សាយ៖** ផេង ពើង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ផែនទីទិន្នន័យគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាព អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

**សោម ប៊ុនថន**




ផែនទីទិន្នន័យគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» បោះពុម្ពនៅឆ្នាំ២០២៤ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតផែនទីទិន្នន័យគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» របស់ខ្លួន រួមមាន ៖ ១) ចំនួនអ្នកស្ម័គ្រចិត្តកម្ពុជា, ២) ចំនួនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានផ្តល់បទសម្ភាសន៍ និងរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម, ៣) ចំនួនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានចូលរួមក្នុងកម្មវិធីអប់រំថែទាំសុខភាព និងពិនិត្យសុខភាពពីគ្រូពេទ្យជំនាញ និង ៤) ចំនួនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅទូទាំងប្រទេសកម្ពុជា។



មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តួចផ្តើមសិក្សាអំពីស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដោយផ្តោតលើការអប់រំ និងពិគ្រោះយោបល់អំពីបញ្ហាសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅទូទាំងប្រទេសកម្ពុជា។ សកម្មភាពនៃគម្រោងនេះគឺធ្វើឡើងក្នុងគោលបំណងធ្វើឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមានសុខភាពល្អប្រសើរឡើងជាងសព្វដង និងរស់នៅបានយូរដើម្បីជួបជុំជាមួយកូនចៅ ព្រមទាំងសង្ឃឹមថាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនេះ អាចបន្តចែករំលែកបទពិសោធន៍ជីវិតរបស់ខ្លួនក្នុងរបបខ្មែរក្រហមទៅកាន់មនុស្សជំនាន់ក្រោយ និងពិភពលោក ដើម្បីគាំទ្រដល់ការអប់រំពីអំពើប្រល័យពូជសាសន៍ សំដៅដល់ការទប់ស្កាត់អំពើឧក្រិដ្ឋកម្មអមនុស្សធម៌នានាពីការកកើតឡើងសារជាថ្មីម្តងទៀត។

គម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ចាប់ផ្តើមដំបូងនៅក្នុងឆ្នាំ ២០២០ ដោយមានការឧបត្ថម្ភគាំទ្រថវិកាពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍



ក្រុមការងារគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ពិនិត្យសុខភាពបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អន្តរជាតិ។ គម្រោងនេះ មានអ្នកស្ម័គ្រចិត្តកម្ពុជាចំនួន ៣,៤៦៤នាក់ ត្រូវបានជ្រើសរើសនៅទូទាំងប្រទេស។ អ្នកស្ម័គ្រចិត្តកម្ពុជានៅទូទាំងប្រទេសបានប្រមូលរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហមពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានចំនួន ៦១,៦២៥នាក់ ក្នុងចំណោមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៥,១៤៣,៣៨៦នាក់ (ស្មើនឹង៣៣,១៦ភាគរយនៃប្រជាជនកម្ពុជាសរុប ចំនួន១៥,៥៥២,២១១នាក់ ក្នុងឆ្នាំ២០១៩)។

ក្នុងចំណោមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ៦១,៦២៥នាក់ ដែលបានផ្តល់បទសម្ភាសន៍ដល់អ្នកស្ម័គ្រចិត្តកម្ពុជា គឺបានទទួលសេវាពិនិត្យសុខភាពចំនួន ៥,៤៤៣នាក់ និងបានចូលរួមក្នុងកម្មវិធីអប់រំថែទាំសុខភាពពីគ្រូពេទ្យជំនាញៗចំនួន២,៩៧៦នាក់ ដែលរៀបចំឡើងដោយគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។





អ្នកស្ម័គ្រចិត្តក្នុងគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# ព្រុំ ឡោ ហៅ ឡុន ៖ ប្រធានកងធំ កាត់ដេររដ្ឋ

ដារ៉ារដ្ឋ មេត្តា



ស្ត្រីនៅខេត្តកំពង់ចាម ថតដោយ ហ្គុនណា បឺយស្ត្រម នៅខែសីហា ឆ្នាំ១៩៧៨។
(ហ្គុនណា បឺយស្ត្រម/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ព្រុំ ឡោ ហៅ ឡុន អាយុ២៦ឆ្នាំ ក្នុងឆ្នាំ១៩៧៨។ ខ្ញុំមានស្រុកកំណើតនៅភូមិដាច់រំពាត់ ឃុំការ៉ែ ឡក ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ តាំងពីតូចខ្ញុំរស់នៅជាមួយឪពុកម្តាយដោយប្រកបមុខរបរកាប់ឈើលក់ ធ្វើចន្ទុះ បោចវល្លិ និងធ្វើស្រែចម្ការ។

នៅក្នុងឆ្នាំ១៩៦៨ ទាហានស័ក្តិ១ ឈ្មោះ សុខ នៅខេត្តកំពង់ធំ បានមកជួយកាប់ព្រៃធ្វើចម្ការឪពុកម្តាយខ្ញុំ ហើយគាត់បានទាក់ទងជាមួយខ្ញុំញឹកញាប់។ ឈ្មោះ សុខ តែងតែឲ្យលុយខ្ញុំចាយមិនដាច់ ហើយគាត់បានអប់រំខ្ញុំឲ្យធ្វើជាទាហានដោយបានលើកឡើងថាប្រសិនបើខ្ញុំបានធ្វើជាទាហានគឺរស់នៅស្រួល មិនលំបាកឪពុកម្តាយទេ ព្រោះទទួលបានប្រាក់ខែចិញ្ចឹមឪពុកម្តាយ។ សុខ បានអប់រំខ្ញុំអំពីខ្មែរក្រហមថា នៅស្រុកចំការលើខ្មែរក្រហមចូលកាប់សម្លាប់ប្រជាជនអស់ចំនួន៩នាក់ហើយយក គោ ក្របី ស្រូវ អង្ករ ជ្រូក មាន់ ទា និងបំផ្លាញដំណាំរបស់អ្នកភូមិអស់មួយចំនួន។

ក្រោយមក សុខ នាំខ្ញុំទៅជួបឈ្មោះ កែ អតីតស័ក្តិ៥ គឺជាទាហានខេត្តកំពង់ធំ (កែ ស្លាប់ក្នុងឆ្នាំ១៩៧២ ដោយអន្តរាយការកម្ទេច)។ ពេលនោះ កែ លើកឡើងពីជំនាន់មុន ហើយចុងក្រោយបានលើកឡើងពីខ្មែរក្រហមដែលចូលមកបង្កប់ខ្លួនក្នុងព្រៃ និងក្នុងភូមិ។ ក្រុមខ្មែរក្រហមនេះគ្មានធ្វើស្រែទេ ដើរកាប់សម្លាប់ប្រជាជន និងយកស្រូវប្រជាជនហូប។ ខណៈនោះ ឈ្មោះ កែ បានបញ្ចូលឈ្មោះខ្ញុំនិងសមាជិក៨នាក់ជាសមាជិក សេ-អ៊ុ-អា ដោយឈ្មោះ សុខ ជាអ្នកខ្ទេសនាម និងឈ្មោះ ប៉ាត មេភូមិដាច់រំពាត់ គឺជាអ្នក

ទទួលស្គាល់។ អ្នកចូល សេ-អ៊ី-អា ជាមួយខ្ញុំមានឈ្មោះ៖ ១) ចាំង គឺជាយុទ្ធជនភូមិដាច់រំពាត់។ នៅក្នុងឆ្នាំ១៩៧៣ ចាំង បានចូលធ្វើជាឈ្លប ហើយរយៈពេលប្រមាណ៧ខែក្រោយមកបានឡើងជាទ័ពតំបន់កំពង់ធំ ភូមិភាគឧត្តរចាស់, ២) ឃី ត្រូវជាប្អូនថ្លៃឈ្មោះ សុខ។ នៅក្នុងឆ្នាំ១៩៧២ ឃី ចូលធ្វើជាឈ្លបភូមិដាច់រំពាត់, ៣) សាយ គឺជាយុទ្ធជនភូមិដាច់រំពាត់ ស្លាប់ក្នុងឆ្នាំ១៩៧៤, ៤) ស៊ិន យុទ្ធជនភូមិដាច់រំពាត់។ នៅឆ្នាំ១៩៧២ ស៊ិន ចូលឈ្លបភូមិ, ៥) ជិន គឺជាយុទ្ធជន, ៦) ទុន ប្រជាជនភូមិដាច់រំពាត់ ត្រូវជាបងរបស់ សុខ, ៧) ទេព ប្រជាជនដាច់រំពាត់ និង ៨) ទិន គឺជាប្អូនរបស់ សុខ ក្លាប់មិនបាន។ កម្មវិធីនេះបញ្ចូលជា សេ-អ៊ី-អា ធ្វើនៅសាលាបុណ្យនៅក្នុងភូមិដាច់រំពាត់ ដោយ កែ បានណែនាំភារកិច្ចឲ្យសមាជិក សេ-អ៊ី-អា ត្រូវដើររកខ្មែរក្រហមតាមព្រៃ និងការពារកុំឲ្យខ្មែរក្រហមចូលក្នុងភូមិ។ ចំណែក ខ្ញុំប្ដេជ្ញាអនុវត្តតាមការណែនាំ។ ក្រោយពីចូល សេ-អ៊ី-អា រួច សុខ បានចាត់តាំងខ្ញុំ, ទេព និង ស៊ិន ឈ្លបភូមិដាច់រំពាត់ឲ្យនៅយាមស្ពានអូរពោ រង់ចាំចាប់ខ្មែរក្រហមឆ្លងកាត់ពីកំពង់ធំ មកស្រុកសណ្ដាន់។ ពេលនោះខ្ញុំបានជួបខ្មែរក្រហមចុះមកស្នាក់នៅ និងដាំបាយនៅគល់ស្ពាន៣នាក់ ហើយក៏ចាប់បាននារីម្នាក់និងយុទ្ធជនពីរនាក់។ ខ្ញុំយកនារីនោះទៅប្រគល់ឲ្យឈ្មោះ សុខ ហើយ សុខ ក៏បានយកនារីនោះទៅសម្លាប់ចោល។

នៅដើមឆ្នាំ១៩៦៩ សុខ និង ប៉ាត បានប្រមូលប្រជាជនទាំងអស់ដែលធ្វើចម្ការនៅក្នុងព្រៃមកធ្វើមីទីញដើម្បីថ្កោលទោសខ្មែរក្រហមដោយឲ្យប្រជាជនប្រុងប្រយ័ត្នកុំឲ្យខ្មែរក្រហមចូលភូមិ។ ខ្លឹមសារដែលអប់រំប្រជាជនគឺ នៅក្នុងព្រៃក្រុមខ្មែរក្រហមបង្កប់ខ្លួនច្រើនណាស់ ហើយក្រុមនេះមិនមានស្រូវអង្ករហូបទេ គឺនៅក្នុងព្រៃហូបតែស្លឹកឈើ។ នៅក្នុងឆ្នាំ១៩៦៩ ដដែល ក្រុមខ្ញុំដើររកខ្មែរក្រហមជាប់ន្តបន្ទាប់តាមព្រៃដោយក្រុមខ្ញុំក្លែងខ្លួនធ្វើជាប្រជាជនកាប់ឈើក្នុងព្រៃ។

នៅឆ្នាំ១៩៧០ កើតមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ហើយអង្គការបដិវត្តន៍បានចូលមកក្នុងភូមិកូនក្អែក ចំណែក សុខ ក៏ឈប់ធ្វើជា ទាហាននៅក្នុងភូមិដាច់រំពាត់នេះដែរ។ រយៈពេលមួយខែក្រោយមក សុខ បានចាត់តាំងខ្ញុំ, ឃី, ស៊ិន ឲ្យយកព័ត៌មានពីអង្គការលាក់ឃ្លាំងស្រូវ ឃ្លាំងអង្ករ នៅភូមិកូនក្អែក។ ក្រោយពីបានទទួលការចាត់តាំង ក្រុមខ្ញុំបានស៊ើបដឹងទីតាំងអង្ករមួយឃ្លាំង និងស្រូវមួយឃ្លាំង ប៉ុន្តែយើងមិនបានធ្វើសកម្មភាពទេ គឺរង់ចាំដល់ពាក់កណ្ដាលឆ្នាំ១៩៧០ ទើបទទួលបញ្ជាពីឈ្មោះ សុខឲ្យដុតឃ្លាំងទាំងនោះ។

នៅឆ្នាំ១៩៧១ អង្គការចូលមកដល់ភូមិដាច់រំពាត់ ដូច្នេះ សុខ ណែនាំកម្លាំង សេ-អ៊ី-អា ទាំងអស់មិនឲ្យធ្វើសកម្មភាពឡើយ។ ក្រោយមក សុខ បានហៅ ខ្ញុំ, លឹម ប្រជាជនភូមិដាច់រំពាត់, សាយ, ចាំង, ប៉ាត, ទេព, ទុន, ទិន, ជឹម គឺជាប្រជាជនភូមិកូនក្អែក និង ឃី ទៅប្រជុំ។ ខ្លឹមសារប្រជុំ សុខ លើកឡើងអំពីកម្លាំងកងទ័ពដែលចូលមកភូមិដាច់រំពាត់ចំនួន៥០នាក់ ហើយនៅក្នុងចំណោមនោះមាន សេ-អ៊ី-អា របស់ សុខ ចំនួន៤នាក់ ដែលធ្លាប់រួមសកម្មភាពជាមួយគាត់កាលនៅជា ទាហាននៅខេត្តកំពង់ធំមានឈ្មោះ ម៉ែន គឺជាប្រធានមន្ទីរស្រុកកំពង់ស្វាយ, ហុន យុទ្ធជនស្រុកកំពង់ស្វាយ, សុត យុទ្ធជនស្រុកកំពង់ស្វាយ, លី ក្រោយមកក្លាយជាកម្មកររត់ខ្សែភ្លើងនិងវិទ្យុនៅស្ទឹងមានជ័យ និង វត្តភ្នំ។

នៅខែមករា ឆ្នាំ១៩៧២ អង្គការចាប់ សុខ។ បន្ទាប់មក ប៉ាត និង ចាំង គឺជាអតីតកសិករបានចាត់តាំងខ្ញុំ, សាយ ឲ្យមកទាក់ទងជាមួយ ម៉ែន ដើម្បីសុំចូលមកបង្កប់ក្នុងជួរបដិវត្តន៍ហើយ ម៉ែន ក៏បានយល់ព្រម។ ម៉ែនបាននាំខ្ញុំ, ស៊ិន និង ទេព ទៅមើលឃ្លាំងស្រូវ ឃ្លាំងអំបិល ដើម្បីឲ្យក្រុមខ្ញុំបំផ្លាញ។ ក្រោយពីឃើញហើយ យើងទាំង៣នាក់ បានធ្វើសកម្មភាពដោយខែភ្លៀងមកបើកដំបូលឃ្លាំងអំបិលនៅជិតមន្ទីរស្រុកកំពង់ស្វាយឲ្យទឹកភ្លៀងហូរចូលនិងរលាយអំបិលអស់ជាងពាក់កណ្ដាល។ នៅពាក់កណ្ដាលឆ្នាំ១៩៧២ ម៉ែន បានហៅខ្ញុំ, សូត យុទ្ធជនមន្ទីរស្រុកកំពង់ស្វាយ, នាត ប្រជាជនភូមិនេពេជ ឃុំកាឡែក, ហុន និង សុង យុវជនវរសេនាតូច៣០៨ ទៅប្រជុំនៅក្នុងព្រៃជិតមន្ទីរស្រុកកំពង់ស្វាយ។

ខ្ទឹម សារប្រជុំ ម៉ែន បានអប់រំឲ្យខំប្រឹងធ្វើសកម្មភាពប្រឆាំងបដិវត្តន៍តទៅទៀត។ ម៉ែន លើកផែនការត្រូវកម្ទេចឃ្លាំងស្រូវ អង្ករ អំបិល អាវុធ គ្រាប់ ឃ្លាំងខោអាវ ដែលមាននៅក្នុងស្រុកកំពង់ស្វាយ។ នៅចុងឆ្នាំ១៩៧២ ម៉ែន បានចាត់តាំងខ្ញុំ សាយ, សុង ឲ្យមកជាយុទ្ធជនតំបន់កំពង់ធំ។ មុនពេលចេញ ម៉ែន បានណែនាំក្រុមខ្ញុំ ត្រូវធ្វើយ៉ាងម៉េចឲ្យអង្គការទុកចិត្តសិនចាំធ្វើសកម្មភាព។ ទៅដល់នោះខ្ញុំទាក់ទងជាមួយឈ្មោះ ឈុំ ។ ខ្ញុំបានចូលក្នុងកងវរសេនាតូច ៤០១ បានរយៈពេលពាថ្ងៃ ឈុំ ក៏នាំយើងខ្ញុំទាំង៣នាក់ទៅប្រគល់ឲ្យឈ្មោះ ឯក គឺជាប្រធានវរសេនាតូច៥០៩ របស់តំបន់កំពង់ធំ។ ឈុំ ខទ្វេសនាមខ្ញុំទាំង៣នាក់ឲ្យជាប់ខ្សែ សេ-អ៊ី-អា ជាមួយ ឯក ដើម្បីដឹកនាំក្រុមខ្ញុំឲ្យធ្វើសកម្មភាពប្រឆាំងបដិវត្តន៍។ ខ្ញុំ និង សាយ បានមកនៅកងតូចទី៣កងធំទី១ វរសេនាតូច៥០៩ ចំណែក សុង ទៅនៅកងធំទី៣ វរសេនាតូច៥០៩។ ប្រហែលរយៈពេល១០ថ្ងៃក្រោយមក ឯក បានហៅខ្ញុំ, សាយ និង សុង ទៅជួប ហើយប្រាប់អំពីកម្លាំង សេ-អ៊ី-អា របស់គាត់។ ឯកឲ្យក្រុមខ្ញុំប្រយ័ត្នខ្លួន ព្រោះគាត់ត្រូវទាក់ទងហៅយន្តហោះមកទម្លាក់គ្រាប់តាមខ្សែត្រៀម។ នៅក្នុងឆ្នាំ១៩៧៣ អង្គការចាប់ ឯក ទើបឈប់មានការទម្លាក់គ្រាប់ទៀត។ កាលនោះកម្លាំងបដិវត្តន៍ស្លាប់ និងរបួសជាបន្តបន្ទាប់ រួមមានយុវជន និងកម្មាភិបាលមួយចំនួនផង។

នៅដើមឆ្នាំ១៩៧៣ អង្គការរំលាយវរសេនាតូច៥០៩ចោល។ ពេលនោះ កងតូចរបស់ខ្ញុំមានមិត្ត ពាន់ គ្រប់គ្រងផ្ទាល់ និងត្រូវបញ្ចូលទៅក្នុងវរសេនាតូច៤០២របស់តំបន់កំពង់ធំវិញ។ ខ្ញុំនៅធ្វើការជាប់ជាមួយ ពាន់ ហើយ ពាន់ បានឡើងជាប្រធានកងធំ ចំណែកខ្ញុំពីរនាក់ សុង គឺជានីរសារ។ ក្រោយពីខ្ញុំទៅនៅវរសេនាតូច៤០២ បានប្រហែលជាកន្លះខែ ពាន់ បានខទ្វេសនាមខ្ញុំឲ្យជាប់ខ្សែ សេ-អ៊ី-អា ជាមួយឈ្មោះ ម៉ែន គឺជាប្រធានកងធំ វរសេនាតូច៤០២។ បន្ទាប់មក ពាន់បានហៅខ្ញុំចូលរួមប្រជុំជាមួយ ម៉ែន នៅវត្តជាយស្បៃ ស្រុកសន្ទុក ខេត្តកំពង់ធំ។ នៅចុងឆ្នាំ១៩៧៣ ពាន់បានចាត់តាំងខ្ញុំមកនៅកងពិសេសរបស់តំបន់កំពង់ធំ។

នៅខែកុម្ភៈ និង ខែមីនា ឆ្នាំ១៩៧៤ ឈុំ បានចាត់តាំង ខ្ញុំ, ស្រ៊ី (ឆ្នាំ១៩៧៦ ប្រធានកងធំឃ្លាំងរដ្ឋខាងលិចផ្សារអូរឫស្សី) និង សង (ឆ្នាំ១៩៧៦ ប្រធានក្រុមឃ្លាំងរដ្ឋខាងលិចផ្សារអូរឫស្សី) ឲ្យដេញក្របី ប្រជាជនចំនួន២០ក្បាល យកឲ្យទាហាននៅបន្ទាយតាយ៉ាប ដោយគាត់និយាយតាមគេអូឲ្យទាហានមកចាំទទួលនៅភូមិត្នោត ស្រុកកំពង់ស្វាយ។ ពេលនោះខ្ញុំ, ស្រ៊ី និង សង ក៏បានដេញក្របីប្រជាជនភូមិរវាំងចំនួន២០ក្បាល យកទៅឲ្យទាហានតាមការកំណត់របស់ ឈុំ។ ខ្ញុំឃើញទាហាន៥នាក់ មកទទួលក្របីពីខ្ញុំប្រហែលម៉ោង៥ល្ងាច។ នៅចុងឆ្នាំ១៩៧៤ អង្គការបានរៀបចំកងពិសេសជាវរសេនាតូចលេខ១០៧ របស់តំបន់កំពង់ធំ។ ឈុំ គឺជាប្រធានវរសេនាតូច ស្រ៊ី គឺជាសមាជិក ហើយឈ្មោះ សៅ គឺជាអនុ ចំណែកខ្ញុំគឺជាប្រធានក្រុមនៅក្នុងវរសេនាតូច។

នៅឆ្នាំ១៩៧៥ ខ្ញុំឈឺគ្រុនចាញ់ទៅដេកពេទ្យរហូតរំដោះប្រទេស។ ពេលដេកពេទ្យខ្ញុំមិនបានធ្វើសកម្មភាពទេព្រោះឈឺខ្លាំងរហូតដល់ជ្រុះសក់។ បន្ទាប់ពីខ្ញុំចេញពីពេទ្យខ្ញុំមកនៅអង្គភាពវិញបានកន្លះខែ អង្គការចាត់តាំងឲ្យខ្ញុំមកនៅវរសេនាតូច១០៧ នៅភ្នំពេញ។ ខ្ញុំនៅឃ្លាំងរដ្ឋផ្សារចាស់ ចំណែក ឈុំ មិនបានមកទេ។ ក្រោយពេលមកឃ្លាំងរដ្ឋផ្សារចាស់ ឈ្មោះ គុណ មកទទួលខុសត្រូវរួមឃ្លាំងរដ្ឋនេះ។ រយៈពេលកន្លះខែក្រោយមក ឈ្មោះ ស្រ៊ីបាននាំខ្ញុំទៅជួបឈ្មោះ គុណ ដើម្បីភ្ជាប់ខ្សែ សេ-អ៊ី-អា និងធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ និងដាក់ផែនការឲ្យដើរវើផ្ទុះ បំផ្លាញសម្ភារចោល។ បន្ទាប់ពីប្រជុំ យើងនាំគ្នាដើរវើផ្ទុះ ហើយយកគ្រឿងម៉ូតូ គ្រឿង ឡានយកទៅទម្លាក់ចោលក្នុងទឹកអូរខាងលិចផ្សារដើមគរអស់ចំនួន២០ ឡាំងក្រដាស។ ក្រោយមកខ្ញុំជាមួយ អោន គឺជាអនុប្រធានឃ្លាំងរដ្ឋខាងលិចផ្សារអូរឫស្សី បំផ្លាញស្រាពីរពាងធំៗ ។ មួយរយៈក្រោយមក គុណ បានមកផ្សារដើមគរ ហើយហៅកម្លាំង សេ-អ៊ី-អា ទាំងអស់មកណែនាំថា យើងត្រូវឈប់បំផ្លាញសម្ភារ គឺត្រូវយកសម្ភារទៅលាក់ទុកនៅផ្សារអូរឫស្សីដើម្បីត្រៀមទុកវាយបដិវត្តន៍វិញ។

នៅខែឧសភា ឆ្នាំ១៩៧៦ គូបានចាត់តាំងកម្លាំង

សេ-អ៊ី-អា ទាំងអស់ឲ្យដឹកគ្រឿងម៉ូតូ ឡាន ប្រេង យកទៅលាក់ទុកនៅផ្សារអូរប៉ុស្សីប្រហែល១ ឡាន សេអឹមសេ ត្រៀមវាយបដិវត្តន៍ ប៉ុន្តែសម្ភារទាំងនេះបានជូនអង្គការវិញហើយ។ នៅខែសីហា ឆ្នាំ១៩៦៧ ដដែល ឃ្លាំងរដ្ឋ និងអ្នកកាត់ដេររដ្ឋ បែកដាច់ពីគ្នា ហើយប្រមូលអ្នកកាត់ដេរទាំងអស់ទៅដាក់នៅផ្សារអូរប៉ុស្សី។ ខ្ញុំត្រូវមកនៅកាត់ដេររដ្ឋ ហើយកម្លាំង សេ-អ៊ី-អា ដែលទៅជួបគ្នានៅកាត់ដេររដ្ឋមានឈ្មោះ គុណ, គូ, ស្រស់ ប្រធានក្រុមកាត់ដេររដ្ឋនៅឆ្នាំ១៩៧៧, ចំរើន ប្រធានក្រុមកាត់ដេររដ្ឋ, រ៉ុន អនុក្រុមកាត់ដេររដ្ឋ ឆ្នាំ១៩៧៧, រៀម យុទ្ធជនកាត់ដេរឆ្នាំ១៩៧៧, សួត និង ទៀង ប្រធានក្រុមកាត់ដេររដ្ឋឆ្នាំ១៩៧៧។ ក្រោយពេលខ្ញុំទៅនៅកាត់ដេររដ្ឋ គុណ បានឲ្យខ្ញុំទៅរៀនកាត់ដេរខោអាវដោយឲ្យខ្ញុំឡើងជាសមាជិកក្រុម។ ខ្ញុំរៀនកាត់ដេរបានរយៈពេលមួយខែក៏ត្រឡប់មកនៅខាងជួសជុលម៉ាស៊ីនវិញ។ នៅចុងឆ្នាំ១៩៧៦ គុណ បានឲ្យអ្នកកាត់ដេររដ្ឋធ្វើរបងបិទផ្លូវមិនឲ្យយុទ្ធជនចូលយកសម្ភារក្នុងឃ្លាំងកាត់ដេរ។ ក្រោយមក យុទ្ធជន និងមន្ទីរកាត់ដេររដ្ឋមានទំនាស់គ្នារហូតជិត៣ខែ ទើបអង្គការចាប់ គុណ នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧។ ក្រោយពីអង្គការចាប់ គុណ ឈ្មោះ ឈុំ ប្រធានមន្ទីរកាត់ដេររដ្ឋ បានហៅខ្ញុំ, គូ, សួ, ម៉ុញ, សួត ទៅណែនាំនៅក្នុងវត្តអណ្តូងមាស ថាឥឡូវអង្គការចាប់ គុណ ហើយដូច្នេះយើងត្រូវបន្តសកម្មភាពតទៅទៀតនៅក្នុងក្រសួងដែលមាន នារី ខន គឺជាអនុប្រធានក្រសួងកាត់ដេរ។ ក្រោយពី ឈុំ បានណែនាំរួចហើយ គាត់បាននាំទាំងអស់គ្នាទៅជួប នារី ខន នៅក្នុងវត្តអណ្តូងមាស។ នារី ខន ក៏បានណែនាំយើងឲ្យស្គាល់ខ្សែ សេ-អ៊ី-អា បន្ថែមទៀត ហើយចាត់តាំងខ្ញុំជាប្រធានក្រុមកាត់ដេរជាមួយនារី។ រយៈពេល៥ថ្ងៃក្រោយមក ស្រាប់តែអង្គការចាប់ ឈុំ, សួត, ម៉ុញ។ ពេលនោះនារី ខន បានហៅខ្ញុំ, នារី គីន, នារី ខេង, នារី សន, នារី ភាព, នារី ភំ និង នារី អាន ឲ្យមកធ្វើស្រែខាងលិចប៉ុស្តិ៍វិទ្យុស្ទឹងមានជ័យវិញ។

នៅខែមេសា ឆ្នាំ១៩៧៧ នារី ខន បានហៅខ្ញុំ, លើម, ភាប់, ស្រស់, ឌឹម អតីតមេ១០ខ្ទង់ និង ធីម ទៅដាក់ផែនការឲ្យបំផ្លាញម៉ាស៊ីន និងជើងម៉ាស៊ីន។ ក្រោយពីទទួលបានផែនការនេះ ក្រុមខ្ញុំបានបំផ្លាញជើងម៉ាស៊ីនអស់ជិតកន្លះឃ្លាំង ដោយវាយកាច់បំបាក់ចោល។ នៅពាក់កណ្តាលខែមេសា ឆ្នាំ១៩៧៧ នារី ខន បានហៅខ្ញុំ, គូ, សួ, ធីម, នារី ខេង, នារី ដាន និង អាន មកប្រជុំនៅលើផ្ទះមួយកន្លែង ដែលស្ថិតនៅខាងលិចផ្ទះខ្ញុំស្នាក់នៅ។ ក្រោយពីប្រជុំចប់ នារី ខន បានចាត់តាំងខ្ញុំជាប្រធានកងតូចកន្លែងកាត់ដេរ។ ក្រោយមក ខ្ញុំបានចាត់តាំង ពេជ, បូ ឲ្យធ្វើសកម្មភាពបំផ្លាញម៉ាស៊ីនក្រឡឹងនៅកន្លែងកាត់ដេរអស់ចំនួន២គ្រឿង ដោយយកដីទៅរោយពីលើធ្វើឲ្យគាំងម៉ាស៊ីន។

នៅខែឧសភា ឆ្នាំ១៩៧៧ ខ្ញុំបានទៅយកប្រេងនៅក្រសួងដឹកជញ្ជូនទួលគោក ហើយពេលនោះខ្ញុំបានជួប ស្រី គឺជាខ្សែចាស់របស់ខ្ញុំនៅខាងលិចផ្សារអូរប៉ុស្សី តាមផ្លូវកម្ពុជាក្រោម។ ស្រី បានប្រាប់ថាកន្លែងឃ្លាំងលើកមកនៅខាងលិចផ្សារអូរប៉ុស្សីហើយ ដោយពីមុននៅផ្សារចាស់។ ខែមិថុនា ឆ្នាំ១៩៧៧ ខ្ញុំនិង សួ បានចាត់តាំង ពេជ, បូ, នាត និង សោយ ឲ្យធ្វើសកម្មភាពវាយជើងគ្រឿងម៉ាស៊ីនអស់មួយចំនួនហើយយកបោះចោលក្រៅឃ្លាំង។ ចុងខែមិថុនា ឆ្នាំ១៩៧៧ នារី ខន ចាត់តាំងខ្ញុំឲ្យធ្វើជាប្រធានកងធំកាត់ដេររដ្ឋ និង ឲ្យ ឈ្មោះ សួ ធ្វើជាអនុប្រធានខ្ញុំ។ ក្រោយពីចាត់តាំងបានរយៈពេល១០ថ្ងៃ អង្គការដកខ្ញុំឲ្យមកនៅកន្លែងយុទ្ធជនខាងលិចប៉ុស្តិ៍វិទ្យុស្ទឹងមានជ័យជាមួយឈ្មោះ ដាន និង អាន ដោយឲ្យដឹកប្រឡាយជាមួយយុទ្ធជនបានរយៈពេល១៥ថ្ងៃប៉ុណ្ណោះ អង្គការក៏ចាប់ខ្លួនខ្ញុំនៅពាក់កណ្តាលខែកក្កដា ឆ្នាំ១៩៧៧ នេះតែម្តង។

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារJ00៥៦៥។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខ ស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ ព្រំ ឡោ ហៅ ឌុន ពិតប្តុយ៉ាងណានោះទេ?***

# បណ្ណាល័យកុមារនៅតាមសហគមន៍ដាច់ស្រយាល

**គាត និត**



កុមារនៅសាលាបឋមសិក្សា ហ៊ុន សែន វត្តទឹកហូត បង្ហាញសៀវភៅដែលទទួលបានពីអ្នកស្ម័គ្រចិត្តកម្ពុជានៃមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៤ ក្រុមការងារបណ្ណាល័យកុមារ បានយកសៀវភៅបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជារួមមាន៖ ១) សៀវភៅការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម, ២) សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), ៣) សៀវភៅព័ត៌មានអំពីការថែទាំសុខភាព, ៤) ទស្សនាវដ្ដីស្វែងរកការពិត, សម្ភារសិក្សា និងសៀវភៅរឿងនិទានសម្រាប់កុមារមួយចំនួនទៀត ទៅចែកជូនសិស្សចំនួន១៩០នាក់ ដែលកំពុងរៀននៅសាលាបឋមសិក្សា ហ៊ុន សែន វត្តទឹកហូត ស្ថិតនៅក្នុងភូមិទឹកហូត ឃុំទឹកហូត ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

បណ្ណាល័យកុមារនេះបង្កើតឡើងដោយអ្នកស្ម័គ្រចិត្តកម្ពុជានៃមជ្ឈមណ្ឌលឯកសារកម្ពុជា រស់នៅតាមសហគមន៍ដាច់ស្រយាលក្នុងប្រទេសកម្ពុជា ដែលធ្វើការងារផ្ដោតលើផ្នែកសុខភាព និងផ្នែកប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដើម្បីជួយដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ បណ្ណាល័យកុមារនេះ មានការឧបត្ថម្ភគាំទ្រពីព្រះរាជបណ្ណាល័យហ្វូងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។

គោលបំណងនៃបណ្ណាល័យកុមារនេះគឺដើម្បីជំរុញទឹកចិត្តឲ្យអ្នកស្ម័គ្រចិត្តកម្ពុជា ទាំងអស់ ចង់ជួយសហគមន៍ដែលខ្លួនកំពុងរស់នៅ តាមរយៈការបង្កើតជាបណ្ណាល័យសម្រាប់កុមារតូចៗនៅតាមទីជនបទដាច់ស្រយាល។ បណ្ណាល័យកុមារនេះ នឹងជួយជំរុញ

កុមារឲ្យចង់អានសៀវភៅ ដែលជាប្រភពនៃចំណេះដឹង និងបណ្តុះនូវបញ្ញាញាណកុមារនៅកម្ពុជាឲ្យក្លាយជាធនធានដ៏មានតម្លៃសម្រាប់ប្រទេសកម្ពុជា។ មិនត្រឹមតែប៉ុណ្ណោះ ការអានសៀវភៅក៏ជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់សិស្សចាប់យកជំនាញ និងមុខវិជ្ជាផ្សេងៗទៀត ព្រមទាំងពង្រីកនូវចំណេះដឹងឲ្យកាន់តែទូលំទូលាយនៅពេលអនាគត។

តាមរយៈបណ្ណាល័យកុមារ នឹងជួយជំរុញកុមារឲ្យឆាប់ចេះអាន ឆាប់ចេះសរសេរភាសាខ្មែរឲ្យបានត្រឹមត្រូវ ធ្វើឲ្យកុមារគិតពិចារណា និងចងចាំបានល្អ។ បណ្ណាល័យកុមារក៏សូមអំពាវនាវដល់ឪពុកម្តាយកុមារ ជួយជំរុញកូនៗរបស់ខ្លួនឲ្យស្រឡាញ់សៀវភៅ ស្រឡាញ់ការអាន និងជួយស្វែងរកអំណានផ្សេងៗឲ្យកូនៗអានបន្ថែម ជាពិសេសអំណានជាភាសាខ្មែរ។










# ពិព័រណ៍រុក្ខជាតិ និងសួនច្បារភ្នំពេញ ជំរុញឱ្យមានការស្រឡាញ់រុក្ខជាតិ និងធម្មជាតិប្រទេសកម្ពុជា

សោម ប៊ុនថន





ការដាក់តាំងបង្ហាញពិព័រណ៍រុក្ខជាតិ នៅព្រះរាជបណ្ណាល័យហ្វូនម៉ែ និងមជ្ឈមណ្ឌលបែតង Connexion នាទីក្រុងកោះពេជ្រ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីថ្ងៃទី៥ ដល់ ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៤ មានការតាំងពិព័រណ៍រុក្ខជាតិ នៅមជ្ឈមណ្ឌលបែតង Connexion នាទីក្រុងកោះពេជ្រ។ ពិព័រណ៍រុក្ខជាតិនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សាភ្ជាប់អ្នកចូលចិត្តធម្មជាតិ និងប្រជាជនខ្មែរឲ្យកាន់តែមានភាពស្និទ្ធស្នាលជាមួយរុក្ខជាតិ និងធម្មជាតិប្រទេសកម្ពុជា។ នេះគឺជាលើកទី៣ហើយនៃការតាំងពិព័រណ៍រុក្ខជាតិ និងសួនច្បារភ្នំពេញ ដោយមានការចូលរួមពីម្ចាស់សួនរុក្ខជាតិមកពីរាជធានីភ្នំពេញ ខេត្ត និងមកពីបណ្ដាប្រទេសផ្សេងៗ។ ការតាំងពិព័រណ៍នៅពេលនេះ មិនត្រឹមតែបង្ហាញពីប្រភេទពូជរុក្ខជាតិដែលដុះលូតលាស់ក្នុងប្រទេសកម្ពុជា និងក្រៅប្រទេសប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្ហាញពីបច្ចេកទេសនៃការដាំដុះ និងការថែទាំរុក្ខជាតិទាំងនេះដែរ។ ពិព័រណ៍រុក្ខជាតិនេះមានភ្ញៀវទាំងជាតិ និងអន្តរជាតិចាប់អារម្មណ៍ចូលរួមទស្សនា និងទិញរុក្ខជាតិដែលខ្លួនពេញចិត្ត។

លោក ជ័យ វីរៈ និង កញ្ញា អាង សុខហេង គឺជានិស្សិតនៅសាកលវិទ្យាល័យ AMERICAN UNIVERSITY OF PHNOM PENH និងជាម្ចាស់ហាងរុក្ខជាតិ MYSTIQUE TROPICAL ។ ដែលស្ថិតនៅក្នុងទីក្រុងភ្នំពេញបានឲ្យដឹងថា «លោក និង កញ្ញា

សុខហេង ស្រឡាញ់រុក្ខជាតិ ហើយលោក និងកញ្ញា សុខហេង ក៏បានចូលរួមក្នុងការដាក់តាំងបង្ហាញរុក្ខជាតិក្នុងពិព័រណ៍នេះដែរ។ ប្រភេទរុក្ខជាតិដែលលោក នីង កញ្ញា សុខខេង ដាក់តាំងក្នុងពិព័រណ៍រុក្ខជាតិលើកទី៣នេះ គឺជាប្រភេទពូជរុក្ខជាតិដុះនៅក្នុងប្រទេសកម្ពុជា និងរុក្ខជាតិកម្រដែលនាំចូលពីបរទេសដែលត្រូវការបច្ចេកទេសទេសនៃការដាំដុះ និងការថែទាំឲ្យបានដិតដល់»។ ម្ចាស់ហាងវិយក្មេងទាំងពីររូបនេះបន្ថែមថា «លោកចង់ឲ្យយុវជន ក៏ដូចប្រជាជនខ្មែរស្រឡាញ់រុក្ខជាតិ និងថែរក្សារុក្ខជាតិរបស់ប្រទេសកម្ពុជា។ យើងដាំរុក្ខជាតិមិនត្រឹមតែលម្អនៅផ្ទះ សហគមន៍ ទីសាធារណៈឲ្យមានភាពស្រស់បំព្រងប៉ុណ្ណោះទេ ប៉ុន្តែយើងក៏អាចនាំរុក្ខជាតិដែលដុះលូតលាស់នៅក្នុងស្រុករបស់យើងចេញទៅប្រទេសក្រៅដែរ។ រុក្ខជាតិក៏អាចជួយរក្សាដល់បរិស្ថាននៅជុំវិញខ្លួនជួយបន្សុទ្ធខ្យល់អាកាសបរិសុទ្ធដល់ការដកដង្ហើម និងជួយកាត់បន្ថយកម្តៅ»។

លោក ជ័យ វីរៈ និងកញ្ញា អាង សុខហេង ក៏បានរៀបចំដាំរុក្ខជាតិទាំងនេះក្នុងសួនច្បាររព្រះរាជបណ្ណាល័យ ហ្វូងម៉ែ ដើម្បីលម្អ និងបង្ហាញដល់ភ្ញៀវដែលមកសិក្សាស្រាវជ្រាវ។

រុក្ខជាតិមានសារសំខាន់ណាស់ក្នុងការផ្សាភ្ជាប់ភ្ជាប់ជាមួយជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែររួមទាំងប្រពៃណី និងវប្បធម៌។








# មជ្ឈមណ្ឌលផ្សះផ្សាវាលវែងដឹកនាំយុវជនទស្សនកិច្ចសិក្សាតំបន់ប្រវត្តិសាស្ត្រយោធាតេជោភ្នំមាន់ (A4) វាលវែង

ឡុង ដានី



យុវជនមកពីស្រុកភ្នំក្រវាញទស្សនកិច្ចសិក្សាតំបន់ប្រវត្តិសាស្ត្រយោធា តេជោ ភ្នំមាន់ (A4) វាលវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង១:៣០នាទីរសៀលថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានដឹកនាំយុវជនមកពីស្រុកភ្នំក្រវាញចំនួន ២៣នាក់ ក្នុងចំណោមនោះមានស្រី ១៥នាក់ ទៅទស្សនាទីតាំងប្រវត្តិសាស្ត្រយោធាតេជោ ភ្នំមាន់ (A4) ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥៥ ឆ្ពោះទៅកាន់ចំណុចព្រំដែនកម្ពុជា-ថៃ។

ដំណើរទស្សនកិច្ចសិក្សានេះក៏ជាការឆ្លើយតបទៅនឹងប្រសាសន៍របស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ដែលបានអញ្ជើញជាអធិបតីក្នុងពិធីខួបអនុស្សាវរីយ៍លើកទី៤៧ ទិវានៃការចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត (២០មិថុនា ១៩៧៧-២០មិថុនា ២០២៤) និងពិធីបញ្ចុះបឋមសាលាសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម

(X16) កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤។ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត បានថ្លែងថា **«ខ្ញុំសូមឱ្យគ្រប់បណ្ដាខេត្ត បន្តជំរុញការរៀបចំសួនតេជោ សន្តិភាព ដែលបានកំណត់ជាក់ចេញតាមបណ្ដាខេត្តនីមួយៗ និងទីពីរចូលរួមនៅក្នុងការជំរុញការរៀបចំតំបន់ប្រវត្តិសាស្ត្រយោធាតេជោ នៅតាមទីតាំងដែលបានសិក្សានិងកំណត់ដោយក្រុមស្រាវជ្រាវប្រវត្តិសាស្ត្រយោធា»**។

យោងតាមអនុក្រឹត្យលេខ១៥៥ អនក្រ.បក ស្តីពីការកំណត់ទីតាំងប្រវត្តិសាស្ត្រយោធារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលចុះហត្ថលេខាដោយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ គឺមានតំបន់ប្រវត្តិសាស្ត្រយោធាសរុបចំនួន៨៧កន្លែង។

**ប្រវត្តិតំបន់ប្រវត្តិសាស្ត្រយោធាតេជោ ភ្នំមាន់ *(A4)* វាលវែង ៖**

តំបន់ប្រវត្តិសាស្ត្រយោធាតេជោ ភ្នំមាន់ (A4) វាលវែង ស្ថិតនៅក្នុងភូមិឯកភាព ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ តំបន់ប្រវត្តិសាស្ត្រយោធាតេជោ ភ្នំមាន់ (A4) វាលវែង មានចម្ងាយប្រមាណ ៥០ គីឡូម៉ែត្រពីចំណុចរង្វង់មូលប្រម៉ោយ និងប្រមាណ២០គីឡូម៉ែត្រពីរង្វង់មូលឃុំថ្មដា តាមផ្លូវជាតិលេខ៥៥។ តំបន់ប្រវត្តិសាស្ត្រយោធាតេជោ ភ្នំមាន់ (A4) វាលវែង ស្ថិតនៅចន្លោះកណ្ដាលដោយមានភ្នំជាច្រើនបាំងព័ទ្ធជុំវិញ ដូចជា ភ្នំ១៥០០ ភ្នំមាន់ និងភ្នំផ្សេងៗទៀត។

បើយោងតាម លោកឧត្តមសេនីយ៍ទោ គឹម សេងផន អតីតមេបញ្ជាការមួយរូបនៃកងពលធំលេខ៤នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ប្រចាំនៅសមរភូមិផ្លូវជាតិលេខ៥៦ បានឲ្យដឹងថា ក្នុងឆ្នាំ១៩៨៣ ឬឆ្នាំ១៩៨៤ កងទ័ពវៀតណាម និងកងពលលេខ៤នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានចាប់ផ្ដើមធ្វើប្រតិបត្តិការសឹកឆ្ពោះមកកាន់តំបន់ព្រំដែនថ្មដា។ នៅពេលនោះកងទ័ពនៃកងពលលេខ៤ និងកងទ័ពវៀតណាមបានមើលដែនទីរកចំណុចឈរជើង និងបានស្វែងរកឃើញតំបន់ A3 និង A4 ដើម្បីធ្វើជាទីបញ្ជាការស្រាល។ នៅអំឡុងពេលនោះ កងទ័ពមិនបានស្គាល់ឈ្មោះតំបន់នេះ ហើយកងទ័ពបានហៅឈ្មោះតាមចំណុចដែនទីថា តំបន់ A4 រហូតមកដល់សព្វថ្ងៃ។ ចំណែកកងទ័ពខ្មែរក្រហមបានហៅតំបន់A4នេះថា ចំណុចស្ពានដែក ឬ ថ្មដាធំ។



លោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ធ្វើបទបង្ហាញអំពីតំបន់ប្រវត្តិសាស្ត្រយោធាតេជោភ្នំមាន់ (A4) វាលវែង ដល់ក្រុមយុវជន។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីមុនរដ្ឋប្រហារឆ្នាំ១៩៧០ តំបន់ A4 ឬចំណុចស្ពានដែក ឬ ថ្មដាធំ គឺជាតំបន់ព្រៃភ្នំស្ថិតក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ និងជាកន្លែងដែលជនជាតិដើមភាគតិចព័រឆ្លងកាត់យកផ្លែក្រវាញ ដង្កោឆ្អឹងសត្វកម្រ និងខ្លឹមច័ន្ទក្រឹះស្នា ទៅលក់នៅផ្សារក្នុងស្រុកសុដាន់ហ៊ឹមនៃប្រទេសថៃដែលជាប់នឹងព្រំដែនកម្ពុជា-ថៃ ដើម្បីដោះដូរយកគ្រឿងទេស និងរបស់របរប្រើប្រាស់ប្រចាំថ្ងៃត្រឡប់មកផ្ទះវិញ។

នៅចន្លោះពីឆ្នាំ (១៩៧០ ដល់ ឆ្នាំ១៩៧៥) និងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) តំបន់ A4 ឬ ចំណុចស្ពានដែក ឬ ថ្មដាធំ ស្ថិតនៅក្នុងស្រុកពាមព្រុស តំបន់៦ ភូមិភាគពាយ័ព្យ។ នៅក្នុងរយៈពេលនោះខ្មែរក្រហមបានបញ្ជូនកងទ័ពមួយកងវរសេនាធំចំណុះកងពលទី២ នៃភូមិភាគពាយ័ព្យមកប្រតិបត្តិការ និងធ្វើសកម្មភាពប្រចាំនៅក្នុង

ស្រុកពាមព្រុស និងតំបន់ព្រំដែនកម្ពុជា-ថៃ ជាប់នឹងស្រុកសុជាន់ហ៊ឹមរបស់ប្រទេសថៃ។ ខ្មែរក្រហមបានសង់បន្ទាយកងទ័ពនៅតំបន់ផ្ទះ២០ (បច្ចុប្បន្នឃុំអន្លង់វាប) តំបន់ផ្ទះ៥ (បច្ចុប្បន្ន ភូមិដីក្រហម ឃុំអន្លង់វាប) ស្ថិតនៅជាប់ភ្នំ១៥០០ឬភ្នំស្វារអិល តំបន់ផ្ទះ៧ ស្ថិតនៅត្រើយខាងកើតស្ពានជ័យជម្នះ(ស្ពានមេទឹក) ក្នុងឃុំថ្មដាជាដើម។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ តំបន់A4 ឬ ចំណុចស្ពានដែក ឬ ថ្មដាធំ គឺជាមន្ទីរពេទ្យ និងភូមិរបស់ក្រុមគ្រួសារកងពល១៨, កងពល១៩, កងពល៣០៥ និងកងពល៤០៥ របស់ខ្មែរក្រហម ប្រចាំសមរភូមិមុខពាយ័ព្យ-ភ្នំពេញ និងសមរភូមិមុខនិរតី-ភ្នំពេញ រួមមាន៖ ខេត្តពោធិ៍សាត់, កំពង់ឆ្នាំង, កំពង់ស្ពឺ, កំពត, តាកែវ និងមួយផ្នែកនៃខេត្តកណ្ដាល និងទីក្រុងភ្នំពេញ។ ប្រធានកងពលលេខ១៨ មានឈ្មោះ កែវ ពង្ស, ប្រធានកងពលលេខ១៩ មានឈ្មោះ តាស៊ឹម ប្រធានកងពលលេខ៣០៥ មានឈ្មោះ ខឹម វ៉ន និងប្រធានកងពលលេខ៤០៥ មានឈ្មោះ សំ ប៊ិត។

ចន្លោះពីឆ្នាំ១៩៨៤ រហូតដល់ឆ្នាំ១៩៨៩ តំបន់A4 ឬ ចំណុចស្ពានដែក ឬ ថ្មដាធំ គឺជាទីបញ្ជាការស្រាលរបស់កងពលលេខ៤ នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម ហើយក៏ជាកន្លែងរក្សាទុកសម្ភារសឹក និងភ័ស្តុភាររបស់កងទ័ពទាំងពីរអង្គភាពខាងលើដែរ។ នៅតាមភ្នំក្បែរៗភូមិសាស្ត្រតំបន់A4 ឬ ចំណុចស្ពានដែក ឬ ថ្មដាធំនេះ គឺជាកន្លែងសម្រាប់ដាក់តាំងកាំភ្លើងធំ១៣០ និងដាក់កាំភ្លើងយន្តដេសេកា ដើម្បីការពារដែនអាកាសនៃកងទ័ពរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម។ តំបន់A4 ឬ ចំណុចស្ពានដែក ឬ ថ្មដាធំនេះ ក៏ជាចំណតសម្រាប់ចុះចតឧទ្ធម្ភាគចក្ររបស់ថ្នាក់ដឹកនាំនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបានធ្វើដំណើរមកសួរសុខទុក្ខកងទ័ព និងទទួលយកកងទ័ពដែលមានជំងឺ និងរបួសទៅព្យាបាលនៅទីក្រុងភ្នំពេញ ពីព្រោះនៅទីបញ្ជាការធំនៅតំបន់ផ្ទះ៧ (ស្ពឹងមេទឹក) មានចម្ងាយប្រមាណ១០គីឡូម៉ែត្រពីតំបន់ A4 ឬ ចំណុចស្ពានដែក ឬ ថ្មដាធំ គឺមានភូមិសាស្ត្រក្បែរព្រំដែនកម្ពុជា-ថៃនោះមិនអាចឲ្យឧទ្ធម្ភាគចក្រចុះចតបានទេ។

បើតាមឧត្តមសេនីយ៍ទោ គីម សេងឆន នៅអំឡុងឆ្នាំ១៩៨៦, ១៩៨៧ និង ១៩៨៨ មានថ្នាក់ដឹកនាំក្រសួងការពារជាតិ ចុះមកសួរសុខទុក្ខកងទ័ពនៅតំបន់ A4 ឬ ចំណុចស្ពានដែក ឬ ថ្មដាធំនេះ រួមមាន៖ សមមិត្ត ចាយ សាំងយុន, សមមិត្ត កុយ ប៊ុនថា, សមមិត្ត ជៀង អំ ជាដើម។

សព្វថ្ងៃភូមិសាស្ត្រតំបន់A4 ឬ ចំណុចស្ពានដែក ឬ ថ្មដាធំ នៅសេសសល់ផ្លូវចាស់ (អតីតផ្លូវជាតិលេខ៥៦) ចម្ងាយប្រហែល៥០០ម៉ែត្រ ដោយសាររាជរដ្ឋាភិបាលកម្ពុជាបានសាងសង់ផ្លូវជាតិលេខ៥៥ថ្មីវាងតំបន់A4 ឬ ចំណុចស្ពានដែក ឬ ថ្មដាធំនេះ (បច្ចុប្បន្នតំបន់ប្រវត្តិសាស្ត្រយោធាតេជោ ភ្នំមាន់ A4 វាលវែង)។

បន្ទាប់ពីទស្សនាតំបន់ប្រវត្តិសាស្ត្រយោធាតេជោភ្នំមាន់(A4) រួចមក ក្រុមយុវជនបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម៖

១) នាងខ្ញុំឈ្មោះ **ភា ថាវរី** អាយុ១៨ឆ្នាំ រស់នៅភូមិតាដែស ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ នាងខ្ញុំពិតជាមានសេចក្ដីសោមនស្សចំពោះដំណើរទស្សនកិច្ចសិក្សាតំបន់ប្រវត្តិសាស្ត្រយោធានៅស្រុកវាលវែង និងបានសិក្សាពីរបបខ្មែរក្រហមដែលបានជម្លៀសប្រជាជនកម្ពុជាពីទីក្រុងភ្នំពេញទៅតាមបណ្ដាខេត្តនានា និងបានធ្វើទារុណកម្មយ៉ាងឃោរឃៅព្រៃផ្សៃចំពោះកុមារនិងប្រជាជនកម្ពុជា។ ជាពិសេសនៅភ្នំ១៥០០ ដែលជាទីតាំងប្រវត្តិសាស្ត្រយោធាតេជោ ភ្នំមាន់(A4) គឺជាតំបន់មានរាងបាតខ្ទះដែលធ្វើឲ្យក្រុមខ្មែរក្រហមងាយស្រួលក្នុងការលាក់ខ្លួនពីកងទ័ពវៀតណាម។ នាងខ្ញុំពិតជារំភើបរីករាយណាស់បានសិក្សានិងបានស្គាល់ទីតាំងប្រវត្តិសាស្ត្រយោធាដែលខ្ញុំមិនដែលបានស្គាល់ពីមុនមក។



២) នាងខ្ញុំឈ្មោះ **ហង្ស ស្រីនីន** គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែន ភ្នំក្រវាញ។ នាងខ្ញុំបានយល់ដឹងកាន់តែច្រើនឡើងៗអំពីតំបន់ប្រវត្តិសាស្ត្រយោធាតេជោ ភ្នំមាន់ (A4) វាលវែង ខេត្តពោធិ៍សាត់ និងតំបន់ដែលខ្មែរក្រហមបោះទីតាំងសម្រាប់ធ្វើសមរភូមិប្រយុទ្ធ ដែលមានជួរភ្នំព័ទ្ធជុំវិញ ដែលធ្វើឲ្យកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជាពិបាកវាយចូលមក។ លើសពីនេះខ្មែរក្រហមធ្លាប់បាញ់កាំភ្លើងធំទៅកាន់យន្តហោះថៃនិងយន្តហោះរបស់សត្រូវផ្សេងទៀត។

៣) នាងខ្ញុំឈ្មោះ **ធិត្យ ស្រីនិច** ភេទស្រី អាយុ២១ឆ្នាំ មកពីស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ នាងខ្ញុំពិតជារំភើបនៅពេលបានស្គាល់ និងបានដឹងអំពីប្រវត្តិសាស្ត្រយោធាតេជោ ភ្នំមាន់ (A4) វាលវែង។ ទីតាំងនេះ គឺជាទីតាំងប្រវត្តិសាស្ត្រដ៏ជូរចត់នៃការវាយប្រយុទ្ធគ្នា។ នៅពេលខ្ញុំស្តាប់រឿងរ៉ាវដែលបានកើតឡើងក្នុងតំបន់នេះ ធ្វើឲ្យខ្ញុំកាន់តែចង់ដឹងពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាថែមទៀត។

៤) នាងខ្ញុំឈ្មោះ **ផុង រស្មី** ភេទស្រី អាយុ១៩ឆ្នាំ មកពីស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ខ្ញុំពិតជាសប្បាយចិត្តណាស់ ដែលបានមកសិក្សាពីប្រវត្តិសាស្ត្រយោធាតេជោ ភ្នំមាន់ (A4) វាលវែង និងប្រវត្តិសាស្ត្រខ្មែរក្រហម។ តំបន់ប្រវត្តិសាស្ត្រយោធាតេជោភ្នំមាន់ (A4) គឺជាតំបន់សមរភូមិប្រយុទ្ធ និងជាកន្លែងដែលខ្មែរក្រហមបានមកលាក់ខ្លួននៅលើភ្នំ ដែលកងទ័ពវៀតណាមពិបាកក្នុងការឡើងមកប្រយុទ្ធ។ ជាចុងក្រោយ ដើម្បីដឹងរឿងរ៉ាវឲ្យកាន់តែច្បាស់ ខ្ញុំនឹងខិតខំសិក្សា និងស្រាវជ្រាវពីប្រវត្តិសាស្ត្រខ្មែរក្រហមបន្ថែមទៀត។



យុវជនមកពីស្រុកភ្នំក្រវាញទស្សនកិច្ចសិក្សាតំបន់ប្រវត្តិសាស្ត្រយោធា តេជោ ភ្នំមាន់ (A4) វាលវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចែករទេះរុញ និងការសង្គ្រោះជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅស្រុកវាលវែង ខេត្តពោធិ៍សាត់

ឡាំ ស្រីនីត, ចាន់ ណារិទ្ធ



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ទទួលរទេះរុញ និងការសង្គ្រោះជំនួយត្រចៀក ពីក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៩ និងថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានចុះទៅកាន់ភូមិប្រម៉ោយ ភូមិស្ទឹងថ្មី និងភូមិឈើទាលជ្រុំ ស្ថិតនៅក្នុងឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដើម្បីផ្តល់រទេះរុញ និងការសង្គ្រោះជំនួយត្រចៀកជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៤នាក់ ដែលមានពិការភាព។

ជាដំបូង លោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានធ្វើការណែនាំខ្លួន និងក្រុមការងារទៅកាន់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងមេភូមិ អំពីគោលបំណងដែលក្រុមការងារចុះមកនាពេលនេះគឺចង់សម្រាលទុក្ខលំបាកដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងការធ្វើដំណើរទៅមកប្រចាំថ្ងៃ និងទំនាក់ទំនងជាមួយសមាជិកក្នុងគ្រួសារ បងប្អូនក្នុងសហគមន៍ ដោយផ្តល់ជារទេះរុញ និងការសង្គ្រោះជំនួយត្រចៀក។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់ គឺជាអ្នកដែលបានរួចផុត

ជីវិតពីរបបខ្មែរក្រហម និងជាសាក្សីរស់ដែលអាចនិយាយរឿងរ៉ាវដែលខ្លួនបានឆ្លងកាត់របបខ្មែរក្រហម ប្រាប់ទៅកូនចៅជំនាន់ក្រោយឲ្យបានដឹងពីការឈឺចាប់ ការបែកបាក់ ព្រមទាំងទុក្ខលំបាកគ្រប់បែបយ៉ាងនៅក្នុងរបបខ្មែរក្រហម ដើម្បីទប់ស្កាត់កុំឲ្យមានអំពើប្រល័យពូជសាសន៍កើតឡើងសារជាថ្មី។

តមកលោក សូត្រ ដា អាយុ៥២ឆ្នាំ គឺជាប្រធានភូមិស្ទឹងថ្មី បានមានប្រសាសន៍ថា ការចែករទេះរុញ និងកាសជំនួយត្រចៀកជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព គឺមានផលប្រយោជន៍ច្រើន ព្រោះគាត់អាចធ្វើដំណើរ និងអាចធ្វើការងារតិចតួចជុំវិញផ្ទះបានងាយស្រួលជាងមុន។ លោក សូត្រ ដា បានបន្តថា ខ្ញុំសប្បាយចិត្តនៅពេលដែលក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានចូលរួមចំណែក និងយកចិត្តទុកដាក់ចំពោះជនពិការដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងភូមិរបស់ខ្ញុំ។ ការចែករទេះរុញ និងកាសជំនួយត្រចៀកបានជួយសម្រាលបន្ទុកក្នុងគ្រួសាររបស់ជនពិការបានមួយកម្រិត និងងាយស្រួលទំនាក់ទំនងជាមួយអ្នកជិតខាងបានល្អប្រសើរជាងមុន។

បន្ទាប់ពីស្តាប់ប្រសាសន៍របស់លោកមេភូមិ សូត្រ ដា រួច ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានចែករទេះរុញ និងកាសជំនួយត្រចៀកដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅក្នុងឃុំប្រម៉ោយ។ នៅក្នុងឱកាសនេះ អ្នករស់រានមានជីវិតពីរបបខ្មែរទាំង៤នាក់ដែលមានពិការភាព បានបង្ហាញនូវចំណាប់អារម្មណ៍ផ្ទាល់ខ្លួនដូចខាងក្រោម៖

ខ្ញុំឈ្មោះ **សុក ភ័ក្រ** អាយុ៦៧ឆ្នាំ កើតនៅភូមិរការ ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល។ សព្វថ្ងៃខ្ញុំរស់នៅក្នុងភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ សម្រាប់ខ្ញុំដែលជាជនពិការ រទេះរុញពិតជាមានសារសំខាន់សម្រាប់ខ្ញុំ ព្រោះចាប់តាំងពីខ្ញុំធ្លាក់ខ្លួនពិការមក ខ្ញុំមិនដែលបានចេញទៅណាមកណានោះទេ។ ខ្ញុំធ្លាក់ខ្លួនពិការអស់រយៈពេលជាង២ឆ្នាំមកហើយ ខ្ញុំពិតជាមិនសប្បាយចិត្តទេ ព្រោះមិនសូវមានទំនាក់ទំនងជាមួយសាច់ញាតិ និងមិនអាចទៅពិនិត្យសុខភាពជាញឹកញាប់បាន ព្រោះពិបាកក្នុងការធ្វើដំណើរ។ ស្ថានភាពជីវភាពគ្រួសាររបស់ខ្ញុំ ចាប់ផ្តើមពិបាកតាំងពីខ្ញុំដើរមិនរួច ព្រោះខ្ញុំមិនអាចរកចំណូលបានដូចមុន ហើយកូនខ្ញុំក៏មិនបានចេញទៅរកស៊ីឆ្ងាយបាន ព្រោះត្រូវនៅមើលថែខ្ញុំ។ ខ្ញុំទទួលបានរទេះរុញ ខ្ញុំគិតថា ជីវិតរបស់ខ្ញុំនឹងទទួលបាននូវភាពរីករាយ និងសប្បាយចិត្តបានច្រើនជាងមុន ព្រោះខ្ញុំអាចជិះរទេះរុញដោយខ្លួនឯងនៅជុំវិញផ្ទះ ហើយកូនៗរបស់ខ្ញុំមិនចាំបាច់នៅមើលថែខ្ញុំគ្រប់ពេល និងមានពេលវេលាចេញទៅប្រកបមុខរបរផ្សេងៗ។ រទេះរុញអាចជួយខ្ញុំទៅយករបស់របរប្រើប្រាស់បានដោយខ្លួនឯង អាចប្រាស្រ័យទាក់ទងគ្នាជាមួយញាតិមិត្តជិតខាង និងអាចជួយការងារផ្ទះបានបន្តិចបន្តួច ជាពិសេសខ្ញុំងាយស្រួលទៅមន្ទីរពេទ្យដើម្បីពិនិត្យសុខភាព។

ខ្ញុំឈ្មោះ **គង់ សុខុម** ភេទប្រុស អាយុ៦៨ឆ្នាំ កើតនៅភូមិធម្មវិន័យ ឃុំស្នោ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ សព្វថ្ងៃខ្ញុំរស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ក្នុងរបបខ្មែរក្រហម ខ្ញុំគឺជាអ្នកបើកយន្តហោះចម្បាំងខ្មែរក្រហម។ រាល់ថ្ងៃនេះ ខ្ញុំមិនអាចដើរទៅណាមកណាបានទេ គឺខ្ញុំអង្គុយនៅតែមួយកន្លែងតែប៉ុណ្ណោះ។ វាពិតជាពិបាកខ្លាំងណាស់ ពេលខ្ញុំចង់ដើរទៅណាម្តងៗលុះត្រាតែមានកូនចៅជួយគ្រា ទើបអាចដើរបាន។ រទេះរុញមួយនេះ វាពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ខ្ញុំ វាជួយសម្រួលដល់ខ្ញុំក្នុងការធ្វើដំណើរនៅជុំវិញផ្ទះ ឬក៏ទៅមន្ទីរពេទ្យបានយ៉ាងងាយស្រួល ហើយមួយវិញទៀតកូនចៅរបស់ខ្ញុំក៏មិនចាំបាច់ជួយគ្រាខ្ញុំដូចមុនដែរ។ ខ្ញុំពិតជាអរគុណខ្លាំងណាស់ដល់មជ្ឈមណ្ឌលផ្សះផ្សាវាលវែងដែលបានឧបត្ថម្ភរទេះរុញដល់ខ្ញុំ។

ខ្ញុំឈ្មោះ **សូ ធន** ភេទប្រុស អាយុ៦៩ឆ្នាំ កើតនៅភូមិបឹង ឃុំបឹង ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ សព្វថ្ងៃរស់នៅភូមិឈើទាលជ្រុំ ឃុំប្រម៉ោយ ស្រុកវាលវែង

ខេត្តពោធិ៍សាត់។ ខ្ញុំចាប់ផ្ដើមមានបញ្ហាធ្ងន់ត្រចៀកតាំងពីឆ្នាំ២០០៨មក ដោយសារជំងឺគ្រុនចាញ់។ ជំងឺគ្រុនចាញ់ធ្វើឲ្យខ្ញុំមានអាការញ័រញាក់ជាខ្លាំង និងត្រូវព្យាបាលរយៈពេលមួយឆ្នាំទើបជាសះស្បើយ។ ចំណែកត្រចៀករបស់ខ្ញុំក៏ចាប់ផ្ដើមស្ដាប់មិនឮតាំងពីពេលនោះមក។ ដំបូងឡើយ ខ្ញុំមានអារម្មណ៍ថាសប្បាយរីករាយយ៉ាងខ្លាំង នៅពេលដែលមានក្រុមអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចុះមកសម្ភាសន៍ខ្ញុំ អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដែលខ្ញុំបានឆ្លងកាត់ដោយផ្ទាល់។ បន្ទាប់មកទៀត ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែងក៏បានចុះមកចែកកាសជំនួយត្រចៀកដល់ខ្ញុំដែលពិបាកក្នុងការស្ដាប់។ កាសជំនួយត្រចៀកនេះ ពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ខ្ញុំ វាជួយខ្ញុំឲ្យស្ដាប់បានច្បាស់ជាងមុន និងមានទំនាក់ទំនងជាមួយអ្នកជិតខាង ព្រមទាំងអាចប្រកបរបរ និងធ្វើការងារផ្សេងៗ។

ខ្ញុំឈ្មោះ **ច្រួន ធុត** ភេទប្រុស អាយុ៧៨ឆ្នាំ កើតនៅភូមិដំណាក់ធ្លង់ ឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់។ សព្វថ្ងៃខ្ញុំរស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំគឺជាកងទ័ព។ សព្វថ្ងៃខ្ញុំមានបញ្ហាត្រចៀក ដោយសារចាស់ជរា និងជំងឺកាលពី៤ឆ្នាំមុន បណ្ដាលឲ្យខ្ញុំស្ដាប់មិនឮ និងពិបាកក្នុងការទំនាក់ទំនងជាមួយប្រពន្ធកូន និងអ្នកជិតខាង។ ពេលត្រូវការនិយាយស្ដីម្ដងៗ ត្រូវនិយាយឲ្យខ្លាំងៗ ប៉ុស្រែក ទើបខ្ញុំអាចស្ដាប់ឮ ដូច្នេះសមាជិកគ្រួសារមិនចង់និយាយជាមួយខ្ញុំឡើយ។ ខ្ញុំពិតជាសប្បាយចិត្តខ្លាំងណាស់ដែលក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានយកកាសជំនួយត្រចៀកមកឲ្យខ្ញុំដោយផ្ទាល់។ កាសជំនួយត្រចៀកនេះ ពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់អ្នកដែលមានត្រចៀកធ្ងន់ដូចជារូបខ្ញុំ។ កាសនេះអាចជួយឲ្យខ្ញុំស្ដាប់ឮជាងមុន និងមិនសូវពិបាកដល់កូនចៅពេលដែលស្រែកហៅខ្ញុំម្ដងៗ។ ចុងក្រោយ ខ្ញុំសំណូមពរដល់ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង សូមបន្តចុះចែកកាសជំនួយត្រចៀកឲ្យបានច្រើនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានបញ្ហាធ្ងន់ត្រចៀក។ ខ្ញុំសូមអរគុណដល់ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង សូមឲ្យជួបតែសេចក្ដីសុខ ធ្វើការងារអ្វីសូមឲ្យបានសម្រេច និងជួបតែមនុស្សល្អៗ។







ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តស្ទឹងត្រែង

## ផ្តល់រទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព នៅស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង

*ស៊ាង ចិន្តា*



ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាចែករទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព នៅស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ ដឹកនាំដោយលោក ព្រាប សារ៉េត អនុប្រធានការិយាល័យរដ្ឋបាល ផ្តល់រទេះរុញចំនួន៥គ្រឿង ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាពចំនួន៥នាក់ រស់នៅភូមិអូរស្វាយ និងភូមិអូររុណ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ការផ្តល់រទេះរុញទាំង៥គ្រឿងជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅពេលនេះ គឺដើម្បីជួយសម្រួលដល់ការធ្វើដំណើរប្រចាំថ្ងៃនិងទុក្ខលំបាករបស់គាត់។

នៅក្នុងឱកាសនោះ លោក ព្រាប សារ៉េត តំណាងឲ្យលោក លី មីណា អភិបាលនៃគណៈអភិបាលស្រុកបុរីអូរស្វាយសែនជ័យ បានថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបាននាំយករទេះរុញមកជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព និងជរាភាពនៅក្នុងមូលដ្ឋានរបស់គាត់។ ការផ្តល់ជូនរទេះរុញនៅពេលនេះ គឺនៅក្នុងពេលវេលាដ៏ត្រឹមត្រូវ និងមានសារសំខាន់

ណាស់ ខណៈដែលគាត់អាចមានភាពងាយស្រួលក្នុងការធ្វើដំណើរទៅទទួលការព្យាបាល និងការជួបប្រជុំៗ បន្ថែមលើនេះទៀត ការផ្តល់រទេះរុញនាពេលនេះ គឺជាការឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់របស់អាជ្ញាធរមូលដ្ឋាន និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមិនទុកចោលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងគ្រាលំបាកឡើយ។

បន្ទាប់ពីលោក ព្រាប សារ៉េត មានប្រសាសន៍ចប់ លោក ស៊ាង ចិន្តា និងក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រគល់រទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព ព្រមទាំងសួរនាំគាត់អំពីសុខទុក្ខ និងរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហមដែលបានសង្ខេបដូចខាងក្រោម៖

**ហ៊ីម ម៉ាលី** អាយុ៦៦ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងមានពិការភាពមិនអាចដើររួចរយៈពេល៧ឆ្នាំ បានរៀបរាប់ថា «ខ្ញុំឈ្មោះ ហ៊ីម ម៉ាលី កើតនៅភូមិអំពិល ឃុំកន្ទុំ ស្រុកអង្គរជ័យ ខេត្តកំពត។ ខ្ញុំរៀបការជាមួយប្ដីឈ្មោះ ពុំ ភារម្យ។ ខ្ញុំគឺជាកូនទី១០ ក្នុងចំណោមបងប្អូនទាំងអស់ចំនួន១៣នាក់ ដែលមាន៧នាក់ស្លាប់ក្នុងរបបខ្មែរក្រហម។ នៅវ័យកុមារ ខ្ញុំរៀនថ្នាក់ទី១២ចាស់ នៅខេត្តកំពត។ នៅឆ្នាំ១៩៦៩ បងប្រុសរបស់ខ្ញុំឈ្មោះ ហ៊ីម ឌីន គឺជាទាហាននិរសុកម្ម និងត្រូវបានបញ្ជូនមកបុរីអូរស្វាយសែនជ័យនៅចន្លោះឆ្នាំ១៩៦៤ និងឆ្នាំ១៩៦៥ បាននាំខ្ញុំមករស់នៅជាមួយគាត់នៅអូរស្វាយ ដើម្បីជួយមើលថែកូនរបស់គាត់។ ខ្ញុំមកដល់មិនដល់រយៈពេល១ឆ្នាំផង រដ្ឋប្រហាររបស់ លន់ នល់ បានកើតឡើង។ នៅពេលនោះ ក៏ចាប់ផ្ដើមមានការទម្លាក់គ្រាប់បែកនៅបន្ទាយទាហាន។ រាល់ពេលដែលមានការទម្លាក់គ្រាប់បែកម្តងៗ ខ្ញុំនិងគ្រួសារបងប្រុសខ្ញុំរត់គេចខ្លួនទៅជ្រកនៅតាមអូរ។ ការទម្លាក់គ្រាប់បែកនៅពេលនោះមានរយៈពេលពីកន្លះម៉ោងទៅ១ម៉ោង។ ចាប់ពីចុងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៣ ទាហាន លន់ នល់ តែងតែទទួលរងការវាយប្រហារពីកងទ័ពរំដោះខ្មែរក្រហម។ នៅឆ្នាំ១៩៧៤ និងឆ្នាំ១៩៧៥ ខ្ញុំនិងគ្រួសារបងប្រុសបន្តរស់នៅបុរីអូរស្វាយដដែល។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើការងារនៅស្តៅ គឺធ្វើស្រែប្រាំង, លើកភ្លឺស្រែ និងកាស់គល់ឈើ។ ខ្ញុំនៅកងចល័តនារី ដែលមានគ្នាចំនួន៣០នាក់។ ខ្ញុំនិងក្រុមរបស់ខ្ញុំត្រូវលើកភ្លឺស្រែប្រវែង១០ម៉ែត្រនៅពេលព្រឹក និងនៅពេលល្ងាចលើកឲ្យបាន១០ម៉ែត្របន្ថែមទៀត។ ប្រធានកងចល័តមានឈ្មោះ មិត្ត ចា និងមិត្ត ដាន់។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ខ្ញុំបានវិលត្រឡប់មករស់នៅអូរស្វាយ រហូតមកដល់សព្វថ្ងៃ»។

**នុត ចំរើន** អាយុ៦៨ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់ទៀត និងមានពិការភាពមិនអាចដើររួចរយៈពេលជិត៥ឆ្នាំ រស់នៅភូមិគគីរសែនជ័យ២ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង រៀបរាប់អំពីបទពិសោធន៍ក្នុងរបបខ្មែរក្រហម និងអារម្មណ៍រំភើបបន្ទាប់ពីទទួលបានរទេះរុញថា «ខ្ញុំមានស្រុកកំណើតនៅឃុំអង្គតាចាក ស្រុកបាទី ខេត្តតាកែវ ។ ខ្ញុំមានបងប្អូនចំនួន៣នាក់ គឺស្រី២និងប្រុសម្នាក់។ កាលនៅក្មេង ខ្ញុំរៀននៅសាលាឯកជនទទួលប្រស្រី រហូតដល់ថ្នាក់ទី១១ចាស់។ ក្រោយមក ខ្ញុំបានឈប់រៀន ពីព្រោះខ្ញុំកំព្រាម្តាយឪពុក និងមានតែបងប្អូន៣នាក់។ នៅពេលរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ខ្ញុំផ្លាស់ទៅនៅភ្នំពេញ និងរស់នៅម្តុំកៀនស្វាយនៅឆ្នាំ១៩៧២។ ខ្ញុំដេកនៅតាមមុខផ្ទះប្រជាជន។ នៅពេលដែលទីក្រុងភ្នំពេញត្រូវបានរំដោះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅខេត្តបាត់ដំបង ដោយដើរថ្មើរជើងជាមួយប្រជាជនជាច្រើននាក់ទៀត។ ខ្ញុំដើររយៈពេលកន្លះខែទើបបានទៅដល់ភូមិភ្នំធំ ខេត្តបាត់ដំបង។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅលើកទំនប់កំពីងពួយ។ ខ្ញុំត្រូវក្រោកម៉ោង៤ទៀបភ្លឺដើម្បីទៅតម្រង់ជួរ និងមានស្ពាយចានឆ្នាំងនៅជាប់ខ្លួនការពារកុំឲ្យបាត់។ ខ្ញុំលើកទំនប់ចាប់ពីម៉ោង៦ព្រឹករហូតដល់ម៉ោង១១ព្រឹក ទើបឈប់សម្រាកហូបបបររាវ។ ខ្មែរក្រហមឲ្យខ្ញុំលើកទំនប់ប្រវែង៤ម៉ែត្រ ទៅ៦ម៉ែត្រក្នុង១ថ្ងៃ។ ខ្ញុំចាប់ផ្តើមធ្វើការបន្តនៅម៉ោង១រសៀល ដល់ម៉ោង៦យប់

ទើបបានឈប់ និងទទួលរបបអាហារ។ ចាប់ពីម៉ោង៧ដល់ម៉ោង៩ ខ្ញុំនិងអ្នកផ្សេងទៀតនៅកងចល័តត្រូវចូលរួមប្រជុំទិតៀន។ ខ្ញុំត្រូវបានអង្គប្រជុំទិតៀន ហើយប្រធានឃុំបានហៅខ្ញុំទៅអប់រំ រួចហើយបានដោះលែងមកវិញ។ ខ្ញុំរៀបការប្តីក្រោយរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ នៅឆ្នាំ១៩៩៤ ខ្ញុំនិងគ្រួសារមករស់នៅកៀនស្វាយ ហើយឆ្នាំ២០១៣ ទើបខ្ញុំនិងគ្រួសារបានផ្លាស់មករស់នៅស្រុកបុរីអូរស្វាយសែនជ័យ រហូតមកដល់សព្វថ្ងៃ»។

**កើត វ៉ាន់ថុន** អាយុ៧២ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់ទៀត និងមានពិការភាពមិនអាចដើររួច ចែករំលែករឿងរ៉ាវរបស់ខ្លួនថា «ខ្ញុំឈ្មោះកើត វ៉ាន់ថុន រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ខ្ញុំរៀបការប្រពន្ធឈ្មោះ សាន នាង និងមានកូនប្រុសម្នាក់។ កាលនៅពីក្មេង ខ្ញុំរៀនបានដល់ថ្នាក់ទី៧ចាស់ នៅសាលាបឋមសិក្សារាជានគរ។ នៅសម័យនោះ ខ្ញុំក៏រៀនភាសាបារាំងដែរ និងចេះអានភាសាបារាំងបន្តិចបន្តួច។ ខ្ញុំឈប់រៀនដោយសារតែខ្ញុំមានតែម្តាយ និងមានជីវភាពក្រលំបាក។ ម្តាយខ្ញុំធ្វើជាកម្មករនៅត្រារ៉ូ ហើយខ្ញុំធ្វើការងារសម្អាតស្មៅតាមចិញ្ចើមថ្នល់។ ខ្ញុំទទួលបានប្រាក់ខែចំនួន៧៥០រៀល។ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំបានចូលធ្វើជាទាហានលន់ នល់។ ក្រោយមក បន្ទាយទាហានរបស់ខ្ញុំ ត្រូវបានកងទ័ពរំដោះខ្មែរក្រហមវាយប្រហារ ទើបខ្ញុំវិលត្រឡប់មកផ្ទះវិញ។ នៅពេលដែលកងទ័ពរំដោះខ្មែរក្រហមចូលក្នុងភូមិ ខ្ញុំក៏សម្រេចចិត្តចូលបម្រើជាកងទ័ពរំដោះខ្មែរក្រហមវិញ។ នៅឆ្នាំ១៩៧៥ ខ្ញុំផ្លាស់មកនៅកងដឹកជញ្ជូនរហូតដល់ឆ្នាំ១៩៧៩។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ខ្ញុំមករស់នៅផ្ទះវិញ»។

**ឈឹម ច័យ** អាយុ៦៧ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងមានពិការភាពមិនអាចដើររួចរយៈពេលជិត៧ឆ្នាំ។ សព្វថ្ងៃ ឈឹម ច័យ រស់នៅភូមិអូររុណ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង មានប្រសាសន៍ថា «ខ្ញុំរៀបការប្រពន្ធឈ្មោះ ហៃ សុខជា និងមានកូនចំនួន៨នាក់ ក្នុងនោះប្រុស៥នាក់និងស្រី៣នាក់។ ខ្ញុំមានបងប្អូនចំនួន៣នាក់ ហើយខ្ញុំគឺជាកូនពៅនៅក្នុងគ្រួសារ។ កាលពីក្មេង ខ្ញុំបានចូលរៀន និងចេះអក្សរដែរ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវបានបង្ខំឲ្យលើកទំនប់ និងធ្វើស្រែគ្មានពេលសម្រាក ហើយ ហូបមិនបានគ្រប់គ្រាន់ទេ។ ខ្ញុំរស់នៅពិបាកណាស់ក្នុងរបបខ្មែរក្រហម។ ខ្ញុំបាត់បង់បងប្រុសម្នាក់ក្នុងរបបខ្មែរក្រហម។ ខ្ញុំពិការដើរមិនរួចរយៈពេល៧ឆ្នាំមកហើយ។ ខ្ញុំសូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានផ្តល់រទេះរុញឲ្យខ្ញុំដើម្បីជួយសម្រួលក្នុងការដំណើរ»។







ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាចែករទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកោះថ្ម ផ្តល់រទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជនដែលមានពិការភាពរស់នៅឃុំជាំតាម៉ៅ និង ឃុំទន្លូង

ឈុំ រ៉ា




ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មចែករទេះរុញ និងកាសជំនួយត្រចៀកជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាពនៅឃុំជាំតាម៉ៅ និងឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានយករទេះរុញចំនួន៣គ្រឿង និង កាសជំនួយត្រចៀកចំនួន៥ ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅក្នុងឃុំជាំតាម៉ៅ និង ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ការផ្តល់ជូនរទេះរុញ និងកាសជំនួយត្រចៀកនេះ គឺស្របតាមគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ការផ្តល់រទេះរុញ និងកាសជំនួយត្រចៀក គឺជាផ្នែកមួយនៃកិច្ចជួយគាំទ្រជ្រោមជ្រែង ដល់អ្នកមានពិការភាពអាចចូលរួមធ្វើសកម្មភាពផ្សេងៗក្នុងសហគមន៍ ជាពិសេសគឺការជួយផ្សព្វផ្សាយ និងចែករំលែករឿងរ៉ាវ និងបទពិសោធន៍ដែលគាត់ធ្លាប់ឆ្លងកាត់របបខ្មែរក្រហមដល់យុវជនជំនាន់ក្រោយដើម្បីជាការទប់ស្កាត់អំពើប្រល័យពូជសាសន៍កុំឲ្យកើតមានឡើងនាថ្ងៃអនាគត។

បន្ទាប់ពីទទួលបានរទេះរុញ និងកាសជំនួយត្រចៀករួច អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖

ខ្ញុំឈ្មោះ **គួច រឿង** ភេទប្រុស អាយុ៦៧ឆ្នាំ គឺជាជនជាតិស្មៀង កើតនៅភូមិកន្ទួត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃ ខ្ញុំរស់នៅភូមិកន្ទួត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំពិការជើងដោយសារត្រូវគ្រាប់ផ្លោងនៅចុងឆ្នាំ១៩៧៨ អំឡុងពេលមានការបាញ់គ្នារវាងកងទ័ពតំបន់២១ ជាមួយទាហានលន់ នល់។ ពេលខ្ញុំធ្លាក់ខ្លួនពិការ ខ្ញុំពិបាកក្នុងការធ្វើដំណើរ និងធ្វើការងារផ្សេងៗ។ ចំណែកជីវភាពគ្រួសារខ្ញុំចាប់ផ្តើមធ្លាក់ចុះ ណាមួយកូនៗខ្ញុំត្រូវបួលសាលារៀន។ ខ្ញុំពិតជាពិបាកក្នុងការធ្វើការងារណាស់ ទោះជាការងារនោះងាយស្រួលសម្រាប់មនុស្សធម្មតាក៏ដោយ។ កាលពីជិត១០ឆ្នាំមុនជីវភាពក្រុមគ្រួសារខ្ញុំមានការពិបាកខ្លាំង ខ្ញុំពិបាកចិត្ត និងគិតច្រើនណាស់។ សម្រាប់រទេះរុញដែលក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ជូនមកខ្ញុំពេលនេះ គឺមានសារប្រយោជន៍ច្រើនសម្រាប់ខ្ញុំនិងគ្រួសារ។ ខ្ញុំអាចទៅវត្តស្តាប់ព្រះសង្ឃសូត្រធម៌ និងជិះដើរលេងនៅជិតៗផ្ទះដោយខ្លួនឯង មិនចាំបាច់ប្រើប្រពន្ធ កូនជួយឡើយ។ រទេះរុញនេះអាចជួយផ្លូវចិត្តខ្ញុំឲ្យរួចផុតពីការធុញថប់ ដែលកន្លងមកធ្លាប់នៅតែមួយកន្លែងមិនសូវបានចេញទៅកន្លែងណាឡើយ។ ជាចុងក្រោយខ្ញុំ និងក្រុមគ្រួសារ សូមអរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម សូមទទួលបាននូវសេចក្តីសុខ សុភមង្គលក្នុងគ្រួសារ មានអ្នកស្រឡាញ់ចូលចិត្ត និងជោគជ័យគ្រប់ភារកិច្ច។

ខ្ញុំឈ្មោះ **ថូន សារឹម** ភេទស្រី អាយុ៦៨ឆ្នាំ ជនជាតិដើមភាគតិចស្មៀង។ ខ្ញុំមានបញ្ហាត្រចៀក និងស្តាប់មិនឮតាំងពីឆ្នាំ២០២១។ ខ្ញុំមិនដឹងមូលហេតុអ្វីទេ ព្រោះសុខៗស្រាប់តែខ្ញុំហឹងត្រចៀក ហើយធ្វើឲ្យខ្ញុំស្តាប់មិនឮ។ ខ្ញុំពិតជាពិបាកក្នុងការស្តាប់ណាស់។ ខ្ញុំពិតជាចង់និយាយជាមួយកូនចៅណាស់ប៉ុន្តែខ្ញុំស្តាប់មិនឮ។ យូរៗទៅកូនចៅ លែងចង់និយាយជាមួយខ្ញុំ ប៉ុន្តែពេលនេះខ្ញុំអាចឮ និងអាចនិយាយជាមួយកូនចៅនៅក្នុងគ្រួសារ និងបងប្អូនញាតិមិត្ត



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មចែករទេះរុញ និងកាសជំនួយត្រចៀកជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាពនៅឃុំជាំតាម៉ៅ និងឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មចែករទេះរុញ និងកាសជំនួយត្រចៀកជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅឃុំជាំតាម៉ៅ និងឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រស់នៅក្នុងភូមិបាន។ ពេលខ្ញុំស្តាប់មិនបាន ខ្ញុំមានអារម្មណ៍មិនល្អ និងតឹងទ្រូង ប៉ុន្តែការពិតកូនចៅនិយាយល្អដាក់ខ្ញុំ។ ចំពោះសុខភាពខ្ញុំ កាលពីប៉ុន្មានថ្ងៃមុននេះ ខ្ញុំឈឺដល់ថ្នាក់ដាំបាយមិនកើតឲ្យប្អូននៅខាងកើតមកជួយដាំបាយ។ កាសជំនួយត្រចៀកនេះអាចឲ្យខ្ញុំមានទំនាក់ទំនងល្អប្រចាំថ្ងៃជាមួយអ្នកនៅជុំវិញខ្លួនបានល្អប្រសើរ។ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានផ្តល់កាសជំនួយត្រចៀកដល់រូបខ្ញុំ។

**ភួង សាយ** ភេទស្រី អាយុ៩៧ឆ្នាំ មានស្រុកកំណើតក្នុងខេត្តក្រចេះ ហើយសព្វថ្ងៃរស់នៅភូមិក្តុលផ្សារ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ បើតាមការរៀបរាប់កូនស្រីរបស់យាយ កូវ សាយ បានឲ្យដឹងថា ៖ ម្តាយខ្ញុំចាប់ផ្តើមថ្លង់ស្តាប់មិនសូវឮតាំងពីមានអាយុប្រហែលជាង៤០ឆ្នាំ ដោយសារមានការទម្លាក់គ្រាប់បែកក្នុងឆ្នាំ១៩៧០ ដែលមានសំឡេងខ្លាំងពេកធ្វើឲ្យប៉ះពាល់ដល់ត្រចៀក ស្តាប់មិនឮជាង៥០ឆ្នាំកន្លងមកហើយ។ បច្ចុប្បន្នម្តាយខ្ញុំដើរមិនរួច ពីព្រោះគាត់មានអាយុ៩៧ឆ្នាំ។ ពេលម្តាយខ្ញុំបានរទេះរុញនេះមក ខ្ញុំនឹងរុញគាត់ដើរលេងនៅមុខផ្ទះ។ ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយជាខ្លាំង ដែលក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានផ្តល់កាសជំនួយត្រចៀក និងរទេះរុញដល់ម្តាយខ្ញុំ។ ម្តាយខ្ញុំគាត់ត្រេកអរខ្លាំងណាស់ដែលអាចស្តាប់ឮឡើងវិញ និងអាចជិះរទេះរុញទៅនេះទៅនោះបានខ្លះៗ។ រាល់ថ្ងៃម្តាយខ្ញុំដេកច្រើនពេកធ្វើឲ្យខ្នងគាត់មានដំបៅ។ ប៉ុន្តែពេលនេះម្តាយខ្ញុំអាចស្តាប់បាន និងអាចនិយាយជាមួយកូនចៅក្នុងគ្រួសារ និងបងប្អូនញាតិមិត្តរស់នៅក្នុងភូមិ។ កាសជំនួយត្រចៀកនេះអាចឲ្យម្តាយខ្ញុំមានទំនាក់ទំនងប្រចាំថ្ងៃជាមួយអ្នកនៅជុំវិញខ្លួនបានល្អជាងមុន។ ចំណែករទេះរុញវិញ អាចឲ្យម្តាយខ្ញុំអង្គុយបាន ហើយខ្ញុំអាចរុញគាត់ចល័តទៅកន្លែងផ្សេងៗដែលគាត់ចង់ទៅ។ រទេះរុញ និងកាសជំនួយត្រចៀកនេះជួយសម្រាលការ

លំបាករបស់កូនៗច្រើនៗ ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានផ្តល់កាសជំនួយត្រចៀកនិងរទេះរុញមកដល់ម្តាយខ្ញុំ។

ខ្ញុំឈ្មោះ **គុង សុផល** មូលហេតុដែលខ្ញុំពិការជើង ដោយសារជាន់គ្រាប់មីន ពេលខ្ញុំធ្វើដំណើរទៅរកត្រី នៅឆ្នាំ១៩៩៣។ ខ្ញុំដើរមិនប្រយ័ត្នក៏ជាន់មីនបណ្តាលឲ្យជើងខ្ញុំដាច់មួយកំណាត់លើក្បាលជង្គង់។ ចាប់តាំងពីពេលនោះមកខ្ញុំពិការជើងម្ខាង។ ចំពោះរទេះរុញនេះ គឺពិតជាមានប្រយោជន៍សម្រាប់ខ្ញុំ ព្រោះកន្លងមកខ្ញុំមិនធ្លាប់ទទួលបានរទេះរុញនេះទេ ហើយនេះគឺជាលើកដំបូង។ រទេះរុញនេះជួយខ្ញុំបានច្រើន ព្រោះកន្លងមកខ្ញុំចង់ទៅណាមកណាត្រូវប្រើកូនប្រុសប្រពន្ធជូនទៅ។ ពេលខ្លះក៏មិនបានធ្វើដូចចិត្តខ្ញុំដែរ ដោយសារកូនចៅមានការងារត្រូវធ្វើ ព្រោះប្រសិនបើចំណាយពេលនៅជាមួយខ្ញុំច្រើនពេក ធ្វើឲ្យប៉ះពាល់ដល់ជីវភាពគ្រួសារ។ រាល់ថ្ងៃខ្ញុំ គឺជាបន្ទុកសម្រាប់គ្រួសារ ព្រោះខ្ញុំពិការមិនអាចធ្វើការងារបានដូចគេ។ កន្លងមក ខ្ញុំធ្លាប់បានចូលរួមវេទិកាជនពិការនៅមជ្ឈមណ្ឌលឯកសារកោះថ្មម្តង ដែលក្រុមការងារដឹកនាំខ្ញុំនិងជនពិការផ្សេងៗទៀតទៅចូលរួម។ ខ្ញុំទទួលបានការពិនិត្យសុខភាព និងការណែនាំល្អៗពីក្រុមគ្រូពេទ្យទាក់ទងជាមួយបញ្ហាសុខភាពប្រចាំថ្ងៃ និងការថែទាំសុខភាព។ ជាចុងក្រោយខ្ញុំសូមអរគុណក្រុមការងារម្តងទៀតដែលបានយកចិត្តទុកដាក់លើជនពិការ ជាពិសេស រូបខ្ញុំផ្ទាល់។







ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មចែករទេះរុញ និងកាសជំនួយត្រចៀកជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅឃុំជាំតាម៉ៅ និងឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកោះថ្មផ្តល់រទេះរុញ និងកាសជំនួយត្រចៀក ដល់អង្គការជនពិការ

## ខេត្តត្បូងឃ្មុំ ដើម្បីជួយសម្រាលការលំបាករបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព

ឈុំ រ៉ា



*ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មផ្តល់រទេះរុញ និងកាសជំនួយត្រចៀក ជូនអង្គការជនពិការ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*នៅវេលាម៉ោង១០ព្រឹក ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបាននាំយករទេះរុញសម្រាប់ជនពិការចំនួន៥គ្រឿង និងកាសជំនួយត្រចៀកចំនួន១០០គ្រឿងទៅផ្តល់ជូនអង្គការជនពិការខេត្តត្បូងឃ្មុំ។*

*ជាកិច្ចចាប់ផ្តើម លោក អន ចាន់ថន ប្រធានអង្គការជនពិការខេត្តត្បូងឃ្មុំ មានប្រសាសន៍ថា អង្គការជនពិការខេត្តត្បូងឃ្មុំធ្វើការងារទាក់ទងនឹងការគាំទ្រមតិយ៉ាងសកម្មក្នុងការពង្រឹងសិទ្ធិរបស់ជនដែលមានពិការភាព និងបរិយាបន្នពិការភាពនៅក្នុងសហគមន៍តាំងពីឆ្នាំ២០០១។ នៅក្នុងឆ្នាំ២០១៩ លោក ចាន់ថន ត្រូវបានជ្រើសរើសឲ្យធ្វើជាប្រធានអង្គការតំណាងជនពិការភាពនៅក្នុងខេត្តត្បូងឃ្មុំ។ លោក ចាន់ថនបានប្រើប្រាស់បណ្តាញ និងទំនាក់ទំនង ដើម្បីស្វែងរកការគាំទ្រមតិសម្រាប់ធ្វើឲ្យកាន់តែប្រសើរឡើងនូវបរិយាបន្ននៃសេវាផ្សេងៗសម្រាប់ជនពិការ។ កន្លងមកអង្គការជនពិការខេត្តត្បូងឃ្មុំ*

បានចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កំណត់បណ្ណសម្គាល់ជនមានពិការភាព។ អង្គការជនពិការខេត្តត្បូងឃ្មុំ ក៏បានចូលរួមប្រមែប្រមូលកញ្ចប់ថវិកាជួយសម្រាលដល់ជីវភាពគ្រួសារជនពិការ និងជួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់បណ្ណសមធម៌ដល់ប្រជាជនក្រីក្រ ខ្វះខាត ដែលមានពិការភាព។ គិតត្រឹមចុងខែធ្នូ ឆ្នាំ២០២៣ អង្គការជនពិការខេត្តត្បូងឃ្មុំ បានចុះបញ្ជីជនពិការចំនួន១៧០០នាក់ ភាគច្រើនជនពិការដែលមានអាយុចន្លោះពី៣០ឆ្នាំឡើងទៅ។ ក្នុងនោះ ក៏មានជនពិការដែលរស់រានមានជីវិតពីរបបខ្មែរក្រហម និងសម័យសង្គ្រាមដោយសារការដាន់មីន និងជំងឺលើសឈាម និងទឹកនោមផ្អែមជាដើម។

តមក លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្មបានលើកឡើងក្នុងពិធីផ្តល់វេទិកា និងការសជំនួយត្រចៀកដល់អង្គការជនពិការខេត្តត្បូងឃ្មុំថា មជ្ឈមណ្ឌលឯកសារកោះថ្ម បានបើកដំណើរការជាសាធារណៈនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ ត្រូវនឹងខួបលើកទី៤៣ ទិវានៃការចងចាំដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុលពត (១៩៧៧-២០២០)។ មជ្ឈមណ្ឌលឯកសារកោះថ្មមានគោលបំណងធំៗដូចខាងក្រោម៖

១) បង្ហាញប្រវត្តិសាស្ត្រសង្គ្រាមនៅប្រទេសកម្ពុជាចាប់ផ្តើមពីចុងទសវត្សរ៍ឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៩០។ ជាពិសេសប្រវត្តិសាស្ត្រពីសង្គ្រាមដែលចាប់ផ្តើមឡើងនៅតំបន់កោះថ្មក្នុងស្រុកមេមត់ ខេត្តកំពង់ចាម និងស្រុកស្នួល ខេត្តក្រចេះ នៅចុងទសវត្សរ៍ឆ្នាំ១៩៦០។

២) ពង្រឹងការកសាងសន្តិភាព និងការការពារជម្លោះតាមរយៈកម្មវិធីអប់រំ ដែលនឹងផ្តល់ឱកាសសម្រាប់យុវជននៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលបានចូលរួមរៀនសូត្រ។

៣) លើកទឹកចិត្តឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចែករំលែកការចងចាំរបស់ពួកគាត់ក្នុងរបបខ្មែរក្រហមដល់យុវជនជំនាន់ក្រោយ។







ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មផ្តល់វេទិកា និងការសជំនួយត្រចៀក ជូនអង្គការជនពិការ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

៤) ប្រមូលរឿងរ៉ាវ និងបទពិសោធន៍ពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទីតាំងឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកោះថ្មក៏បានយកចិត្តទុកដាក់លើ សុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងនោះក៏មានជនពិការក្នុងរបបខ្មែរក្រហម និងសម័យសង្គ្រាម។ កន្លងមកមជ្ឈមណ្ឌលឯកសារ

កោះថ្មបានពិនិត្យសុខភាព ផ្តល់រទេះរុញ និងកាសជំនួយត្រចៀកដល់ជនពិការជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកោះថ្មធ្លាប់បានជួប និងសាកសួរអំពីរឿងរ៉ាវឆ្លងកាត់របបខ្មែរក្រហម និងបញ្ហាសុខភាពប្រចាំថ្ងៃ។

ថ្ងៃនេះ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មមានសេចក្តីសោមនស្សរីករាយក្នុងការផ្តល់រទេះរុញចំនួន៥គ្រឿង និងកាសជំនួយត្រចៀកចំនួន១០០គ្រឿងជូនអង្គការជនពិការខេត្តត្បូងឃ្មុំ ពីព្រោះវាជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ជួយដល់យាយ តា អ៊ំ ពូមីង បងប្អូនជនពិការ ដែលអាចយកវាទៅប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួន ក្រុមគ្រួសារ និងសហគមន៍។ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មសង្ឃឹមថា រទេះរុញ និងកាសជំនួយត្រចៀកអាចចូលរួមចំណែកដោះស្រាយការលំបាកបានមួយកម្រិតចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនពិការក្នុងការធ្វើដំណើរទៅមកប្រចាំថ្ងៃ និងទំនាក់ទំនងជាមួយសមាជិកក្នុងក្រុមគ្រួសារ និងបងប្អូននៅក្នុងសហគមន៍។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនពិការកាន់តែមានភាពងាយស្រួលក្នុងការនិយាយរឿងរ៉ាវ និងការចងចាំរបស់ខ្លួនកាលពីរបបខ្មែរក្រហម និងបញ្ហាសុខភាពរបស់ខ្លួននាពេលបច្ចុប្បន្នប្រាប់ដល់កូនចៅជំនាន់ក្រោយ ដែលជាប្រយោជន៍ក្នុងការទប់ស្កាត់កុំឲ្យរបបឃោរឃៅនេះកើតឡើងវិញម្តងទៀត។ ការផ្តល់រទេះរុញ និងកាសជំនួយត្រចៀកក៏ជាផ្នែកមួយនៃកិច្ចសហការជិតស្និទ្ធរវាងមជ្ឈមណ្ឌលឯកសារកោះថ្ម និងអង្គការជនពិការខេត្តត្បូងឃ្មុំក្នុងពេលបច្ចុប្បន្ន និងអនាគត។

ចុងក្រោយ លោក ចាន់ថន បានថ្លែងអំណរគុណមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានផ្តល់រទេះរុញសម្រាប់ជនពិការចំនួន៥ និងកាសជំនួយត្រចៀកចំនួន១០០ដល់អង្គការជនពិការខេត្តត្បូងឃ្មុំ សម្រាប់ចែកជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនពិការនៅក្នុងក្របខណ្ឌអង្គការជនពិការខេត្តត្បូងឃ្មុំ។ លោក ចាន់ថន បានបញ្ជាក់ថា ខ្ញុំចង់លើកទឹកចិត្តដល់ជនពិការឲ្យមានជំនឿចិត្តលើខ្លួនឯង បើទោះបីជាពួកគាត់មានពិការភាពក៏ដោយ ក៏ត្រូវបន្តក្តីសុបិន និងធ្វើការងារដែលមានប្រយោជន៍សម្រាប់ជីវិតខ្លួនបន្តទៅទៀត។

លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម និងក្រុមការងារ យករទេះរុញ និងកាសជំនួយត្រចៀកទៅជូនអង្គការជនពិការ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ផ្តល់រទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាពរស់នៅស្រុកកំពង់សៀម និង ក្រុងកំពង់ចាម ខេត្តកំពង់ចាម

**ទូច ទវណ្ណាត**




អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅស្រុកកំពង់សៀម និងក្រុងកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចន្លោះពីថ្ងៃទី៩ ដល់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ផ្តល់រទេះរុញចំនួន៥គ្រឿងជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាព ចំនួន៥នាក់ រស់នៅស្រុកកំពង់សៀម និងក្រុងកំពង់ចាម ខេត្តកំពង់ចាម។ ការប្រគល់ជូននូវរទេះរុញទាំង៥គ្រឿងនេះធ្វើឡើងតបតាមការស្នើសុំរបស់លោក គុង សុភា តំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកំពង់សៀម ដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅក្នុងសហគមន៍។

លោក គុង សុភា បានលើកឡើងថា «ការផ្តល់រទេះរុញជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅពេលនេះ គឺពិតជាមានសារសំខាន់ណាស់ ពីព្រោះគាត់អាចមានលទ្ធភាពធ្វើដំណើរទៅមកបុផ្លាស់ទីបានងាយស្រួលជាងមុន។ ការផ្តល់រទេះរុញនេះក៏បង្ហាញអំពីការយកចិត្តទុកដាក់ដល់សង្គម និងជាការលើកទឹកចិត្តដល់អ្នករស់

រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព និងមានវ័យកាន់តែចាស់ជរា។ ខ្ញុំសង្ឃឹមថា បន្ទាប់ពីទទួលបានរទេះរុញនេះរួច អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនឹងសប្បាយរីករាយ និងមានសុខភាពល្អប្រសើរឡើង ពីព្រោះគាត់អាចធ្វើដំណើរទៅចូលរួមកិច្ចការសង្គម ក៏ដូចជា ចែករំលែកអំពីបទពិសោធន៍របស់ខ្លួនក្នុងរបបខ្មែរក្រហមប្រាប់ដល់ក្មេងជំនាន់ក្រោយ»។

ខាងក្រោមនេះ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព ដែលទទួលបានរទេះរុញពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ៖

**ប៉ោង ព្រីន** ភេទប្រុស អាយុ៧៥ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលពិការជើងផ្នែកខាងស្តាំ ដោយសារត្រូវអំបែងគ្រាប់ផ្ទុះពីសម័យសង្គ្រាម។ គាត់កើតនៅភូមិដីដុះ ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ សព្វថ្ងៃគាត់រស់នៅក្នុងភូមិគគរ២ ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ គាត់មិនអាចចេញទៅប្រកបមុខរបរបានទេ គឺគាត់រស់នៅក្នុងផ្ទះដោយមានកូនៗអ្នកមើលថែ។

**គីម លីគន់** ភេទប្រុស អាយុ៦៣ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការដោយសារជំងឺលើសឈាម។ សព្វថ្ងៃគាត់រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ គាត់បានរៀបការជាមួយប្រពន្ធឈ្មោះ សាវី និងមានកូនប្រុសចំនួន៣នាក់។ គាត់មានឪពុកឈ្មោះ ស៊ិន និងម្តាយឈ្មោះ មី។ គាត់មានបងប្អូនប្រុសស្រីចំនួន៧ នាក់ ហើយគាត់គឺជាកូនទី៤ក្នុងគ្រួសារ។ កាលពីក្មេងគាត់រៀនបានត្រឹមថ្នាក់ទី៩ចាស់ នៅសាលាបឋមសិក្សាកំពង់ក្របី។

**អ៊ុង រិទ្ធ** ភេទប្រុស អាយុ៥៩ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលពិការជើងទាំងសងខាង ដោយសារជំងឺ។ សព្វថ្ងៃ គាត់រស់នៅភូមិបឹងស្នាយ សង្កាត់សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម។ គាត់មានឪពុកឈ្មោះ អ៊ុង និងម្តាយឈ្មោះ អាត។ គាត់គឺជាកូនទី៦ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៧ នាក់នៅក្នុងគ្រួសារ។ នៅក្នុងរបបខ្មែរក្រហម គាត់មានអាយុ១២ឆ្នាំ និងត្រូវបានអង្គការចាត់តាំងឲ្យធ្វើការក្នុងកងកុមារ ហើយគាត់ត្រូវធ្វើការងារដូចជា រើសអាចម៍គោ ដេញចាប និងឃ្វាលគោ។

**ធួន ស៊ីថុន** ភេទស្រី អាយុ៦៧ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលពិការជើងទាំងសងខាងដោយសារជំងឺ។ គាត់កើតនិងរស់នៅភូមិគគរ២ ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ កាលពីក្មេង គាត់បានចូលរៀននៅសាលាបឋមសិក្សាកំពង់ក្របីបានត្រឹមថ្នាក់ទី៩ សង្គមចាស់ ក៏ឈប់រៀន ដោយសារតែជីវភាពគ្រួសារមានការលំបាក។ នៅក្នុងរបបខ្មែរក្រហម ស៊ីថុន ត្រូវអង្គការចាត់តាំងឲ្យចូលធ្វើការក្នុងកងចល័តស្រុក។ គាត់ចេញទៅធ្វើការនៅតាមការដ្ឋានវែកដី លើកភ្លឺស្រែ លើកទំនប់នៅល្អាក និងលើកទំនប់ស្រុកព្រៃឈរ។

**ហួច ណៃអេន** ភេទស្រី អាយុ៦៨ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលពិការជើងទាំងសងខាងដោយសារជំងឺ។ គាត់រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ គាត់មានឪពុកឈ្មោះ ហុង ហ៊ាវ និងម្តាយឈ្មោះ គួក លាងសេង។ គាត់គឺជាកូនទី៣ ក្នុងចំណោមបងប្អូនស្រីចំនួន៣នាក់។ គាត់មានប្តីឈ្មោះ ហេង និងមានកូនប្រុសចំនួន៤ នាក់។ កាលពីក្មេងគាត់បានរៀនសូត្រនៅសាលាបឋមសិក្សាកំពង់ក្របីដល់ថ្នាក់ទី៨ សង្គមចាស់។ នៅក្នុងរបបខ្មែរក្រហម គាត់ត្រូវអង្គការបញ្ជូនទៅធ្វើការនៅកងចល័ត លើកទំនប់ត្រួយចេក ដែលស្ថិតនៅឃុំទ្រាន ស្រុកកំពង់សៀម ខេត្តកំពង់ចាម។



ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ផ្តល់រទេះរុញ និងការសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅស្រុកកំពង់សៀម និងក្រុងកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារខេត្តតាកែវ ផ្តល់រទេះរុញ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាព ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ

*ឌីម សុខគា*



ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាពនៅស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៦ ដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានផ្តល់រទេះរុញចំនួន៥គ្រឿង ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៥នាក់ ដែលមានពិការភាពរស់នៅក្នុងឃុំត្រពាំងធំខាងត្បូង និងឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ ការផ្តល់ជូនរទេះរុញ គឺក្នុងគោលបំណងជួយសម្រួលដល់ការធ្វើដំណើរ និងជីវភាពរស់នៅប្រចាំថ្ងៃរបស់អ្នកដែលមានពិការភាព។

ជាកិច្ចចាប់ផ្តើមលោក ដេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានណែនាំខ្លួន និងក្រុមការងារ ព្រមទាំងបានសួរសុខទុក្ខលោកមេភូមិ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានអញ្ជើញមកចូលរួម។ បន្ទាប់មកលោក ដេង ពង្សរ៉ាស៊ី ក៏បានសួរនាំអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមអំពីមូលហេតុដែលបណ្តាលឲ្យមានពិការភាព និងបានថ្លែងអំណរគុណដល់អាជ្ញាធរភូមិឃុំ ដែលតែងតែសហការយ៉ាងល្អជាមួយបុគ្គលិក និងអ្នកស្ម័គ្រចិត្តកម្ពុជានៃមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ព្រមទាំងអរគុណអ៊ំ

ពូមីង ដែលបានចំណាយពេលវេលាកន្លងមក ដូចជាការផ្តល់បទសម្ភាសន៍ដល់អ្នកស្ម័គ្រចិត្តកម្ពុជា។

លោក ផេង ពង្សរ៉ាស៊ី បន្ថែមថា ការចែករទេះរុញនៅក្នុងថ្ងៃនេះ គឺមិនបានគ្រប់គ្នាសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពឡើយ ព្រោះមជ្ឈមណ្ឌលឯកសារកម្ពុជា បានស្រង់ឈ្មោះតាមបញ្ជីឈ្មោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលធ្លាប់បានផ្តល់បទសម្ភាសន៍ដល់បុគ្គលិក និងអ្នកស្ម័គ្រចិត្តកម្ពុជានៃមជ្ឈមណ្ឌលឯកសារកម្ពុជានាពេលកន្លងមកតែប៉ុណ្ណោះ។ ហេតុនេះ ក្រុមការងារ បានផ្តល់រទេះរុញជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពទាំង៥នាក់ ព្រមទាំងបានបង្រៀនអំពីរបៀបប្រើប្រាស់រទេះរុញដែរ។ បន្ទាប់ពីចប់កម្មវិធី ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ ជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពដើម្បីសម្ភាសន៍ និងសាកសួរអំពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់គាត់។ ខាងក្រោមនេះ ជាចំណាប់អារម្មណ៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ៖

ខ្ញុំឈ្មោះ **ជុំ អ៊ូច** ភេទប្រុស អាយុ៦៣ឆ្នាំ រស់នៅភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានអារម្មណ៍សប្បាយរីករាយយ៉ាងខ្លាំង ពេលដែលបានទទួលរទេះរុញពីមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ព្រោះរទេះរុញនេះអាចជួយខ្ញុំឲ្យធ្វើដំណើរទៅណាមកណាបានដោយខ្លួនឯង ដោយមិនចាំបាច់ពឹងពាក់អ្នកដទៃ។

ខ្ញុំឈ្មោះ **ចាន់ រោម** ភេទប្រុស អាយុ៦៣ឆ្នាំ រស់នៅភូមិត្រពាំងថ្ម ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ បន្ទាប់ពីទទួលបានរទេះរុញនេះ ខ្ញុំមានអារម្មណ៍សប្បាយរីករាយណាស់ ព្រោះខ្ញុំអាចធ្វើដំណើរបានដោយខ្លួនឯង។ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមការដែលបានចែករទេះរុញនេះដល់ខ្ញុំ។ ខ្ញុំសូមឲ្យក្រុមការងារធ្វើដំណើរត្រឡប់ទៅវិញដោយសុវត្ថិភាព។

ខ្ញុំឈ្មោះ **ឯក គ្រិល** ភេទប្រុស អាយុ៥៨ឆ្នាំ រស់នៅភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង



*លោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋានក្នុងអំឡុងពេលចុះចែករទេះរុញ និងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅឃុំត្រពាំងធំខាងត្បូង និងឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានការត្រេកអរខ្លាំងណាស់នៅពេលដែលទទួលបានរទេះរុញពីមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រោះវាជួយកាត់បន្ថយនូវការលំបាកដល់ខ្ញុំក្នុងការធ្វើដំណើរ។ ពីមុន គឺខ្ញុំត្រូវដើរដោយកាន់ឈើច្រត់ និងមិនងាយស្រួលឡើយ។ រទេះរុញនេះ គឺសម្រួលដល់ខ្ញុំនិងគ្រួសារបានច្រើនណាស់។ ខ្ញុំកាត់ជើងនៅឆ្នាំ២០០៦ ប៉ុន្តែខ្ញុំកើតមានជំងឺតាំងពីឆ្នាំ១៩៩៣ មកម្ល៉េះ។ ខ្ញុំធ្លាប់សុំរទេះរុញពីកន្លែងផ្សេងៗច្រើនដងដែរ ប៉ុន្តែពុំមាននរណាផ្តល់ឲ្យខ្ញុំសោះ។ នៅពេលនេះ ខ្ញុំបានទទួលហើយ គឺបានទទួលពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ ជាចុងក្រោយ ខ្ញុំគ្មានអ្វីក្រៅតែពីបួងសួងដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ព្រមទាំងអ្នកដែលថែរក្សាម្ចាស់ទឹក ម្ចាស់ដី ជួយឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមការងារទាំងអស់ឲ្យរីកចម្រើន និងជួបប្រទះតែសេចក្តីសុខទៅមុខបន្តទៀត។

ខ្ញុំឈ្មោះ **សែន ប៊ុន** ភេទប្រុស អាយុ៦៨ឆ្នាំ រស់នៅភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំពិតជាសប្បាយចិត្តជាខ្លាំងនៅពេលដែលខ្ញុំទទួលបានរទេះរុញនេះ។ ខ្ញុំពុំដែលបានទទួល រទេះរុញនេះពីមុនមកទេ។ ក្រៅពីពិការភាពដោយសារជាន់មីន ខ្ញុំនៅមានជំងឺផ្សេងទៀត ដូចជា សួត លើសឈាម បេះដូង និងខ្វះជាតិស្ករ។

ខ្ញុំឈ្មោះ **ឆន់ និន** ភេទស្រី អាយុ៨៣ឆ្នាំ រស់នៅភូមិត្រពាំងតាសោម ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានអារម្មណ៍សប្បាយចិត្ត និងសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលផ្តល់រទេះរុញដល់ខ្ញុំ។ រទេះរុញនេះអាចជួយសម្រួលការលំបាករបស់ខ្ញុំ ហើយខ្ញុំអាចជិះទៅធ្វើបុណ្យនៅវត្តជិតៗនេះបាន។



ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចុះសម្ភាសន៍ និងចែករទេះរុញ ព្រមទាំងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព នៅឃុំត្រពាំងធំខាងត្បូង និងឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ផ្ដល់រទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

## ដែលមានពិការ រស់នៅស្រុកពារាំង និងស្រុកកំពង់ត្របែក ខេត្តព្រៃវែង

គា រស្មី



ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ចែករទេះរុញ និងការសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅស្រុកពារាំង និងស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១០ និងថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ផ្ដល់រទេះរុញចំនួន៤គ្រឿងជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព រស់នៅក្នុងខេត្តព្រៃវែង ក្នុងនោះរទេះរុញចំនួន២គ្រឿង ត្រូវបានផ្ដល់ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពផ្នែករាងកាយ កំពុងរស់នៅភូមិព្រៃកន្សា និង ភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង និង២គ្រឿងទៀត ត្រូវបានផ្ដល់ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលកំពុងរស់នៅភូមិព្រៃស្នៀត ឃុំព្រៃស្នៀត ស្រុកពារាំង ខេត្តព្រៃវែង។

ការផ្ដល់ជូនរទេះរុញនេះគឺតាមរយៈគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបប

ខ្មែរក្រហម» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងគោលបំណងជួយប្រជាជនកម្ពុជាដែលជួបប្រទះការលំបាកក្រោយរបបខ្មែរក្រហម ហើយដែលយើងគ្មានអ្វីអាចតបស្នងបាន។ ការផ្តល់ជូនរទេះរុញនេះគឺជាជំហានដ៏ចាំបាច់ឆ្ពោះទៅរកការគាំទ្រ និងការជួយជ្រោមជ្រែងពិតប្រាកដមួយដល់មនុស្សចាស់ និងជនពិការដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ការផ្តល់រទេះរុញជូនដល់ជនពិការនៅពេលនេះ គឺជាឱកាសផ្តល់ឲ្យគាត់មានភាពងាយស្រួលជាងមុនក្នុងការធ្វើដំណើរទៅមកដោយខ្លួនឯង ដោយមិនរំខានដល់សមាជិកក្រុមគ្រួសារគាត់។ រទេះរុញនេះពិតជាបានជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់គាត់បានច្រើន ព្រោះគាត់អាចនឹងមានពេលវេលាច្រើនក្នុងការប្រកបរបររកស៊ីចិញ្ចឹមគ្រួសារ។ ក្រុមគ្រួសាររបស់គាត់ក៏មានការត្រេកអរ និងពេញចិត្តចំពោះការផ្តល់រទេះរុញពីមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងដែរ។

ក្នុងឱកាសនោះ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ឆ្លៀតឱកាសដើម្បីសំណេះសំណាល សួរសុខទុក្ខ និងសាកសួររឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពទាំងបួននាក់បន្ថែមពីលើសាច់រឿងជីវិតរបស់គាត់ដែលធ្លាប់បានផ្តល់បទសម្ភាសន៍ទៅកាន់អ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកន្លងមក។

បន្ទាប់ពីទទួលរទេះរុញរួច អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពទាំង៤នាក់ សម្តែងអារម្មណ៍រំភើបរីករាយ និងលើកឡើងថា រទេះរុញទាំងអស់នេះ គឺជាមធ្យោបាយធ្វើដំណើរប្រចាំថ្ងៃដ៏សំខាន់បំផុតសម្រាប់គាត់ ហើយក៏ជួយពន្យារអាយុជីវិតគាត់ឲ្យបានរស់នៅយូរតទៅមុខទៀតដើម្បីបន្តចែករំលែករឿងរ៉ាវជីវិតឆ្លងកាត់របបខ្មែរក្រហមទៅកាន់ក្មេងៗជំនាន់ក្រោយ។







ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ចុះសម្ភាសន៍ និងចែករទេះរុញ ព្រមទាំងកាសជំនួយត្រចៀក ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅស្រុកពារាំង និងស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកោះថ្ម ផ្តល់រទេះរុញសម្រាប់ជនពិការ តាមការស្នើសុំរបស់រដ្ឋបាលឃុំទន្លូង

ឈុំ រ៉ា



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ផ្តល់រទេះរុញ និងកាសជំនួយត្រចៀក ជូនរដ្ឋបាលឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានផ្តល់ជូនរទេះរុញចំនួន៣គ្រឿងដល់អាជ្ញាធរឃុំទន្លូង ដែលបានស្នើសុំតាមលិខិតយោងរបស់លោក ប៊ឹង ប៊ុនថន មេឃុំទន្លូង ចុះលេខ២៤៤៨/២៤ទល ក្នុងថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤ មកកាន់មជ្ឈមណ្ឌលឯកសារកោះថ្ម សម្រាប់ផ្តល់ជូនដល់ជនពិការភាព ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងប្រជាពលរដ្ឋដែលមានពិការភាពពីកំណើត។

តាមប្រសាសន៍លោក ប៊ឹង ប៊ុនថន មេឃុំទន្លូង បានលើកឡើងថា ជនពិការភាពត្រូវការសិទ្ធិសេរីភាពក្នុងការធ្វើដំណើរ និងសំឡេងគាំទ្រក្នុងសហគមន៍ឬសង្គមទាំងមូល ដូចប្រជាជនដែលមានកាយសម្បទាគ្រប់គ្រាន់ដែរ។ យើងទាំងអស់គ្នាត្រូវយកចិត្តទុកដាក់ គាំទ្រចំពោះជនពិការ ដែលស្តែងឲ្យឃើញពីចិត្តព្រួយបារម្ភ លើកទឹកចិត្តដើម្បីឲ្យជនពិការមានក្តីសង្ឃឹមបន្ត។

ជាកិច្ចបន្ទាប់លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម បានលើកឡើងថា កន្លងមកក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានផ្តល់ជូនរទេះរុញចំនួន៨គ្រឿង និងកាសជំនួយត្រចៀកចំនួន១០៩គ្រឿង សម្រាប់ជនពិការភាពកាលពីសម័យ




សង្គ្រាមក្រោយរបបខ្មែរក្រហម និងជនពិការពីកំណើតមួយចំនួននៅក្នុងឃុំទន្លូង ឃុំជាំក្រវៀន ឃុំជាំតាម៉ៅ និងអង្គការជនពិការខេត្តត្បូងឃ្មុំ។ ការផ្តល់ជូនរទេះរុញនេះគឺជាផ្នែកមួយជួយសម្រួលដល់ជីវភាពក្រុមគ្រួសារ សិទ្ធិសេរីភាពក្នុងការដើរហើរ និងការបញ្ចេញមតិរបស់បុគ្គលម្នាក់ៗ ទោះជាជនពិការភាពក៏ដោយ។ ចំណែកជនពិការដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺជាមនុស្សសំខាន់ក្នុងការចែករំលែករឿងរ៉ាវដែលគាត់បានចងចាំមិនភ្លេចពីរបបខ្មែរក្រហម និងបញ្ហាសុខភាពនៅពេលបច្ចុប្បន្ននេះ ដល់យុវជនជំនាន់ក្រោយដែលជាកូនចៅរបស់គាត់ផ្ទាល់។

លោក ឡុង ដានី និង ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម សង្ឃឹមថាពេលទទួលបានរទេះរុញនេះ ជនដែលមានពិការភាពនឹងមានក្តីសង្ឃឹមសប្បាយរីករាយ អាចចូលរួមជួបជុំក្នុងសហគមន៍ មានសិទ្ធិក្នុងការបញ្ចេញមតិយោបល់ផ្សេងៗក្នុងការអភិវឌ្ឍន៍សង្គម និងជួយទប់ស្កាត់កុំឲ្យមានអំពើប្រល័យពូជសាសន៍កើតឡើងសារជាថ្មី។



លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម ពិភាក្សាមួយលោក ប៊ឹង ប៊ុនថន មេឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាចុងក្រោយ លោកប៊ឹងប៊ុនថនថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានផ្តល់រទេះរុញចំនួន៣គ្រឿង តាមការស្នើសុំរបស់រដ្ឋបាលឃុំ។ លោក ប៊ឹង ប៊ុនថន លើកឡើងថា «ខ្ញុំពិតជារីករាយ ដែលមជ្ឈមណ្ឌលឯកសារកោះថ្ម បានយកចិត្តទុកដាក់លើជនពិការ។ ក្នុងនាមខ្ញុំជាមេឃុំទន្លូង ខ្ញុំពិតជារីករាយក្នុងការសហការជាមួយមជ្ឈមណ្ឌលឯកសារកោះថ្ម»។

# អ្នកតម្បាញជនជាតិចាមមកពីស្រុកកោះសូទិន

## ចូលរួមដំណើរទស្សនកិច្ចសិក្សា រៀបចំដោយ «គម្រោងសូត្រចាម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា

*មីន សាណាស់*



ស្ត្រីតម្បាញជនជាតិចាមមកពីស្រុកកោះសូទិន ខេត្តកំពង់ចាម ជួបសម្តែងការគួរសមជាមួយលោកជំទាវ Ülkü Kocaefe ឯកអគ្គរដ្ឋទូតតួកគី ប្រចាំនៅប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមការងារគម្រោងសូត្រចាម ឬពណ៌នៃការចងចាំ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំដំណើរទស្សនកិច្ចសិក្សាដល់តំណាងស្ត្រីជនជាតិចាមចំនួន៣នាក់ដែលកំពុងធ្វើការងារតម្បាញសូត្រ នៅសហគមន៍ក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម។ ដំណើរទស្សនកិច្ចសិក្សានេះមានរយៈពេលពីរថ្ងៃ គឺចាប់ពីថ្ងៃទី១៦ ដល់ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ នៅ ទីក្រុងភ្នំពេញ និងខេត្តតាកែវ។



នៅ ទីក្រុងភ្នំពេញតំណាងស្ត្រីតម្បាញជនជាតិចាមបានជួបសម្តែងការគួរសមជាមួយលោកជំទាវ ÜLKÜ KOCAEFE ឯកអគ្គរដ្ឋទូតតួកគី ប្រចាំនៅ



ប្រទេសកម្ពុជា ដើម្បីរាយការណ៍អំពីដំណើរការរបស់គម្រោងសូត្រចាម និងពិភាក្សាអំពីយុទ្ធសាស្ត្រផែនការរយៈពេលវែងនាពេលអនាគត។ ចំពោះគម្រោងសូត្រចាម ពិតជាមានសារសំខាន់ខ្លាំងណាស់ក្នុងការថែរក្សាប្រពៃណីវប្បធម៌ជនជាតិចាម ដែលនៅសេសសល់ពីរបបខ្មែរក្រហម និងទាមទារឲ្យមានការចូលរួមពីយុវជនជំនាន់ក្រោយ ព្រមទាំងធ្វើឲ្យមានការប្រកួតប្រជែង។

លោកជំទាវ ÜLKÜ KOCAEFE ឯកអគ្គរដ្ឋទូត បានលើកទឹកចិត្តដល់អ្នកតម្បាញគិតគូរអំពីដំណើរការទាំងមូល ដូចជា ការដាំដើមមន ចិញ្ចឹមដង្កូវនាង ការផលិតសូត្រ និងសរសៃសូត្រ ការជ្រលក់ពណ៌ សង្វាក់ការងារតម្បាញ រហូតដល់ផលិតផលសម្រេច និងការផ្តល់ផលប្រយោជន៍ ព្រមទាំងផ្ទេរជំនាញ ដល់យុវជនជំនាន់ក្រោយ និងការទាក់ទាញភ្ញៀវទេសចរណ៍ខាងក្រៅតំបន់ឲ្យមកទស្សនាសហគមន៍តម្បាញរបស់ជនជាតិចាមដោយផ្ទាល់។ លោកជំទាវ ÜLKÜ KOCAEFE បន្តថា ដើម្បីធ្វើឲ្យមានការទាក់ទាញដល់យុវនារីវ័យក្មេងឲ្យមានចំណាប់អារម្មណ៍មកលើគម្រោងសូត្រចាម





ស្ត្រីតម្បាញជនជាតិចាមមកពីស្រុកកោះសូទិន ទស្សនកិច្ចព្រះរាជបណ្ណាល័យ ហ្វូងម៉ែ និងមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចំណុចសំខាន់ក្នុងការងារនេះ គឺបញ្ចូលការរចនាម៉ូតបែបសិល្បៈទាន់សម័យឲ្យស្របតាមសង្គមសម័យទំនើបនេះ។ យើងក៏ត្រូវផ្ដល់ការលើកទឹកចិត្តមួយចំនួនដល់យុវនារី ដើម្បីទាក់ទាញអ្នកទាំងនោះឲ្យមកធ្វើការងារត្បាញជាមួយស្ត្រីវ័យចំណាស់ដែលមានជំនាញខាងត្បាញ។ កិច្ចប្រជុំរវាងតំណាងស្ត្រីតម្បាញជនជាតិចាម និងលោកជំទាវ ÜLKÜ KOCAEFE ត្រូវបានបញ្ចប់ដោយការពិភាក្សាយ៉ាងរស់រវើក និងប្រកបដោយក្ដីសង្ឃឹម។

បន្ទាប់ពីកិច្ចប្រជុំនៅទីក្រុងភ្នំពេញរួច តំណាងស្ត្រីតម្បាញជនជាតិចាម ទាំង៣នាក់បានធ្វើដំណើរទៅទស្សនកិច្ចមជ្ឈមណ្ឌលបណ្ដុះបណ្ដាលជំនាញតម្បាញសូត្រខេត្តតាកែវ ដែលមានមូលដ្ឋាននៅក្នុងស្រុកសំរោង ខេត្តតាកែវ។ មជ្ឈមណ្ឌលនេះទទួលបានការឧបត្ថម្ភដោយធនាគារ មេយប៊ែង។ គោលបំណងនៃដំណើរទស្សនកិច្ចនេះគឺដើម្បីពង្រីកការយល់ដឹងបន្ថែមរបស់តំណាងស្ត្រីតម្បាញជនជាតិចាម ទាក់ទងនឹងសិប្បកម្មតម្បាញ និងធ្វើឲ្យផលិតផលរបស់ខ្លួនកាន់តែប្លែកនិងលេចធ្លោ។

តំណាងស្ត្រីជនជាតិចាម ចាប់អារម្មណ៍លើគម្រោងបណ្ដុះបណ្ដាលជំនាញតម្បាញសូត្រនេះ ដោយសារគម្រោងនេះផ្ដល់ឱកាសដល់សហគមន៍ស្រុកសំរោង ជាពិសេសស្ត្រីនិងក្មេងស្រី ដែលក្នុងនោះបានផ្ដល់ចំណេះជំនាញនិងធនធានដល់សហគមន៍។ បន្ទាប់មក តំណាងស្ត្រីជនជាតិចាម ទាំងនោះបានចែករំលែកជំនាញតម្បាញរបស់ខ្លួនជាមួយអ្នកគ្រប់គ្រងនៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលជំនាញតម្បាញសូត្រខេត្តតាកែវ។

តំណាងស្ត្រីជនជាតិចាម ទាំងនេះ កាន់តែមានការជឿជាក់និងថាមពល បន្ទាប់ពីដំណើរទស្សនកិច្ចនេះ និងមានចក្ខុវិស័យវែងឆ្ងាយនៅពេលអនាគតទាក់ទងនឹងការងារត្បាញសូត្រ។

គម្រោងសូត្រចាម ឬ ព៌ណនៃការចងចាំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចាប់ផ្ដើមតាំងពីឆ្នាំ២០២០។ គម្រោងនេះត្រូវបានផ្ដួចផ្ដើមឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងមានការគាំទ្រថវិកាពីទីភ្នាក់ងារសហប្រតិបត្តិការ និងសម្របសម្រួលតួកគី (TIKA) តាមរយៈស្ថានទូតតួកគីប្រចាំនៅកម្ពុជា។ គម្រោងសូត្រចាម ឬ ពណ៌នៃការចងចាំ ផ្ដោតសំខាន់លើការស្រាវជ្រាវ ការអប់រំ និងសិប្បកម្មតម្បាញ។ រហូតមកដល់ពេលនេះ គម្រោងសម្រេចបានសូត្រចំនួន១៧០សំពត់ និងក្រមាចំនួន១៧០។ គម្រោងនេះត្រូវបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ នៅខែកក្កដា ឆ្នាំ២០២៤។




មជ្ឈមណ្ឌលបណ្ដុះបណ្ដាលជំនាញតម្បាញសូត្រខេត្តតាកែវ ដែលមានមូលដ្ឋាននៅក្នុងស្រុកសំរោង ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អន ពន ៖ ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅឃុំឃាំង និងធ្វើការធ្ងន់នៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ដោយចោទថា ខ្ញុំគឺជាកងទ័ពបូព៌ាក្បត់

**ភា រស្មី**

ខ្ញុំឈ្មោះ អន ពន ភេទប្រុស កើតនៅក្នុងឆ្នាំ១៩៥២ ហើយបច្ចុប្បន្នខ្ញុំរស់នៅភូមិព្រៃកន្សា ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូនចំនួន៧ នាក់ ក្នុងចំណោមនោះគឺស្លាប់ម្នាក់ៗ កាលនៅកុមារ ខ្ញុំចូលរៀនបានមួយរយៈ ហើយក្រោយមកក៏បានឈប់រៀនត្រឹមថ្នាក់ទី៨ពីសង្គមចាស់ ដោយសារមានការទម្លាក់គ្រាប់បែកយ៉ាងខ្លាំងពីសំណាក់រដ្ឋការ លន់ នល់ នៅឆ្នាំ១៩៧០។ នៅពេលនោះ ផ្ទះអ្នកភូមិត្រូវបានឆេះអស់មួយចំនួន ចំណែកខ្ញុំត្រូវអំបែងគ្រាប់ដែលខ្ទាតមកចំជើងខាងឆ្វេងរបស់ខ្ញុំបណ្តាលឲ្យរងរបួស។



អន ពន សព្វថ្ងៃរស់នៅភូមិព្រៃកន្សា ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឆ្នាំ១៩៧៣ បន្ទាប់ពីបានស្តាប់ឮសេចក្តីប្រកាសរបស់សម្តេចព្រះ នរោត្តម សីហនុ ពីទីក្រុងប៉េកាំង ប្រទេសចិនឲ្យកូនចៅរត់ចូលព្រៃម៉ាគីដើម្បីតស៊ូប្រឆាំងនឹងរបប លន់ នល់ ខ្ញុំក៏បានស្ម័គ្រចិត្តចូលបម្រើកងទ័ពរំដោះតាមការអំពាវនាវរបស់ព្រះអង្គ។ ក្រុមរបស់ខ្ញុំមានគ្នាចំនួន៤នាក់ ត្រូវបានស្នើសុំឲ្យធ្វើដំណើរទៅខេត្តកំពង់ចាម ដើម្បីហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រធ្វើសង្គ្រាមជាមួយគ្រូជនជាតិវៀតណាម (វៀតណាមខាងជើង)។ រយៈពេល៣ខែក្រោយមក ខ្ញុំក៏ត្រឡប់មកប្រចាំការនៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង រហូតដល់កងទ័ពខ្មែរក្រហមទទួលជ័យជម្នះលើរបប លន់ នល់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

នៅឆ្នាំ១៩៧៦ ខ្ញុំ និងក្រុមរបស់ខ្ញុំ ត្រូវបានមេបញ្ជាការបញ្ជូនឲ្យទៅវាយតទល់ជាមួយកងទ័ពវៀតណាម នៅសមរភូមិក្នុងខេត្តស្វាយរៀង។ ក្រុមរបស់ខ្ញុំបានស្លាប់នៅលើសមរភូមិស្ទើរទាំងអស់ គឺនៅរស់តែខ្ញុំម្នាក់ប៉ុណ្ណោះ។ កាលនោះខ្ញុំត្រូវរបួសនៅត្រង់ចង្កេះដែរ។ ខ្ញុំនៅប្រយុទ្ធលើសមរភូមិក្នុងខេត្តស្វាយរៀង រហូតដល់ឆ្នាំ១៩៧៨ ស្រាប់តែកងទ័ពនៅក្នុងតំបន់ និងភូមិភាគបូព៌ា ទាំងអស់ត្រូវបានថ្នាក់ដឹកនាំមជ្ឈិមចោទថា បានចូលដៃចូល

ជើងជាមួយវៀតណាមៗ កងទ័ពភូមិភាគបូព៌ាទាំងអស់ត្រូវបានដកហូតកាំភ្លើង និងត្រូវប្រគល់ខ្លួនឲ្យអង្គការ។ កាលនោះមានរថយន្តប្រមាណ៦០គ្រឿង បានមកដឹកកងទ័ពភូមិភាគបូព៌ាប្រមាណជាង២,០០០នាក់ យកទៅឃុំឃាំង នៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។ ក្នុងនោះក៏មានដឹក ចាន់ចក្រី និងមេបញ្ជាការកងពលភូមិភាគបូព៌ាផ្សេងទៀតចេញទៅស្របពេលជាមួយគ្នាដែរ ប៉ុន្តែមេដឹកនាំធំៗទាំងនោះមិនបានបញ្ជូនទៅដល់ព្រលានយន្តហោះទេ។ ក្រោយមកទើបខ្ញុំដឹងថា មេបញ្ជាការកងទ័ពធំៗមួយចំនួនត្រូវបានដឹកទៅដាក់នៅវ៉ារទេះភ្លើងខ្នាចរមាស និងបានសម្លាប់នៅទីនោះតែម្តង។ ចំណែកឯកូនទាហានផ្សេងទៀត គឺត្រូវបញ្ជូនទៅតាមគោលដៅដែលបានកំណត់។

ទម្រាំតែបានទៅដល់គោលដៅ ត្រូវចំណាយពេលវេលាប្រហែលជា៣ថ្ងៃ ព្រោះអ្នកបើករថយន្តខស្វាហ៍ឈប់ដើម្បីឲ្យម៉ាស៊ីនឡានត្រជាក់។ ក្នុងរយៈពេល៣ថ្ងៃនោះ ខ្ញុំមិនបានទទួលរបបអាហារហូបចុកពីអ្នកគ្រប់គ្រងខ្មែរក្រហមឡើយ។ រហូតទៅដល់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ទើបខ្មែរក្រហមយកបាយមកចែកឲ្យខ្ញុំហូប និងបញ្ជូនខ្ញុំទៅដាក់ក្នុងគុក។ គុកនោះមានសណ្ឋានជាផ្ទះគំរូ ដោយមានជញ្ជាំង និងដំបូលប្រក់ដែក។ រយៈពេលមួយថ្ងៃក្រោយមក កងទ័ពភូមិភាគនិរតីចំនួន៨នាក់ បានមកសួរអំពីជីវប្រវត្តិរបស់ខ្ញុំ ។ ពេលនោះ ខ្ញុំរកគិតធ្វើយ៉ាងណាឲ្យរួចផុតពីសេចក្តីស្លាប់ ព្រោះអង្គការត្រៀមយកកងទ័ពភូមិភាគបូព៌ាទៅសម្លាប់ហើយ។ ខ្ញុំក៏បានគិតឃើញចំណុចមួយ គឺខ្ញុំមិនឆ្លើយថាខ្ញុំគឺជាអ្នកមកពីភូមិភាគបូព៌ាឡើយ។ ខ្ញុំបានប្រាប់កងទ័ពទាំង៨មកពីភូមិភាគនិរតីនោះថា ខ្ញុំក៏មកពីខាងនិរតីដែរ ដោយខ្ញុំបាននិយាយសំឡេងរដឹនឲ្យដូចទៅនឹងសំឡេងកងទ័ពភូមិភាគនិរតី។

រយៈពេលដំបូង ខ្មែរក្រហមដែលគ្រប់គ្រងនៅទីនោះមិនទាន់ទុកចិត្តខ្ញុំទាំងស្រុងឡើយ គឺចាំឃ្លាំមើលពីសកម្មភាពខ្ញុំជារៀងរាល់ថ្ងៃ។ ចំណែកខ្ញុំ តែងតែខិតខំប្រឹងបំពេញការងារឲ្យបានល្អជាប់ជាប្រចាំ។ បន្ទាប់ពីស្រង់ប្រវត្តិរូបខ្ញុំរួច អ្នកគ្រប់គ្រងខ្មែរក្រហមបានបញ្ជូនខ្ញុំទៅដាក់នៅកន្លែងមួយដាច់ដោយឡែក ជាមួយកងទ័ពនិរតី និងចាប់ផ្តើមឲ្យខ្ញុំទៅធ្វើការនៅព្រលានយន្តហោះដែលមានជំនាញការចិន ចាំបញ្ជាឲ្យខ្ញុំធ្វើ។ កាលនោះខ្ញុំត្រូវបានជំនាញការចិនបញ្ជាឲ្យរុញរទេះដឹកថ្ម យកទៅចាក់ក្រាលនៅព្រលានយន្តហោះ។ មានពេលមួយ មេការខ្មែរក្រហមបានបញ្ជូនខ្ញុំ និងសមាជិកប្រមាណ៨នាក់ផ្សេងទៀតឲ្យទៅកាត់ដើមផ្តៅ និងរពាក់នៅក្នុងព្រៃយកមកក្រងធ្វើបង្គីដើម្បីសែងថ្ម។ ពេលចូលទៅក្នុងព្រៃ ស្រាប់តែខ្ញុំឃើញសាកសពមនុស្សស្លាប់ជាច្រើន ដោយមានធំក្លិនស្អុយអសោច និងមានសត្វរុយរោមសាកសពទាំងនោះ។ ខ្ញុំនិងសមាជិកនៅក្នុងក្រុមនិយាយគ្នាថា សាកសពទាំងនេះគឺជាប្រជាជន ហើយក៏មិនហ៊ាននិយាយអ្វីទៀតដែរ ព្រោះនៅក្នុងចំណោមក្រុមរបស់ខ្ញុំ គ្មាននរណាម្នាក់ទុកចិត្តលើនរណាឡើយ។ ចំណែកព្រៃដែលខ្មែរក្រហមយកមនុស្សទៅសម្លាប់នោះ គឺមានចម្ងាយប្រមាណតែ៥០០ម៉ែត្រប៉ុណ្ណោះពីកន្លែងដែលខ្ញុំស្នាក់នៅ។

ពេលត្រឡប់មកផ្ទះគំរូវិញ ខ្ញុំនិងក្រុមរបស់ខ្ញុំមិនហ៊ាននិយាយអំពីហេតុការណ៍ដែលយើងបានជួបប្រទះនៅក្នុងព្រៃឡើយ គឺយើងនាំគ្នាចូលដេកយ៉ាងស្ងៀមស្ងាត់។ លុះព្រឹកឡើង ស្រាប់តែខ្ញុំឃើញសមាជិកក្រុមខ្លះបានដេកស្លាប់ដោយសារតែឆក់ខ្សែភ្លើង។ ខ្ញុំគិតថា នៅក្នុងយប់នោះ គឺមានអ្នកលួចទម្លាក់ខ្សែភ្លើងចុះមកឲ្យប៉ះនឹងដំបូលដែកដែលខ្ញុំ និងក្រុមកំពុងស្នាក់នៅ ដើម្បីឲ្យខ្ញុំនិងអ្នកទាំងនោះឆក់ស្លាប់។ ពេលខ្ញុំឃើញហេតុការណ៍ដូច្នេះ ខ្ញុំឈប់ដេកនៅលើក្តារក្រាលតទៅទៀត ដោយខ្ញុំប្តូរមកចងអង្រឹងដេកវិញ។ រយៈពេល៣ខែក្រោយមក អ្នកគ្រប់គ្រងនៅព្រលានយន្តហោះកំពង់ឆ្នាំង បានបញ្ជូនខ្ញុំឲ្យទៅធ្វើត្រីនៅកោះស្រឡៃ ស្ថិតនៅខាង

ត្បូងភ្នំកង្រី។ ខ្ញុំធ្វើត្រីបានរយៈពេលត្រឹមតែ៣ថ្ងៃប៉ុណ្ណោះ ស្រាប់តែមានអ្នកនៅក្នុងក្រុមមករាយការណ៍ថា មានការបំផ្ទុះឃ្លាំងគ្រាប់នៅអ្នកលឿង ហើយទីក្រុងភ្នំពេញត្រូវបានរំដោះហើយ។ នៅវេលាម៉ោង១២យប់ មេការខ្មែរក្រហមបានបញ្ជូនខ្ញុំ និងអ្នកផ្សេងទៀត តាមកាណូតត្រឡប់មកព្រលានយន្តហោះខេត្តកំពង់ឆ្នាំងវិញ។ ខ្ញុំគិតថា ខ្ញុំនឹងអស់ជីវិតហើយ ព្រោះអ្នកបើកកាណូតនឹងពន្លិចកាណូតនៅកណ្តាលទន្លេឲ្យខ្ញុំលង់ស្លាប់តែម្តង ប៉ុន្តែជាសំណាងល្អ ខ្ញុំបានទៅដល់ព្រលានយន្តហោះកំពង់ឆ្នាំងដោយសុវត្ថិភាព។ ពេលនោះ មានឧទ្ធម្ភាគចក្រជាច្រើនគ្រឿងបានមកដឹកអ្នកដែលចង់ធ្វើដំណើរចេញទៅក្រៅប្រទេសនៅព្រលានយន្តហោះកំពង់ឆ្នាំង។ កាលនោះ ខ្ញុំបានឡើងជិះឧទ្ធម្ភាគចក្រជាមួយអ្នកផ្សេងទៀតដែរ ប៉ុន្តែខ្ញុំសម្រេចចិត្តចុះមកវិញ ព្រោះខ្ញុំនឹកឃើញឪពុកម្តាយដែលរស់នៅស្រុកកំណើត និងមិនដាច់ចិត្តទៅចោលគាត់។

ខ្ញុំបានធ្វើដំណើររយៈពេល ១យប់១ថ្ងៃ ត្រឡប់មកភ្នំពេញ។ បន្ទាប់មក ខ្ញុំបានសុំរថយន្តកងទ័ពវៀតណាមជិះត្រឡប់មកស្រុកកំណើតវិញ។ កងទ័ពវៀតណាមបានជូនខ្ញុំ និងមិត្ត កុល ដល់អ្នកលឿង បន្ទាប់មកខ្ញុំក៏ចុះដើរបន្តរហូតដល់ស្រុកកំណើត។ ពេលមកដល់ផ្ទះ ខ្ញុំបានស្រែកហៅម្តាយខ្ញុំ ប៉ុន្តែគាត់មិនឆ្លើយ ថែមទាំងរត់ពួនខ្ញុំទៀតផង។ ខ្ញុំបានហៅម្តាយខ្ញុំជាច្រើនដង រហូតគាត់ចំណាំសំឡេងខ្ញុំបាន ហើយម្តាយខ្ញុំនិងបងប្អូនខ្ញុំក៏នាំគ្នាយំឱបគ្នាពេញផ្ទះ ព្រោះគិតថា ខ្ញុំបានស្លាប់ហើយ។ ក្រោយរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ មិត្ត កុល បានមកបបួលខ្ញុំឲ្យចូលធ្វើទាហានក្នុងរបបរដ្ឋកម្ពុជាម្តងទៀត ប៉ុន្តែខ្ញុំបានប្រាប់គាត់វិញថា ខ្ញុំលែងចង់ធ្វើកងទ័ពទៀតហើយ។ ខ្ញុំមានការស្តាយក្រោយជាខ្លាំង ដែលខ្ញុំបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម។ ខ្ញុំខំជួយប្រយុទ្ធខ្មែរក្រហម ហើយចុងក្រោយខ្មែរក្រហមបានចាប់ខ្ញុំដាក់គុក ប្រើខ្ញុំឲ្យធ្វើការងារធ្ងន់ធ្ងរ ថែមទាំងប្រុងយកខ្ញុំទៅសម្លាប់ចោលទៀត។

រហូតមកដល់សព្វថ្ងៃ ជើងរបស់ខ្ញុំដែលធ្លាប់រងរបួសក៏ធ្វើទុក្ខខ្លះដែរ។ កាលពីឆ្នាំ២០២២ ខ្ញុំបានទៅប្រទេសវៀតណាមដើម្បីឲ្យគ្រូពេទ្យព្យាបាលដែរ ប៉ុន្តែនៅតែមិនបានធូរ។ ខ្ញុំត្រឡប់មកផ្ទះវិញ និងបានទៅក្រុងភ្នំពេញដើម្បីឲ្យគ្រូពេទ្យពិនិត្យម្តងទៀត។ គ្រូពេទ្យបានប្រាប់ខ្ញុំថា ទាល់តែកាត់ជើងខ្ញុំចោល ទើបព្យាបាលជា បើមិនដូច្នេះទេគឺមិនជាឡើយ។ មួយវិញទៀត ប្រសិនបើខ្ញុំទុកយូរទៀត ជើងរបស់ខ្ញុំអាចនឹងធ្ងន់ធ្ងរជាងនេះ ដូច្នេះហើយខ្ញុំក៏សម្រេចចិត្តថាកាត់ជើងឆ្វេងខ្ញុំចេញ។ បន្ទាប់ពីកាត់ជើងរួច ខ្ញុំក៏បានធូរស្រាល ហើយលែងមានការឈឺចាប់ខ្លាំងតទៅទៀត។ នៅពេលនេះ ខ្ញុំក៏មានអារម្មណ៍រីករាយខ្លាំងដែរ ដែលក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងចុះមកសួរសុខទុក្ខ និងនាំយករទេះរុញមកជូនខ្ញុំ គឺខ្ញុំពិតជាអរគុណខ្លាំងណាស់។ បន្ទាប់ពីទទួលបានរទេះរុញនេះ ខ្ញុំនឹងជិះទៅលេងបងប្អូនញាតិមិត្តជិតខាងនៅក្នុងភូមិ និងដើម្បីឲ្យខ្ញុំបានធូរស្បើយអារម្មណ៍ដែរ។




អន ពន ទទួលរទេះរុញពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាថ្នាក់រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហម ៖

## ការលើកយកប្រធានបទតូចៗនៃព្រឹត្តិការណ៍ក្នុងរបបខ្មែរក្រហមមកបង្រៀន គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការផ្តល់នូវចំណេះដឹងបំណិន និងឥរិយាបទរបស់ក្មេងៗជំនាន់ក្រោយ

ផេង ពង្សរ៉ាស៊ី



សិស្សមកពីវិទ្យាល័យ ហ៊ុន សែន ពារាំង ចូលរួមវេទិកាថ្នាក់រៀនស្តីពី «ការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា» រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





ចាប់តាំងពីឆ្នាំ២០១៥មក មជ្ឈមណ្ឌលឯកសារកម្ពុជាបានអនុវត្តគម្រោង «វេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ទាំងផ្លូវការ និងមិនផ្លូវការជាមួយសិស្សានុសិស្សដែលជាយុវជនជំនាន់ក្រោយចំនួនប្រមាណ២ម៉ឺននាក់រួចមកហើយ។ គម្រោងនេះ ស្ថិតក្រោមគោលបំណងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដើម្បីការបង្ហាញការរួម លើកទឹកចិត្តសិស្សឲ្យមានចិត្តអាណិតអាសូរចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម តាមរយៈការសិក្សាពីបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហម និងការត្រិះរិះពិចារណាពីវិធីសាស្ត្រជាក់លាក់មួយចំនួនក្នុងការទប់ស្កាត់អំពើហិង្សាដែលជាប្រភពនៃការកកើតអំពើប្រល័យពូជសាសន៍។

កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤កន្លងទៅ ក្នុងពិធីបើកអង្គសន្និសីទលើកទី១ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍» ក្នុងរយៈពេលបីថ្ងៃ ចាប់ពីថ្ងៃទី២០ ដល់ ថ្ងៃទី២២ ខែ

ឧសភា ឆ្នាំ២០២៤ នៅសាលយុត្តិតេជោ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងសារដ៏មានសារសំខាន់ដើម្បីលើកកម្ពស់ដល់ការបង្រៀនប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យពីកម្រិតអនុវិទ្យាល័យ រហូតដល់វិទ្យាល័យ និងបានលើកទឹកចិត្តឲ្យមានការចូលរួមបង្រៀន និងផ្សព្វផ្សាយ ពីគ្រប់ស្ថាប័នទាំងអស់ ទាំងយោធា និងស៊ីវិល ឲ្យមានការគាំទ្រដល់ការអប់រំពីអំពើប្រល័យពូជសាសន៍សម្រាប់មនុស្សជំនាន់ក្រោយ។

មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបាននឹងកំពុងអនុវត្តកិច្ចការដ៏មានសារសំខាន់នេះ នៅតែបន្តកិច្ចការងាររបស់ខ្លួនតទៅទៀត ព្រមទាំងបានបង្កើនការបង្រៀនពីប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ ដោយប្រើប្រាស់គ្រប់ទម្រង់នៃការបង្រៀនដើម្បីធានាថាការអប់រំពីអំពើប្រល័យពូជសាសន៍ កាន់តែមានប្រសិទ្ធភាព និងគុណភាពខ្ពស់ សម្រាប់ក្មេងៗជំនាន់ក្រោយរបស់កម្ពុជា។ សម្រាប់ឆ្នាំ២០២៤នេះ និងឆ្នាំបន្តបន្ទាប់ទៀតមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងបង្កើនការបង្រៀនរបស់ខ្លួនពីមេរៀនលម្អិតពីប្រធានបទតូចៗ ជាច្រើនដែលបានកើតមាននៅក្នុងរបបខ្មែរក្រហម ហើយប្រធានបទតូចៗទាំងនោះ នឹងត្រូវបានរៀបរៀងឲ្យក្លាយជាមេរៀនខ្លីៗ អមជាមួយនឹងកិច្ចតែងការបង្រៀនបែបទំនើបៗ ដែលធានាដល់ការសិក្សារបស់យុវជនជំនាន់ក្រោយឲ្យមានប្រសិទ្ធភាពខ្ពស់។

នៅព្រឹកថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពីការចងចាំប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងវិធីសាស្រ្តទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា ដល់យុវជនវ័យក្មេងចំនួន៣០នាក់ មកពីវិទ្យាល័យ ហ៊ុន សែន ពារាំង ស្រុកពារាំង ខេត្តព្រៃវែង។ វេទិកានេះ ត្រូវបានរៀបរៀងឡើងក្នុងគោលបំណងសំខាន់ៗចំនួន៣គឺៈ ១) ឈ្វេងយល់ពីព្រឹត្តិការណ៍ជម្លៀសប្រជាជនដោយបង្ខំរបស់ខ្មែរក្រហម ដំណាក់កាលទី១ ទី២ និងទី៣ ចាប់ផ្តើមពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៨។ ២) ឈ្វេងយល់ពីរបៀប និងមូលហេតុដែលនាំឲ្យខ្មែរក្រហមបង្កើតព្រឹត្តិការណ៍ជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាលទាំង ៣ និង ៣) ឈ្វេងយល់ពីបទពិសោធន៍នៃការជម្លៀសដោយបង្ខំរបស់អ្នករស់រានមានជីវិតនៅក្នុងសហគមន៍ៗ ដើម្បីសម្រេចបានគោលបំណងសំខាន់ទាំងបីនេះ សិស្សានុសិស្សដែលជាយុវជនវ័យក្មេងទាំងអស់ បានចំណាយពេលមួយថ្ងៃពេញ ដើម្បីសិក្សាលម្អិតពីប្រធានបទ «ការជម្លៀសប្រជាជនដោយបង្ខំរបស់ខ្មែរក្រហម» ពិភាក្សាស៊ីជម្រៅពីប្រធានបទ ចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សាទៅកាន់វាលពិឃាតខ្មែរក្រហមដែលអ្នកស្លាប់នៅទីនោះ ដែលភាគច្រើនជាប្រជាជនជម្លៀស និងស្តាប់សក្ខីកម្មពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលធ្លាប់ឆ្លងកាត់បទពិសោធន៍នៃការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម។

លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជានៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានលើកយកវិធីសាស្រ្តបង្រៀនពេញនិយមមួយគឺ ខេ-ដាបែលយូ-អិល (K-W-L TEACHING TECHNIQUE) មកប្រើប្រាស់ក្នុងការបង្រៀនពីមេរៀនការជម្លៀសប្រជាជនដោយបង្ខំ។ សកម្មភាពនៃការបង្រៀន ផ្តោតលើការវាស់ស្ទង់ចំណេះដឹងពីមុនរបស់សិស្សទាក់ទងនឹងប្រធានបទ ការវាយតម្លៃចំណេះដឹងទាំងនេះ ដើម្បីសម្របសម្រួលការបង្រៀនឲ្យត្រូវនឹងចំណេះដឹង ការផ្តល់ឱកាសដល់សិស្សឲ្យគិតគូរ និងដោះស្រាយចម្ងល់ផ្សេងៗរបស់ខ្លួនដែលមានទាក់ទងនឹងប្រធានបទ និងសំយោគចំណេះដឹងរបស់សិស្សទាក់ទងនឹងប្រធានបទ។ ក្នុងរយៈពេលពេញមួយព្រឹក លោក ផេង ពង្សរ៉ាស៊ី បានចំណាយពេលវេលាតែទៅលើការពន្យល់បកស្រាយពីប្រធានបទ និងដោះស្រាយចម្ងល់របស់សិស្សដែលបានចោទជាសំណួរទាក់ទងនឹងប្រធានបទសិក្សានៅក្នុងថ្ងៃនេះ។

នៅពេលរសៀលថ្ងៃដដែលលោក ដេង ពង្សរ៉ាស៊ី បានបន្តការពិភាក្សាពី និយមន័យនៃអំពើប្រល័យពូជសាសន៍ កត្តាគ្រោះថ្នាក់ជាក់លាក់មួយចំនួនដែលនាំឲ្យកើតមានអំពើប្រល័យពូជសាសន៍ និងវិធីសាស្ត្រជាក់លាក់មួយចំនួនក្នុងការចូលរួមទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត។ បន្ទាប់មកទៀតលោក ដេង ពង្សរ៉ាស៊ី និងក្រុមការងារ បានដឹកនាំក្រុមយុវជនវ័យក្មេងទាំងនោះទៅកាន់ទីតាំងសម្លាប់របស់ខ្មែរក្រហមមួយកន្លែង ស្ថិតនៅក្នុងឃុំបាបោង ស្រុកពាមរក៍ ស្ថិតនៅចម្ងាយប្រមាណ៣០គីឡូម៉ែត្រពីទីរួមខេត្តព្រៃវែង។ នៅទីនោះ យុវជនវ័យក្មេងទាំងអស់បានសង្កេតមើលស្លាកស្នាមរណ្ដៅដែលនៅសេសសល់បន្តិចបន្តួច និងបានជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់ ដែលធ្លាប់មានបទពិសោធន៍ក្នុងការជម្លៀសដោយបង្ខំក្នុងដំណាក់កាលទី៣ ទៅកាន់ភូមិភាគពាយ័ព្យ កាលពីឆ្នាំ១៩៧៨។

ការសិក្សាក្រៅថ្នាក់រៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ព្រោះថាយុវជនវ័យក្មេងទាំងអស់បានស្ដាប់ផ្ទាល់ដោយផ្ទាល់ត្រចៀក មើលឃើញដោយផ្ទាល់ភ្នែក និងនឹកគិតពិចារណាពីរូបភាព និងព្រឹត្តិការណ៍ដែលបានកើតឡើងពីអតីតកាលមកលើដីដូនដីតារបស់ខ្លួន ដែលបានទទួលរងគ្រោះដោយសារមានមេដឹកនាំដែលដឹកនាំឲ្យមានការកាប់សម្លាប់ ធ្វើទារុណកម្ម បង្អត់អាហារ បំបែកក្រុមគ្រួសារ និងធ្វើការហួសកម្លាំង។ ចំណុចទាំងអស់នេះ គឺជាមេរៀនដ៏មានប្រសិទ្ធភាពដែលបានផ្ដល់ដល់យុវជននូវចំណេះដឹងពីប្រវត្តិ-សាស្ត្រ បង្កើនភាពប៉ិនប្រសប់ចំពោះការរារាំងការវិលត្រឡប់នៃអំពើប្រល័យពូជសាសន៍ និងលើកកម្ពស់ឲ្យមានឥរិយាបថថ្លៃថ្នូរ មានសីលធម៌ និងជំនាញទប់ស្កាត់អំពើហិង្សាប្រកបដោយការទទួលខុសត្រូវចំពោះមនុស្សដែលនៅជុំវិញខ្លួន។



សិស្សមកពីវិទ្យាល័យ ហ៊ុន សែន ពារាំង ចូលរួមវេទិកាថ្នាក់រៀនស្ដីពី «ការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា» រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកា

## ថ្នាក់រៀនស្តីពី សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ដល់សិស្សវិទ្យាល័យស្រែណូយ

ស្លូត វិចិត្រ



សិស្សមកពីវិទ្យាល័យ ស្រែណូយ ចូលរួមវេទិកាថ្នាក់រៀនស្តីពី «ការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា» រៀបចំដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សា «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)» ដល់សិស្សនៃវិទ្យាល័យស្រែណូយចំនួន២០នាក់។ គោលបំណងនៃការរៀបចំវេទិកាថ្នាក់រៀននេះ គឺដើម្បីលើកកម្ពស់ការយល់ដឹង និងការចងចាំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), ការការពារ និងទប់ស្កាត់ការកកើតឡើងវិញនៃអំពើប្រល័យពូជសាសន៍តាមរយៈការមិនប្រព្រឹត្តអំពើហិង្សាគ្រប់ទម្រង់ មិនប្រកាន់ពណ៌សម្បុរ ពូជសាសន៍ ជនជាតិ និងនិន្នាការនយោបាយ។

មុនចាប់ផ្តើមកម្មវិធី បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ឲ្យសិស្សទស្សនាភាពយន្តឯកសារដែលមានចំណងជើងថា «គុកទួលស្លែង»។ ភាពយន្តឯកសារនេះ ត្រូវបានថតដោយអ្នកកាសែតជនជាតិវៀតណាមឈ្មោះ ហូ វ៉ាន់តាយ នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៥ បន្ទាប់ពីការដួលរលំរបបខ្មែរក្រហម។ សិស្សម្នាក់ៗគឺតម្រូវឲ្យសរសេរការយល់ឃើញរបស់ខ្លួនបន្ទាប់ពីទស្សនាភាពយន្តឯកសារនេះចប់។ សិស្សមួយចំនួន

យល់ឃើញថា ភាពយន្តឯកសារនេះពោរពេញទៅដោយការឈឺចាប់ និងទុក្ខលំបាក ដែលអ្នកទោសបានជួបប្រទះ។ ចំណែកសិស្សខ្លះទៀតយល់ថា របបខ្មែរក្រហមគ្មានច្បាប់ ហើយថែមទាំងសម្លាប់មនុស្សស្រេចតែចិត្ត។ នៅផ្នែកបន្ទាប់ បណ្ឌិត លី សុខឃាង ក៏បានធ្វើបទបង្ហាញអំពីការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង និងទីប្រជុំជនដោយយោងទៅលើហេតុផលសំខាន់ៗ ដូចជា ១) ខ្លាចកងទ័ពសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែក, ២) ខ្វះមធ្យោបាយដឹកស្បៀង, ៣) បោសសម្អាតខ្មាំង។ នៅក្នុងនោះ អតីតកងទ័ព និងមន្ត្រីរដ្ឋការ លន់ នល់ ត្រូវបានដឹកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ ដែលស្ថិតនៅកៀកនឹងបឹងទន្លេសាបក្នុងខេត្តពោធិ៍សាត់ ក្នុងហេតុផលកោះហៅឲ្យចូលរួមវគ្គបណ្តុះបណ្តាល និងចូលគាល់សម្តេចព្រះ នរោត្តម សីហនុ។ មានការប៉ាន់ស្មានថា អតីតទាហាន និងមន្ត្រីរដ្ឋការ លន់ នល់ ទាំងនោះត្រូវបានសម្លាប់ប្រមាណពី ២ពាន់ទៅ ៨ពាន់នាក់។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចាត់ចូលសំណុំរឿងនេះជាសំណុំរឿងមួយ ដើម្បីជំនុំជម្រះទោសទៅលើមេដឹកនាំខ្មែរក្រហម។ នៅក្នុងទិដ្ឋភាពផ្លូវច្បាប់ កេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) គឺជាឯកសារផ្លូវច្បាប់ដែលបញ្ជាក់ថា របបខ្មែរក្រហមបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មយ៉ាងធ្ងន់ធ្ងរទៅលើប្រជាជនកម្ពុជា។ ជាងនេះទៀត យុវជនអាចរៀនសូត្រពីប្រវត្តិសាស្ត្រនៅក្នុងសង្គមរបស់ខ្លួនដែលមានប្រភពឯកសារច្បាស់លាស់។

នៅផ្នែកចុងក្រោយនៃវេទិកា សិស្សបានរៀនពីវិធីសាស្ត្រនៃការទប់ស្កាត់អំពើហិង្សា និងអំពើប្រល័យពូជសាសន៍នាពេលអនាគត ដោយផ្អែកលើសំណួរមួយថា តើក្នុងនាមជាយុវជនម្នាក់អាចធ្វើអ្វីបានខ្លះចំពោះការទប់ស្កាត់អំពើហិង្សា និងអំពើប្រល័យពូជសាសន៍នាពេលអនាគត។ នៅក្នុងចំណុចនេះការបដិសេធចំពោះអំពើហិង្សា, ការលើកទឹកចិត្តឲ្យមានដំណោះស្រាយដោយសន្តិវិធីចំពោះជម្លោះ និងនិយាយប្រឆាំងនឹងអំពើហិង្សា, ការការពារសិទ្ធិជាបុគ្គលរបស់សមាជិកក្នុងសហគមន៍ដោយមិនគិតពីពណ៌សម្បុរ និន្នាការនយោបាយ និងការបង្រៀនយុវជនឲ្យស្រឡាញ់ភាពសម្បូរបែបនៃវប្បធម៌ សាសនា និងសហគមន៍ ការទទួលបានការអប់រំ ទំនាក់ទំនងការទូត និងមូលហេតុដែលនាំឲ្យកើតមានអំពើប្រល័យពូជសាសន៍គឺសុទ្ធសឹងតែជាវិធីសាស្ត្រដែលអាចឲ្យយុវជនចេះគិតគូរពិចារណា និងឆ្លុះបញ្ចាំងអំពីខ្លួនឯង សហគមន៍ និងសង្គមជាតិ។

នៅចុងបញ្ចប់នៃវេទិកាថ្នាក់រៀន សិស្សបានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖

**ណាន ផានិត** ភេទប្រុស អាយុ១៧ឆ្នាំ រៀនថ្នាក់ទី១២ នៅវិទ្យាល័យស្រែណូយ បានលើកឡើងថា៖ «ខ្ញុំយល់ថាការសិក្សារៀនសូត្រពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ល្អខ្លាំងណាស់សម្រាប់ខ្ញុំ ព្រោះធ្វើឲ្យខ្ញុំដឹងពីប្រវត្តិសាស្ត្រដ៏យោរយៅនៅក្នុងរបបនោះ។ នៅថ្ងៃមុខ ខ្ញុំអាចយកប្រវត្តិសាស្ត្រមួយនេះទៅប្រាប់ដល់ប្អូនជំនាន់ក្រោយ ដើម្បីកុំឲ្យអំពើប្រល័យពូជសាសន៍កើតមានឡើងម្តងទៀត។ ការសិក្សាអំពីប្រវត្តិសាស្ត្រនៅថ្ងៃនេះ បានធ្វើឲ្យខ្ញុំយល់ដឹងបន្ថែមអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដោយបង្ខំ ការកាប់សម្លាប់ ការធ្វើទារុណកម្មប្រជាជន និងអំពើកាចសាហាវផ្សេងៗទៀត។ ចំពោះការកាត់ទោសមេដឹកនាំខ្មែរក្រហមអាចជួយឲ្យខ្ញុំដឹងអំពីការទទួលបាននូវយុត្តិធម៌ សម្រាប់ជនរងគ្រោះ និងនាំឲ្យអ្នកដែលបានប្រព្រឹត្តកំហុស ទទួលទោសទៅតាមច្បាប់។ ក្នុងនាមខ្ញុំជាយុវជនម្នាក់ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍កុំឲ្យកើតមានឡើងម្តងទៀត គឺត្រូវតែអប់រំលើផ្នែកសិទ្ធិមនុស្ស ការមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ មិនមានការបិទសិទ្ធិសេរីភាព និងធ្វើការណែនាំក្មេងៗជំនាន់ក្រោយឲ្យបានយល់ដឹងពីភាពយោរយៅនៅក្នុងរបបខ្មែរក្រហម។

**ទូច ផល្លា** ភេទស្រី អាយុ២១ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ វិទ្យាល័យស្រែណូយ រៀបរាប់ថា «ខ្ញុំពិតជាចង់រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ខ្លាំងណាស់ ព្រោះការរៀនប្រវត្តិសាស្ត្រធ្វើឲ្យខ្ញុំបានដឹងពីរបៀបរបបនៃការរស់នៅរបស់ប្រជាជនពីសម័យកាលនីមួយៗ និងប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតដែលប្រជាជនបានឆ្លងកាត់របបខ្មែរក្រហម។ ខ្ញុំគិតថាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានជួយដល់ខ្ញុំរួមទាំងសង្គមជាតិយ៉ាងធំធេង ពីព្រោះតុលាការបានជួយរកយុត្តិធម៌ដល់បងប្អូនសាច់ញាតិដែលបានបាត់បង់សមាជិកគ្រួសារនៅក្នុងជំនាន់នោះ រួមទាំងអ្នកដែលបានស្លាប់ទៅហើយ។ លើសពីនេះទៅទៀត គឺជួយទប់ស្កាត់អំពើឃោរឃៅមិនឲ្យកើតមានឡើងនៅក្នុងប្រទេសកម្ពុជាម្តងទៀត។ ក្នុងនាមខ្ញុំជាយុវជនម្នាក់ ដើម្បីចូលរួមទប់ស្កាត់អំពើប្រល័យពូជសាសន៍ ខ្ញុំត្រូវចូលរួមណែនាំអំពីការមិនប្រើប្រាស់អំពើហិង្សា ការចេះឲ្យតម្លៃគ្នាទៅវិញទៅមក និងយោគយល់អធ្យាស្រ័យគ្នាតាមដែលអាចធ្វើទៅបាន»។

**ឈន ប៊ុនហេង** ភេទប្រុស អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ វិទ្យាល័យស្រែណូយ បានឲ្យដឹងថា « ខ្ញុំពិតជារំភើបណាស់ដែលបានមកចូលរួមក្នុងវេទិកាថ្នាក់រៀន ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ពីព្រោះការរៀនពីប្រវត្តិសាស្ត្រនេះបានធ្វើឲ្យខ្ញុំយល់ដឹងពីការដឹកនាំក្នុងរបបខ្មែរក្រហម។ លើសពីនេះទៅទៀត ខ្ញុំបានឈ្វេងយល់បន្ថែមទៀតពីការជម្លៀសប្រជាជនដោយបង្ខំ ការឡើងកាន់អំណាចរបស់ខ្មែរក្រហម ការធ្វើទារុណកម្មលើអ្នកទោស និងប្រជាជននៅក្នុងរបបកុម្មុយនីស្ត។ ក្នុងនាមខ្ញុំជាយុវជនជំនាន់ក្រោយម្នាក់ ដើម្បីទប់ស្កាត់កុំឲ្យអំពើប្រល័យពូជសាសន៍កើតមានឡើងម្តងទៀត គឺខ្ញុំត្រូវផ្សព្វផ្សាយពីផលវិបាកនៃការកើតមានអំពើប្រល័យពូជសាសន៍ចូលរួមឈ្វេងយល់ពីប្រវត្តិសាស្ត្រឲ្យបានកាន់តែច្រើនដើម្បីយកទៅប្រាប់ក្មេងៗជំនាន់ក្រោយ ហើយជាងនេះទៅទៀតនោះ គឺយើងមិនត្រូវប្រើប្រាស់អំពើហិង្សា និងរើសអើងពូជសាសន៍ឡើយ»។

**នីម ស៊ីនឿន** ភេទស្រី អាយុ១៨ឆ្នាំ លើកឡើងថា «ការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បានជួយឲ្យខ្ញុំមានចំណេះដឹងទៅលើជីវភាពរស់នៅរបស់ប្រជាជនក្នុងរបបខ្មែរក្រហម។ ការឈ្វេងយល់ពីប្រវត្តិសាស្ត្រនេះបានធ្វើឲ្យខ្ញុំដឹងបន្ថែមអំពីការជម្លៀសប្រជាជនចេញពីទីក្រុង ការកៀបសង្កត់ប្រជាជន និងសង្គ្រាមនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំនៅតែចង់ដឹងថាហេតុអ្វីខ្មែរក្រហមធ្វើបាបប្រជាជនខ្លួនឯង ការបង្កើតរបបខ្មែរក្រហមដើម្បីតែសម្លាប់ប្រជាជនខ្មែរ ឬយ៉ាងណា? តើមូលហេតុអ្វីបានជាមានការជម្លៀសប្រជាជនដោយបង្ខំ និងប្រើប្រាស់អំពើហិង្សាយ៉ាងព្រៃផ្សៃទៅលើអ្នកទោស? ក្នុងនាមខ្ញុំជាយុវជនម្នាក់ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍យើងត្រូវចូលរួមអភិវឌ្ឍន៍ប្រទេស លុបបំបាត់ចោលនូវការរើសអើង និងប្រឆាំងនឹងអំពើពុករលួយដែលមាននៅក្នុងសង្គម។





សិស្សមកពីវិទ្យាល័យ ស្រែណូយ ចូលរួមវេទិកាថ្នាក់រៀនស្តីពី «ការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា» រៀបចំដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្តោតលើប្រធានបទ ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម ដល់យុវជន-យុវនារីមកពីស្រុកចំការលើ

*សាំង ចាន់ធូ*



យុវជនមកពីស្រុកចំការលើ ចូលរួមវេទិកាថ្នាក់រៀនស្តីពី «ការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)» រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្តោតលើប្រធានបទ៖ «ការជម្លៀសប្រជាជនដោយបង្ខំក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីយុវជន-យុវនារីមកពីស្រុកចំការលើ ចំនួន២០នាក់ ក្នុងនោះមានស្រីចំនួន១៨នាក់។ គោលបំណងនៃការរៀបចំវេទិកាថ្នាក់រៀនគឺដើម្បីបង្កើនចំណេះដឹងដល់យុវជន-យុវនារីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងជាការលើកកម្ពស់វិធានការទប់ស្កាត់អំពើប្រល័យពូជសាសន៍កុំឲ្យកើតឡើងនាពេលអនាគត។

ជាកិច្ចស្វាគមន៍ក្រុមការងារនៃមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានទទួលស្វាគមន៍ និងណែនាំយុវជន-យុវនារីឲ្យទស្សនាផ្ទាំងពិព័រណ៍នៅបរិវេណខាងមុខមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលបង្ហាញអំពីប្រវត្តិមេដឹកនាំខ្មែរក្រហម, ការជម្លៀសប្រជាជនដោយបង្ខំ, ការធ្វើការងារនៅតាមការដ្ឋាន និងមេដឹកនាំខ្មែរក្រហមដែលត្រូវបានកាត់ទោស

នៅសាលាក្តីខ្មែរក្រហម។ បន្ទាប់មក យុវជន-យុវនារី ទស្សនាបន្ទប់តម្កល់ឯកសារខ្មែរក្រហម និងបណ្ណាល័យរបស់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមក៏មានសាលពិព័រណ៍រូបថត ដែលដាក់តាំងបង្ហាញព្រះឆាយាល័ក្ខណ៍ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ចំនួន១៨ផ្ទាំង ដែលជាផ្នែកមួយនៃពិព័រណ៍ «ក្តីសុបិនកម្ពុជា» រៀបចំដោយ «ព្រះរាជបណ្ណាល័យ ហ៊ូងម៉ែ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅក្នុងឱកាសនោះ លោក លី ដេវីត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ក៏ឡើងបង្ហាញអំពីកីតម្បាញសូត្រចាម ដែលជាផ្នែកមួយនៃ «គម្រោងសូត្រចាម» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

ជាកិច្ចបន្តលោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចាប់ផ្តើមធ្វើបទបង្ហាញរបស់ខ្លួនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលផ្តោតទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ ដូចជា៖ រដ្ឋប្រហារ លន់ នល់ នៅឆ្នាំ១៩៧០, ការផ្ទុះឡើងនូវសង្គ្រាមជិត៥ឆ្នាំរវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម, ការចូលកាន់កាប់ទីក្រុងភ្នំពេញដោយកងទ័ពខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥, ការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជនទៅកាន់ជនបទ, ការបង្ខំប្រជាជនឲ្យធ្វើការងារហួសកម្លាំងនៅតាមការដ្ឋានទំនប់ និងការកាប់សម្លាប់ទៅលើប្រជាជន។ ក្នុងចំណោមព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗខាងលើ លោក ស៊ាង ចិន្តា បានជ្រើសរើសយកប្រធានបទការជម្លៀសដោយបង្ខំទាំងបីដំណាក់កាលមកពិភាក្សាក្នុងវេទិកាថ្នាក់រៀន។ ការជម្លៀសប្រជាជនដោយបង្ខំទាំងបីដំណាក់កាល មានដូចជា៖ ១) ភ្លាមៗ បន្ទាប់ពីចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមអនុវត្តការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជននានាទៅកាន់ទីជនបទ។ ២) ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧ ប្រជាជននៅភូមិភាគកណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា (រួមមានខេត្តកណ្តាល កំពង់ធំ តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ចាម) ត្រូវបានជម្លៀសដោយបង្ខំក្នុងដំណាក់កាលទី២ ឆ្ពោះទៅកាន់ខេត្តសៀមរាប ខេត្តព្រះវិហារ និង ភូមិភាគពាយ័ព្យ (រួមមាន ខេត្តបាត់ដំបង ពោធិ៍សាត់ និងបន្ទាយមានជ័យ) និង ៣) ការជម្លៀសប្រជាជនពីភូមិភាគបូព៌ាចាប់ពីឆ្នាំ១៩៧៧ រហូតដល់ចុងឆ្នាំ១៩៧៨។ ប្រជាជននៅភូមិភាគបូព៌ាត្រូវបានជម្លៀសចេញពីផ្ទះសម្បែងឆ្ពោះទៅភូមិភាគពាយ័ព្យ រួមមាន ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង។

នៅចុងបញ្ចប់នៃបទបង្ហាញ លោក ស៊ាង ចិន្តា លើកឡើងអំពីនិយមន័យ និងវិធីសាស្ត្រទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងអំពើប្រល័យពូជសាសន៍។ បន្ទាប់ពីបទបង្ហាញបានបញ្ចប់ យុវជន-យុវនារី បានសួរសំណួរដើម្បីឲ្យវាគ្មិនធ្វើការបកស្រាយចម្ងល់របស់ខ្លួន។ ផ្សារភ្ជាប់ជាមួយវេទិកាថ្នាក់រៀន យុវជន-យុវនារី បានធ្វើទស្សនកិច្ចសិក្សាទៅកាន់ស្តូបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះនៃរបបខ្មែរក្រហមស្ថិតនៅឃុំគគរ ស្រុកកំពង់សៀម និងទស្សនាសហគមន៍តម្បាញសូត្រចាម នៅសហគមន៍កោះសូទិន ខេត្តកំពង់ចាម។

បន្ទាប់ពីបានចូលរួមក្នុងវេទិកាថ្នាក់រៀន និងដំណើរទស្សនកិច្ចរួចមក យុវជន-យុវនារីបានបង្ហាញនូវចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម៖

**ថា សុខជាតិ** រៀបរាប់ថា «ខ្ញុំទទួលបានចំណេះដឹងថ្មីៗ ពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងយល់ដឹងអំពីដំណាក់កាលដែលខ្មែរក្រហមជម្លៀសប្រជាជនដោយបង្ខំ។ ខ្ញុំពិតជាមានចិត្តអាណិតអាសូរប្រជាជនខ្មែរដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ហើយទទួលរងទុក្ខលំបាកវេទនា ការបង្ខំឲ្យធ្វើការហួសកម្លាំង ការធ្វើទារុណកម្ម ការមិនមានអាហារហូបគ្រប់គ្រាន់ និងទទួលរងការសម្លាប់យ៉ាងសាហាវព្រៃផ្សៃ។ ក្នុងនាមជាយុវជនជំនាន់ក្រោយ ខ្ញុំនឹងខិតខំរៀនសូត្រដើម្បីចូលរួមការអភិវឌ្ឍន៍ប្រទេសជាតិ និងចូលរួមការពារសន្តិភាព ទប់ស្កាត់កុំឲ្យរបប

ប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀត»។

**នីន ស្វីស** លើកឡើងថា «ខ្ញុំយល់ដឹងច្រើនជាងមុនពីប្រវត្តិសាស្ត្រខ្មែរក្រហម មានដូចជា ការជម្លៀសប្រជាជនដោយបង្ខំ ការបង្ខំឲ្យធ្វើការជាទម្ងន់ ការហូបចុកមិនគ្រប់គ្រាន់ និងការចាប់យកទៅសម្លាប់ ដែលបានបណ្តាលឲ្យប្រជាជនជាច្រើនលាននាក់បានស្លាប់ក្នុងរបបខ្មែរក្រហម។ បន្ថែមលើអ្វីដែលខ្ញុំបានរៀននៅក្នុងវេទិកានេះ ខ្ញុំក៏បានចុះទៅកាន់ទីតាំងស្តូបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅស្រុកកំពង់សៀម និងទស្សនាការត្បាញសូត្ររបស់សហគមន៍ចាម នៅស្រុកកោះសូទិន។ ខ្ញុំបានដឹងរឿងរ៉ាវរបស់សហគមន៍ចាម និងការរស់ឡើងវិញនូវការត្បាញសូត្ររបស់បងប្អូនចាម បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ»។



យុវជនមកពីស្រុកចំការលើទស្សនកិច្ចស្តូបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម និងសហគមន៍តម្បាញសូត្រជនជាតិចាមនៅស្រុកកោះសូទិន ខេត្តកំពង់ចាម ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





# មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាថ្នាក់រៀន

## ស្តីអំពី ប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់សិស្សវិទ្យាល័យលាជលើ

**ទី ស៊ីថា, ខន បុប្ផា, ម៉ាប់ ស៊ីណា**







*សិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន លាជលើ ចូលរួមវេទិកាថ្នាក់រៀនស្តីពី «ការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា» រៀបចំដោយមជ្ឈមណ្ឌលឯកសារកោះថ្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារកោះថ្ម បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយមានការចូលរួមពីសិស្សចំនួន២០នាក់ ក្នុងនោះមានសិស្សស្រីចំនួន១១នាក់ មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែនលាជលើ។

ជាកិច្ចចាប់ផ្តើម លោក ឈុំ រ៉ា បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្មធ្វើបទបង្ហាញដល់សិស្សអំពីពិព័រណ៌ផ្ទាំងគំនូរ, រូបភាព, ផែនទី ដែលដាក់តាំងនៅក្នុងការិយាល័យមជ្ឈមណ្ឌលឯកសារកោះថ្ម។ ពិព័រណ៌ទាំងនេះ រួមមានរូបថតចំនួន១៣៣សន្លឹក រូបគំនូរចំនួន៣៨ផ្ទាំង និងផែនទីចំនួន៦ផ្ទាំង និងត្រូវបានបែងចែកជា៥ផ្នែកដែលមានរៀបរាប់ដូចខាងក្រោម ៖

**ផ្នែកទី១៖** ផែនទីអំពីខ្ទម្លាគបក្រចំនួន៣គ្រឿងរបស់សហរដ្ឋអាមេរិកដែលបានធ្លាក់ក្នុងអំឡុងសង្គ្រាមវៀតណាមទសវត្សរ៍ឆ្នាំ១៩៧០ នៅតំបន់កោះថ្ម (ឃុំជាំក្រវៀន) ស្រុកមេមត់។

**ផ្នែកទី២៖** បណ្តុំរូបភាពក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ថតដោយជនជាតិ



លោក ឈុំ វ៉ា ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បង្ហាញអំពីផែនទីបង្ហាញផ្លូវដែល សម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្តទាំង៤រូប ចាកចេញពីបន្ទាយកងវរសេនាធំកោះថ្ម ទៅកាន់ប្រទេសវៀតណាម នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដើម្បីកសាងកម្លាំងវាយផ្តួលរំលំរបបខ្មែរក្រហម ដល់សិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន លាជលើ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស៊ុយអ៊ែតឈ្មោះ ហ្គុណា បឺយស្ត្រម ដែលត្រូវបាន ប៉ុល ពត អញ្ជើញឲ្យមកទស្សនកិច្ចប្រទេសកម្ពុជា ក្នុងខែសីហា ឆ្នាំ១៩៧៨។ ខ្មែរក្រហមបានរៀបចំឲ្យ ហ្គុណា បឺយស្ត្រម ធ្វើដំណើរ និងទស្សនានៅទីកន្លែងមួយចំនួនក្នុងខេត្តកំពង់ចាម និងខេត្តកំពង់ធំ ដូចជា នៅផ្សារក្នុងខេត្តកំពង់ចាម ការដ្ឋានទំនប់១មករា។ ហ្គុណា បឺយស្ត្រម បានសរសើររបបកម្ពុជាប្រជាធិបតេយ្យ និងបានឃើញទឹកមុខប្រជាជនធ្វើការងារដោយស្នាមញញឹម។ នៅពេល ហ្គុណា បឺយស្ត្រម ត្រឡប់មកប្រទេសកម្ពុជាម្តងទៀតនៅក្នុងឆ្នាំ២០០៨ ទើបគាត់ដឹងច្បាស់ថា ប្រជាជនកម្ពុជាច្រើនលាននាក់ត្រូវបានខ្មែរក្រហមសម្លាប់យ៉ាងឃោរឃៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហ្គុណា បឺយស្ត្រម បានប្រគល់រូបថតទាំងអស់ដែលបានថតដល់មជ្ឈមណ្ឌលឯកសារកម្ពុជា និងមានការសោកស្តាយជាខ្លាំងចំពោះ ថាជឿជាក់លើរបបកម្ពុជាប្រជាធិបតេយ្យ។

**ផ្នែកទី៣៖** រូបភាពថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គឺជាថ្ងៃដែលប្រជាជនកម្ពុជាបានរស់រាន និងមានសេរីភាពឡើងវិញ។ ប្រជាជនកម្ពុជាបានធ្វើដំណើរវិលត្រឡប់មកស្រុកកំណើតវិញ និងចាប់ផ្តើមកសាងជីវភាពឡើងវិញពីបាតដៃទទេ។

**ផ្នែកទី៤៖** បណ្តុំរូបភាពអំពីសកម្មភាពក្រោយពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ សកម្មភាពប្រជាជនធ្វើដំណើរ និងប្រកបរបររកស៊ី។ ចំណែកក្មេងៗត្រឡប់ទៅរៀនសូត្រវិញ។ ក្រុមអ្នកស្រាវជ្រាវចាប់ផ្តើមស្វែងរក និងជីករណ្តៅសាកសព សាងសង់បូជនីយស្ថាន ដើម្បីធ្វើពិធីបង្សុកូល និងឧទ្ទិសកុសលដល់អ្នកបែកបាក់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ បណ្តុំរូបភាពឧក្រិដ្ឋកម្មទាក់ទងជាមួយរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដូចជា វត្តអារាម ត្រូវបានប្រើប្រាស់ជាកន្លែងធ្វើជាមន្ទីរសន្តិសុខ ធ្វើឲ្យបែកបាក់រូបបដិមាករ និងបន្សល់ទុកជនពិការជាច្រើននាក់។

**ផ្នែកទី៥៖** ផ្ទាំងរូបគំនូរ សម្តេច ហ៊ុន សែន ទីតាំងបន្ទាយកងវរសេនាធំតំបន់២១ ភូមិភាគបូព៌ា។ ដោយឃើញការសម្លាប់យ៉ាងឃោរឃៅ សម្តេច ហ៊ុន សែន បានសម្រេចចិត្តដកខ្លួនចេញពីរបបខ្មែរក្រហម។ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ សម្តេច និងសមមិត្ត៤រូបទៀត បានធ្វើដំណើរពីទីតាំងបន្ទាយកងវរសេនាធំទៅកាន់ប្រទេសវៀតណាម ដើម្បី

កសាងកងកម្លាំងសាមគ្គីសង្គ្រោះជាតិកម្ពុជាវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត។

ជាកិច្ចបន្ទាប់ លោក ឡុង ដានី នាយកមជ្ឈ-មណ្ឌលឯកសារកោះថ្ម បានធ្វើការណែនាំខ្លួន និងគោលបំណងដែលបង្កើតមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលមាន៤ចំណុចសំខាន់ៗដូចខាងក្រោម ៖

១) បង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាជាពិសេសសង្គ្រាមស៊ីវិលចាប់ផ្តើមពីចុងទសវត្សរ៍ឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៩០។

២) ពង្រឹងកសាងសន្តិភាព និងទប់ស្កាត់ជម្លោះ តាមរយៈកម្មវិធីអប់រំដែលផ្តល់ឱកាសដល់យុវជនតាមជនបទ និងតំបន់ដាច់ស្រយាលបានចូលរៀនសូត្រ។

៣) លើកទឹកចិត្តឲ្យយុវជនសួរនាំអំពីបញ្ហារឿងរ៉ាវដែលលោកតាលោកយាយ ធ្លាប់បានឆ្លងកាត់ពីរបបខ្មែរក្រហម ថា តើមានរឿងរ៉ាវអ្វីដែលលោកតា លោកយាយ អំពូមីង នៅចងចាំមិនភ្លេច និង មួយទៀតសួរទាក់ទងជាមួយ បញ្ហាសុខភាពដែលលោកតា លោកយាយ អំពូមីង កំពុងតែកើតមានបច្ចុប្បន្ន។

៤) មជ្ឈមណ្ឌលឯកសារកោះថ្មនៅតែបន្តចងក្រងឯកសារជាប្រវត្តិសាស្ត្រផ្ទាល់មាត់ និងទីតាំងឧក្រិដ្ឋកម្មនានា ដើម្បីទុកជាឯកសារឲ្យក្មេងៗជំនាន់ក្រោយបានសិក្សាឈ្វេងយល់បន្ថែមទៀត។

តមកទៀត លោក ឡុង ដានីបានឲ្យសិស្សានុ-សិស្សធ្វើការចែករំលែកចំណេះដឹងមុនសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងផ្តល់ឱកាសឲ្យសិស្សានុសិស្សសួរសំណួរមាន៖

១) តើការធ្វើទារុណកម្មនៅសម័យខ្មែរក្រហមធ្ងន់ធ្ងរប៉ុនណា?

២) ហេតុអ្វីបានជាខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

៣) តើរបប ប៉ុល ពត ធ្វើទារុណកម្មអ្វីខ្លះ?

៤) ហេតុអ្វីបានជាបង្កឲ្យមានសង្គ្រាមកើតឡើងនៅប្រទេសកម្ពុជា?

៥) តើនៅរបប ប៉ុល ពត មានគោលបំណងអ្វីបានជាលុបបំបាត់សាសនា និង សាលារៀន?

៦) ហេតុអ្វីបានជាខ្មែរក្រហមបង្អត់អាហារប្រជាជនហើយឲ្យប្រជាជនធ្វើការងារធ្ងន់?

៧) តើនៅក្នុងសង្គ្រាមប្រជាជនជួបផលលំបាកអ្វីខ្លះ?

៨) ប្រជាជនខំធ្វើស្រែចម្ការគ្មានពេលសម្រាកហើយហូបមិនគ្រប់គ្រាន់ តើទិន្នផលទាំងអស់នោះត្រូវប្រមូលយកទៅណាខ្លះ?

៩) តើហេតុអ្វីបានជាខ្មែរក្រហមធ្វើសង្គ្រាមជាមួយប្រទេសវៀតណាម?

ក្នុងឱកាសនោះ លោក ឡុង ដានី ឡើងធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយផ្តោតលើការឡើងកាន់អំណាចរបស់ខ្មែរក្រហម៖«ការជម្លៀសប្រជាជនចេញពីទីក្រុង និងការជម្លៀសដោយបង្ខំដំណាក់កាលទី៣»។ លោក ឡុង ដានី បានលើកឡើងថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញ ពេលនោះប្រជាជននាំគ្នាអបអរជាមួយខ្មែរក្រហម ពីព្រោះគិតថាប្រទេសបានរួចផុតពីសង្គ្រាម ដោយសារតែរដ្ឋប្រហាររបស់ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ប្រជាជននាំ



សិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន លាជលើ ចូលរួមវេទិកាថ្នាក់រៀនស្តីពី «ការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា» រៀបចំដោយមជ្ឈមណ្ឌលឯកសារកោះថ្ម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គ្នាសប្បាយរីករាយ ដោយយល់ថានឹងមានសន្តិភាពវិញ ប៉ុន្តែរយៈពេល២ទៅ៣ម៉ោងក្រោយមក ខ្មែរក្រហមបានប្រកាសជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដោយយកលេសថា ខ្មាំងអាមេរិកទម្លាក់គ្រាប់បែក។ ដូច្នេះសូមឲ្យប្រជាជនចាកចេញដោយមិនបាច់យករបស់របរទៅជាមួយខ្លួនឡើយ ព្រោះមានអង្គការបដិវត្តន៍នៅចាំទទួល។ ចំពោះប្រជាជនដែលជំទាស់ជាមួយអង្គការត្រូវបានខ្មែរក្រហមគំរាមសម្លាប់ ដើម្បីព្រមានដល់ប្រជាជនផ្សេងទៀត។ ការជម្លៀសប្រជាជនក៏ចាប់ផ្តើមឡើងតាំងពីពេលនោះមក ដោយបែងចែកជា៣ដំណាក់កាល ៖

**១) ដំណាក់កាលទី១៖** ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដោយគ្មានគោលដៅច្បាស់លាស់។

**២) ដំណាក់កាលទី២៖** ពីខែកញ្ញា ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមជម្លៀសប្រជាជនចេញពីភូមិភាគមួយទៅកាន់ភូមិភាគមួយទៀត និងពីតំបន់មួយទៅតំបន់មួយទៀត។ នៅពេលនោះរថភ្លើងគឺជាមធ្យោបាយដ៏សំខាន់ក្នុងការជម្លៀសប្រជាជនដោយបង្ខំទៅកាន់ភូមិភាគពាយ័ព្យ ដោយឈរប្រជ្រៀតគ្នា និងគ្មានអាហារហូបចុក។

**៣) ដំណាក់កាលទី៣៖** ចាប់ពីចុងឆ្នាំ១៩៧៧ ដល់១៩៧៨ ខ្មែរក្រហមជម្លៀសប្រជាជនចេញពីភូមិភាគបូព៌ា ទៅភូមិភាគពាយ័ព្យ ដោយមានការសង្ស័យលើប្រជាជនភូមិភាគបូព៌ាថា ក្បត់ គឺមានក្បាលយួនខ្លួនខ្មែរ។ ជាពិសេស ខ្មែរក្រហមជម្លៀសប្រជាជនដែលរស់នៅខេត្តស្វាយរៀង និងខេត្តព្រៃវែង តាមរទេះគោ និងធ្វើដំណើរដោយថ្មើរជើងទៅអ្នកលឿងរួចហើយធ្វើដំណើរតាមកាណូតបន្តរហូតមកដល់ទីក្រុងភ្នំពេញ។ ខ្មែរក្រហមបានចែកខោអាវ និងក្រមាឲ្យប្រជាជនភូមិភាគបូព៌ា និងប្រាប់ប្រជាជនឲ្យប្រើប្រាស់វាគ្រប់ពេល។ ប៉ុន្តែគោលបំណងដែលអង្គការចែកខោអាវ និងក្រមាឲ្យនោះ គឺជាការសម្គាល់ថាប្រជាជនដែលជម្លៀសចេញពីភូមិភាគបូព៌ា។ ប្រសិនបើប្រជាជនដែលជម្លៀសចេញពីភូមិភាគបូព៌ាធ្វើខុស ឬមានការជំទាស់បន្តិចជាមួយអង្គការ និងត្រូវយកទៅសម្លាប់ចោលជាមិនខាន។

ក្រោយខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ មានប្រជាជនចន្លោះពី១.៧ទៅ២លាននាក់បានស្លាប់ និងបានបន្សល់ទុកស្ត្រីមេម៉ាយ និងកុមារកំព្រារាប់ពាន់នាក់។ ប្រជាជនខ្មែររាប់សែននាក់បានរត់ចេញពីប្រទេស ហើយបានក្លាយជាជនភៀសខ្លួន។ គ្រាប់មីនរាប់លានគ្រាប់ត្រូវបង្កប់ដោយសារសង្គ្រាម ដែលបណ្តាលឲ្យប្រជាជនរាប់ពាន់នាក់ស្លាប់ និងពិការ ចាប់តាំងទសវត្សរ៍ឆ្នាំ១៩៧៩ រហូតមកដល់សព្វថ្ងៃ។ កត្តាទាំងអស់នេះហើយជាឧបសគ្គដ៏ចម្បងក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ចំណែកអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានប្រឈមបញ្ហាសុខភាពយ៉ាងធ្ងន់ធ្ងរ។ ផ្អែកតាមលទ្ធផលស្ទាបស្ទង់មតិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣២០០០នាក់ បានរកឃើញថាភាគច្រើននៃអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមានជំងឺប្រមាណ១០ប្រភេទរួមមាន៖ ) ជំងឺលើសឈាម ២) ជំងឺក្រពះពោះវៀន ៣) ជំងឺគ្រុនចាញ់ ៤) ជំងឺផ្លូវចិត្ត ៥) ជំងឺបេះដូង ៦) ជំងឺរលាកសន្លាក់៧) ជំងឺហឺតព្រាំរ៉ៃ ៨) ជំងឺរបេង ៩) ជំងឺឆ្កួតជ្រូក និង ១០) ជំងឺទឹកនោមផ្អែម។

ឆ្លៀតឱកាសនោះ លោក ឡុង ដានី ក៏បានធ្វើបទបង្ហាញជាសង្ខេបអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដល់សិស្សានុសិស្សដូចជា សំណុំរឿង០០១ សំណុំរឿង០០២ (០០២/១ និង ០០២/២) និងដឹកនាំដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាតេជោ X-១៦។

បន្ទាប់ពីចប់វេទិកាថ្នាក់រៀន សិស្សបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖

នាងខ្ញុំឈ្មោះ **សារ៉ាត់ នីតា** គឺជាសិស្សមកពីវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន លាដលើ។ ថ្ងៃនេះខ្ញុំពិតជាមានអារម្មណ៍រំភើបណាស់ដែលបានមកចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ ខ្ញុំបានឃើញទិដ្ឋភាពនៅលើពិព័រណ៍របស់ប្រជាជននៅក្នុងរបបខ្មែរក្រហមដោយផ្ទាល់ភ្នែកដូចជា ប្រជាជនកំពុងធ្វើការ ក្មេងកំព្រា វត្តអារាម

បាក់បែក គួរឲ្យសោកសង្រេងខ្លាំងណាស់។ បន្ទាប់ពីបានស្ដាប់លោក ឈុំ វ៉ា ធ្វើបទបង្ហាញអំពីរូបភាព ខ្ញុំទទួលបានចំណេះដឹងថ្មីៗច្រើនទាក់ទងនឹងរឿងរ៉ាវប្រវត្តិសាស្ត្រនៅក្នុងពិព័រណ៍។ ចំណែកលោកគ្រូ ឡុង ដានី បានធ្វើបទបង្ហាញអំពីការជម្លៀសប្រជាជនដោយបង្ខំ ដែលធ្វើឲ្យខ្ញុំអាណិតអាសូរដល់ប្រជាជនដែលរស់នៅក្នុងរបបខ្មែរក្រហមកាន់តែខ្លាំង ជាពិសេសប្រជាជនភូមិភាគបូព៌ា។ ខ្ញុំក៏បានដឹងអំពីវិធីសាស្ត្រនៃការទប់ស្កាត់អំពើប្រល័យពូជសាសន៍ដែរ។ ចុងក្រោយ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកោះថ្មដែលបានរៀបចំកម្មវិធីសិក្សាអំពីរបបកម្ពុជាប្រជាធិបតេយ្យនេះឡើង ដើម្បីផ្ដល់ឱកាសឲ្យខ្ញុំនិងប្អូនៗជំនាន់ក្រោយបានសិក្សាបន្ថែមទៀតអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

នាងខ្ញុំឈ្មោះ **ភី សុខណា** គឺជាសិស្សមកពីវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន លាជលើ។ ដំបូងខ្ញុំសូមអរគុណដល់លោកគ្រូនាយកសាលា ប៊ុនរ៉ានី ហ៊ុនសែន លាជលើ ដែលបានផ្ដល់ឱកាសឲ្យខ្ញុំបានមកចូលរួមទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ ពីមុនមកខ្ញុំមិនសូវយល់ដឹងប៉ុន្មានទេអំពីរបបកម្ពុជាប្រជាធិបតេយ្យ។ ចាប់ពីពេលខ្ញុំបានមកទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្មមក បានឲ្យខ្ញុំយល់ដឹងកាន់តែច្រើនជាងមុនពីការជម្លៀសប្រជាជនដោយការបង្ខំក្នុងរបបខ្មែរក្រហម។ ខ្ញុំចាប់អារម្មណ៍រូបថតដែលដាក់តាំងបង្ហាញនៅមជ្ឈមណ្ឌលឯកសារកោះថ្ម រូបថតមួយចំនួនគឺជាលោកយាយលោក អ៊ំពូមីង ដែលបានខិតខំតស៊ូព្យាយាមទោះបីដឹងថា របបខ្មែរក្រហមប្រព្រឹត្តអំពើឃោរឃៅលើរូបគាត់ ក៏គាត់អត់ធ្មត់ដើម្បីបានរស់ជីវិត ។





សិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន លាជលើ ចូលរួមវេទិកាថ្នាក់រៀនស្ដីពី «ការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា» រៀបចំដោយមជ្ឈមណ្ឌលឯកសារកោះថ្ម និងទស្សនកិច្ចសិក្សានៅតំបន់ប្រវត្តិសាស្ត្រយោធាអ៊ិច ១៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# ការិយាល័យព័ត៌មានសាធារណៈ













«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយ ដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!














# ជីវិតក្មួនប្រុសពុកក្នុងគុកខ្មែរក្រហម (ត)

ហង្ស ឆាំឆាន

## ៤.១៤.យុទ្ធនារីចាប់ពួកខ្ញុំក្នុងព្រៃចងស្លាបសេកដោយប្រឡំ

ម៉ោង៧ កាប់ខសពេញរទេះហើយ នាំគ្នាដើររកឃ្មុំរហូតដល់ពេលបាយបានឃ្មុំជាច្រើនសម្បុករួចមិត្តសុនចាំមើលគោ ពួកខ្ញុំពីរនាក់ចុះខ្វារត្រីក្នុងព្រែក តាពុត សន្តិសុខមាន មិត្តសាលី សារឿង និងមិត្ត ខុម ចាំរើសត្រីខាងលើមាត់ព្រែកនិងជួយសែងត្រីៗ យើងធ្វើការនេះយ៉ាងដក់ចិត្ត និងបានផលល្អណាស់ តែល្ងាចថ្ងៃទី៥ខ្ញុំកំពុងតែជិតអារម្មណ៍និងត្រីធំបានច្រើនស្រាប់តែពុស្នូរពីលើមាត់ព្រែកលាន់ក្រោកក្រាក់ហើយសំឡេងនារីស្រែកសម្លុតថា លើកដៃឡើងលើទាហាន! រួចហៅខ្ញុំទាំងពីរនាក់មកចងស្លាបសេកៗ ទទួលមិត្តសាលី និងសារឿងរត់មកគេស្គាល់គ្នាស្រែកថាឈប់កុំអាលចង តើមិត្តឯងចងយកទៅណាទៅដាក់គុកឬ? ២នាក់ហ្នឹងអ្នកជាប់គុកស្រាប់ហើយ គេក៏លែងពួកខ្ញុំទៅវិញៗ ការងារបន្តពីកាប់ខសគឺទៅដឹកឈើពីការដ្ឋានសន្តិសុខនានាដែលបានរំសាយដូចជាគុកក្រាំងពោន ផ្ទះមេស្រុកសួងវត្ត ធ្លូក គុកស្វាយអណ្តូងៗលៗ ឈើទាំងនេះគេយកមកគរទុកសំរិតៗ

## ៤.១៥. ការដកស្ទូងស្រូវប្រាំង

ខែមីនា ឆ្នាំ១៩៧៧ ដោយសារមានកម្មាភិបាលមកពីសន្តិសុខរំសាយមានគំនិតដឹកនាំខុសៗគ្នាមានការដាក់វិន័យទៅលើអ្នកទោសខុសៗគ្នាមើលទៅ ហាក់ដូចជាប្រកាន់បក្សពួកផ្ទៃក្នុងរង្គោះរង្គើរួមផ្សំនឹងការងារមកថែមជូនៗទៀតពួកអ្នកទោសត្រូវទទួលរងការត្បិតត្បៀតជាខ្លាំងដូចជាផែនការធ្វើរដូវប្រាំងតាមទប្រព័ន្ធភ្លឺស្រែជាង១០០ហិកតាចាប់ផ្តើមប្រយុទ្ធក្តៅគគុកៗ ពួកយើងជាអ្នកទោសត្រូវក្រោកឡើងដោះខ្នោះជើងនៅម៉ោង៤ទៀបភ្លឺ ទៅភ្លួរប្រែដីសម្រុកឲ្យទាន់មុនទ័ពនារីមកស្ទូងស្រូវប្រាំងល្ងាចលើកភ្លឺស្រែដល់ម៉ោង៥ទៅ ទាញបញ្ជោះម៉ាស៊ីនបូមទឹកដាក់ស្រែ ដោយសារម៉ាស៊ីនដោះពីក្បាលឡានមកធ្វើជាម៉ាស៊ីនបូមទឹកបញ្ជោះម្តងទៀតត្រូវប្រើកម្លាំងមនុស្សពី១៥ទៅ២០នាក់ ទាញ២០ទៅ៣០ខ្សែទើបឆេះ ពេលខ្លះឆេះហើយតែមិនបូមទឹកក៏ត្រូវនាំគ្នាចាក់ទឹកកន្ទះម៉ោងទើបពេញ រួចទាញ២០ទៅ៣០ខ្សែម្តងទៀតពេលខ្លះរហូតដល់ម៉ោង១០ ទើបបានដើរទៅដល់គុកហុតបបរហើយ ចូលដាក់ខ្នោះដេកៗ របបហូបនៅអង្ករកន្ទះកំប៉ុងមួយថ្ងៃ តើមានកម្លាំងធ្វើការបាន? (ពួកយើងឆ្ងល់ថាស្រូវរាប់តោន ឡានមកដឹកយកទៅអស់ថ្មីៗ បើសិនជាអ្នកមានវិចារណញ្ញាណគេឲ្យពួកយើងហូបគ្រប់គ្រាន់ ការងារអាចដំណើរការបានល្អ ស្រូវរាប់រយតោននឹងកើតឡើងដោយមិនលំបាកតើហេតុអ្វី? គេដាក់ទារុណកម្មពួកយើងយ៉ាងនេះ?)ៗ គ្រាន់តែ៣អាទិត្យ ពួកយើងម្នាក់ៗធ្លាក់ខ្លួនស្គមមើលស្ទើរមិនស្គាល់ៗ ពួកខ្ញុំពេលនេះត្រូវគ្រោះអាសន្នមកដល់ទៀតហើយ សូម្បីតែរត់ចាប់ក្របីដើរក្នុងក្រោលក៏មិនទាន់



ហង្ស ឆាំឆាន ពេលបួសជាព្រះសង្ឃៗ (ហង្ស ឆាំឆាន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ផង ដើរកាន់នង្គ័លជំពប់តែទងស្មៅបុដុំដីតូចមួយក៏ដួលផ្កាប់មុខដែលហេវដល់ខ្យល់ចេញតាមត្រចៀកលាន់ងឺៗ ភ្នែកស្រវាំងស្ទើរមើលពុំឃើញៗ រយៈពេលជាង២០ថ្ងៃការដាស់ដីបានបញ្ចប់ ខ្ញុំជិះក្របីទៅឲ្យស៊ីស្មៅនៅមាត់បឹងឆៀងមើលក្រែងបានជួបប្អូនៗខ្ញុំៗ ចៃដន្យល្អណាស់ប្អូនរី ប្អូនក៏ស្គាល់សំឡេង អុំទូកមកជិតយកបាយនៅក្នុងទូកគេឲ្យខ្ញុំវេចនឹងក្រមាហូបលើខ្នងក្របី ហើយប្រាប់តិចៗថាស្អែកបងមកទីនេះទៀតខ្ញុំយកកន្ត្រៃកាត់សក់បងចេញៗ ស្អែកយើងបានជួបគ្នា ប្អូនរី និងបងថៃ ឲ្យខ្ញុំអង្គុយលើទូកកាត់សក់ដ៏វែងកន្ទ្រើងមានចៃរាប់រយដែលឆ្លងទៅឆ្លងមកពីអ្នកទោសដូចគ្នាយ៉ាងឆាប់រហ័សបំផុតរួចក៏វេចបាយឲ្យខ្ញុំស៊ីលើខ្នងក្របីហើយ

ប្រាប់ថា បងមកកន្លែងនេះរាល់ថ្ងៃមក ខ្ញុំយកបាយឲ្យបង! បានបាយ ហូប ហើយខ្ញុំមានកម្លាំងដូចមុន ខ្ញុំតែង តែមកមាត់បឹងរាល់ថ្ងៃ តែប្អូនទីណាត់ ជួបជាបន្តបន្ទាប់ ព្រោះមិនចង់ឲ្យ សន្តិសុខសង្ស័យ។ ការភ្ជួរឲ្យគេស្ទូង បានមកដល់កម្លាំងយុទ្ធនារីមានរហូត ដល់៥០០នាក់ក្នុង១ហិកតាត្រូវប្រើ អ្នកស្ទូង៣០នាក់មួយថ្ងៃ ត្រូវស្ទូងឲ្យ ហើយ១៦ហិកតា។ អ្នកភ្ជួរត្រូវធ្វើដី ១៦ហិកតា១ថ្ងៃឲ្យគេ ដោយត្រូវប្រើ មនុស្ស៨០នាក់ តែកម្លាំងអ្នកទោស មានតែ៥០នាក់ស្រី៥នាក់សម្រាប់បុក អង្ករ ប្រុស៥នាក់ត្រូវចុះជញ្ជូនកណ្តាប់ ឲ្យគេស្ទូង អ្នកប្រែដី និងរាស់ដីឲ្យគេ ស្ទូងមានតែ៤០នាក់ បើធ្វើតាមម៉ោង ដូចធម្មតាបានតែ៨ ហិកតា២ថ្ងៃដើម្បី សម្រេចការងារស្ទូងប្រាំងឲ្យបានជោគ ជ័យត្រូវតែបង្កើនម៉ោងអ្នកភ្ជួរគឺត្រូវ ភ្ជួរក្រោកឡើងនៅម៉ោង១យប់នឹង ធ្វើដីនៅពេលល្ងាចឲ្យទាន់អ្នកស្ទូង។

### ៤.១៦.ផែនការស្រូវវស្សាមកដល់ សត្វដូលមនុស្សក៏ទ្រោម

ពេលជាង១អាទិត្យ ការស្ទូង ស្រូវប្រាំងបានបញ្ចប់ដោយជោគជ័យ ផែនការស្ទូងស្រូវវស្សាបានមកដល់ ផែនការរបស់អង្គការមានយុទ្ធសាស្ត្រ ស្រូវប្រាំងក៏ដូចជាស្រូវវស្សាតែពេល នេះមានភ្លៀងធ្លាក់ច្រើន ពួកខ្ញុំមិន បានទៅទាញម៉ាស៊ីនទៀតទេ។ តែវា កាន់តែធ្ងន់ជាងមុនទៀតគឺដកសំណាប រហូតដល់ម៉ោង១០យប់ ទៅហូបបបរ ហើយដេកដាក់ខ្នោះម៉ោង១ សន្តិសុខ មកវាយរនុកខ្នោះឲ្យក្រោកឡើងភ្ជួរ រាស់ដល់ម៉ោង១០បានឈប់ យកគោ ទៅវាលស្មៅម៉ោង២មកភ្ជួរបន្តដល់ ម៉ោង៦ ហូបបបររួចចុះដកសំណាប។ បើពុំមានការផ្គត់ផ្គង់ពីក្រុមគ្រួសារទេ ខ្ញុំប្រហែលជាដាច់ពោះស្លាប់ទៅ ហើយពេលនេះខ្ញុំនឹកឃើញសំដីលោក ពូឡេ និងលោកឪពុកក្មេកខ្ញុំពិភាក្សា គ្នានៅយប់ថ្ងៃបែកពីប្រពន្ធថា បើខ្ញុំ ទៅជាប់គុកនៅស្រុកកំណើតអាច រស់។ ចាប់ពីពេលនោះមក ព័ត៌មាន បានឮដល់លោកឪពុក និងប្អូនៗខ្ញុំទាំង ៨នាក់លោកក៏រៀបចំចាត់ចែងឲ្យប្អូន យកបាយ និងចំណីផ្ញើរសរវេន និងទី កន្លែងដូចជាឲ្យខ្ញុំទៅយករបស់អ្វីពី អ្នកណា? នៅកន្លែងណា? ថ្ងៃណា? ឲ្យ សញ្ញាដូចម្តេច?។ល។ ខ្ញុំមានបាយ និង ចំណីហូបជាប្រចាំមិនសូវជាហេវដូច មុនទេ។

### ៤.១៧. ខ្ញុំដើរភ្ជួរទាំងដេកលក់ ក្របី ដើរវៃងវង្វេចទឹមមនុស្សជំនួស

ទោះជាមានហូបមានកម្លាំងក៏ ដោយបើដេកមិនគ្រប់គ្រាន់និងធ្វើការ ហួសកម្លាំងក៏នៅតែស្គមដដែរក្រោកពី ម៉ោង១យប់ឡើងភ្ជួរ ខ្ញុំដើរភ្ជួរទាំងធ្មេច ភ្នែកលក់ពីពាក់កណ្តាលវាល ដល់ចុង ស្រែ បត់នង្គ័លក្របីឈប់ទើបដឹងខ្លួន ថាអម្បាញ់មិញខ្ញុំដេកលក់។ គោ ក្របី ក៏ដួលរៀងរាល់ថ្ងៃពេលភ្ជួររាស់ដី ដើរវៃងវង្វេចដូចតែមនុស្សដែរ។ ពេល ក្របីអ្នកសរនាស់មិនរួចមិត្តជុន បាន ស្រែកគំហកថា បើក្របីអូសមិនរួច មានតែឲ្យពួកឯងអូសរនាស់ជំនួស ក្របី។ រួចបញ្ជាឲ្យពួកខ្ញុំនិងអ្នកផ្សេង ទៀតដែលជាអ្នករាស់ដីអូសរនាស់ ម្តង។ ពួកយើងអូសបាន២ទៅ៣ជុំ ក៏លត់ជង្គង់ក្រាបនៅកន្លែង ទោះមិត្ត ណាមកបញ្ជាយ៉ាងម៉េចក៏ទៅលែង រួចដែរ។ ដោយឃើញថា ពួកយើង ទាំងអស់គ្នាធ្វើការបានលទ្ធផលល្អ ច្រើនកន្លងមក មិនដែលរុញរានឹង ការងារ និងពុំមានកម្លាំងមាំមួនដោយ សារហូបមិនគ្រប់គ្រាន់តែពួកគាត់ពុំ មានលទ្ធភាពជួយយើងខ្ញុំ ព្រោះនេះគឺ ជាការកំណត់របស់ថ្នាក់ដឹកនាំខាងលើ ហើយពួកគាត់ក៏មិនប្រាកដថាបានសុខ ដែរទើបសន្តិសុខខ្លះក៏ឃាត់លែងឲ្យ ប្រើមនុស្សអូសរនាស់តទៅទៀត។

### ៤.១៨.ការដោះលែងអ្នកទោស ២០នាក់

មកដល់ចុងខែឧសភា ឆ្នាំ ១៩៧៨ ការងារស្រូវវស្សាកំពុង មមាញឹកខ្លាំងនៅការដ្ឋានសន្តិសុខ ទួលសំរិត។ ស្រាប់តែមានព័ត៌មាន ដោះលែងអ្នកទោស២០នាក់បានមក ដល់ពួកយើងទាំងអស់គ្នាឮដូច្នេះ មានសេចក្តីរីករាយណាស់ម្នាក់ៗ ខ្សឹបខ្សៀវគ្នាថាប្រហែលអ្នកនេះអ្នក នោះ ព្រោះគាត់មកជាប់យូរហើយ អ្នកខ្លះថាមិនអាចទេគាត់ជាប់គុក នយោបាយ មិនងាយរួចទេ អ្នកខ្លះថា ម្នាក់ហ្នឹងមិនគួររួចទេព្រោះការងារមិន ធ្វើផងឮតែឈឺរហូត។ ការជជែកគ្នា ទាំងប៉ុន្មានដែលសុទ្ធតែស្មាននោះគឺ ខុសស្ទើរ១០០ភាគរយ ព្រោះអ្នកដែល មានឈ្មោះថាអង្គការដោះលែងនោះ គឺភាគច្រើនជាអ្នករត់ទៅប្រទេស វៀតណាមកាលពីដើមឆ្នាំ១៩៧៧ មុនពេលវៀតណាមឈប់ដូរអំបិល ដូរជ្រូក។ សូមបញ្ជាក់ថា មុនដំណាច់ ខែមេសា ឆ្នាំ១៩៧៧ មានអ្នករត់ទៅ វៀតណាមជាច្រើនដោយភ័យនឹងការ ចាប់ខ្លួនកម្មាភិបាលជាច្រើនដូចជា ចាន់ ចក្រី គឺជាប្រធានសេនាធិការ ភូមិភាគបូព៌ា ទេព ឈុក ប្រធាន តំបន់២៤ ប៉ែន ស៊ីលា ប្រធានសេនា ធិការតំបន់២៤។ ពេលកម្មាភិបាល និង ប្រជាជនទាំងនោះរត់ទៅរដ្ឋអំណាច ខ្មែរក្រហមទៅសុំរដ្ឋអំណាចវៀតណាម ឲ្យបញ្ជូនអ្នករត់ទៅទាំងប៉ុន្មាន ត្រឡប់ មកខ្មែរវិញ ដើម្បីគេធ្វើការអប់រំបន្ត ទៀត ភាគីវៀតណាមយល់ព្រមតែ ត្រូវមានលក្ខខណ្ឌគឺបើយកទៅវិញ ត្រូវដូរជាអំបិលឬជាជ្រូកតាមចំនួន ដែលឯកភាពគ្នា។ តាមព័ត៌មានថា សកម្មភាពនេះពួកគេបានដូរជាច្រើន លើកមកហើយ តែដល់ពេលនោះគឺ ឆ្នាំ១៩៧៧ ពេលដូរជ្រូកវៀតណាម យកជ្រូកទៅឯខ្មែរក្រហមយកមនុស្ស ដែលត្រូវដូរស្ទើរមិនទាន់ផុតព្រំដែន វៀតណាមផងក៏បាញ់សម្លាប់ភ្លាមៗ នៅមុខគេៗក៏ឈប់ដូរចាប់ពីពេល

នោះមក។ ដូច្នេះអ្នកដែលមានឈ្មោះដោះលែង២០នាក់នោះមាន១៣នាក់ជាអ្នករត់ទៅវៀតណាមដូចជាឈ្មោះ ឆ្នូ រស់នៅភូមិបឹងខ្យង សង្កាត់បន្ទាយចក្រី ជាដើម។ ក្រៅពីនេះគឺអ្នកដែលបះបោរប្រឆាំងនិងរដ្ឋអំណាចសង្កាត់ ដូចជាឈ្មោះ យ៉េត រស់នៅភូមិស្វាសង្កាត់ក្រាំងតាយ៉ង។ល។ ក្រោយពីបញ្ជូនពួកនេះទៅបាត់មួយរយៈ ក្រោយមកពួកយើងខ្ញុំដែលរួចទៅក្រោយ គេពុំបានឃើញក្រុម២០នាក់នោះបានទៅដល់ផ្ទះទេ។ បានន័យថា ២០នាក់នោះគេយកទៅសម្លាប់ចោលអស់ព្រោះអ្នកទាំងនោះរស់នៅមិនឆ្ងាយពីភូមិកកំណើតខ្ញុំទេ។ ទោះជាលំបាកយ៉ាងណាក៏ដោយក៏ពួកយើងនៅសល់ក្នុងគុក៣០នាក់នេះបានតស៊ូដើម្បីរស់តទៅទៀត។

## ៤.១៩. ទំនប់ពោធិ៍បូរីបាក់ដូចជាជួយសង្គ្រោះជីវិតយើងខ្ញុំ

ការងារស្រូវប្រាំង ស្រូវកំពុងបែកគុម្ព លូណាស់ មានស្រែខ្លះស្រូវដង្ហើមចេញផ្កាមួយៗ ហើយក្តីសង្ឃឹមយើងខ្ញុំថានឹងបានរបបកើនឡើងពេលស្រូវប្រាំងទុំ។ តែចំពោះមុខនេះម្នាក់ៗឡើងជ្រួញដើរទៅមុខទាំងត្រដរលែងស្តីលែងនិយាយអ្វីទាំងអស់ ការជជែកគ្នាពេលដេក ពីមុនធ្លាប់តែព្រុអ៊ូអរនិងសើចសប្បាយទោះបីជើងជាប់ខ្នោះក៏ដោយ ឥឡូវពេលដេកស្ងាត់ ដូចជាក្នុងគុកនេះគ្មានមនុស្សម្នាក់សោះ។ ម្នាក់ៗបន់ឲ្យតែដល់កន្លែង មិនចាំបាច់ផ្លុតទឹកទេដេកលក់បាត់ហើយពីម៉ោង១០ដល់ម៉ោង១យប់ពួកយើងលង់លក់គ្មានដឹងខ្លួនឡើយ។ ស្រូវវស្សាស្ទូងបានទើបតែបាន១ភាគ៣នៃស្រែវស្សាទាំងមូល កម្លាំងមនុស្សបាត់អស់២០នាក់ ភារកិច្ចប្រជែងជាមួយនារី ដកស្ទូង ជាបន្ទុកមកលើយើងនៅសល់៣០នាក់។ ដោយខ្លាចគ្មានដីឲ្យគេស្ទូងក្រុមសន្តិសុខមួយចំនួនត្រូវចុះភ្ជួររាស់ជាមួយអ្នកទោសតែគេមានរបបហូបគ្រប់គ្រាន់និងអាចផ្លាស់វេនគ្នាបាន។ ចុងខែមិថុនា ឆ្នាំ១៩៧៨ ថ្ងៃនោះពួកយើងខ្ញុំត្រូវទៅភ្ជួររាស់នៅមាត់បឹងបង្កោល ចាប់ពីម៉ោងប្រហែល២កណ្តាលអធ្រាត្រ យើងខ្ញុំបានភ្ជួរស្រែទី១រួចរាល់ហើយក៏ចុះភ្ជួរស្រែទី២ និងឮស្នូរទឹកហូរបាក់ទំនប់ដូចសំឡេងយន្តហោះ។ យើងខ្ញុំមិនចាប់អារម្មណ៍ថាមានបាក់ទំនប់អីទេ គិតទៅរឿងផ្សេង គឺបើមានគេមករំដោះនឹងអាលរត់ចូលព្រោះឮសំឡេងដូចយន្តហោះតែហេតុអ្វីនៅកន្លែងដដែលដូចជាមិនទៅណាសោះ និងឆ្ងល់ត្រង់ការភ្ជួរស្រែទី១ពុំមានទឹកទេដល់ចុះស្រែទី២បាន៤កន្លងទឹកឡើងដល់ពាក់កណ្តាលកំភួនជើង។ ក្រុមសន្តិសុខដែលនៅយាមពួកខ្ញុំតាមស្រែក៏មិនដឹងដែរ ដោយស្រែនេះទឹកជ្រៅគេបញ្ជូឲ្យទៅភ្ជួរស្រែទី៣បានតែ១គន្លងក៏លិចដល់ក្បាលជង្គង់និងមេឃចាប់ភ្លឺឡើងទើបដឹងថាទឹកបាក់ទំនប់លិចស្រែអស់ហើយមិនអាចភ្ជួរបានទេ។ ពេលមេឃភ្លឺឡើងយើងក្រឡេកមើលទៅស្រូវប្រាំងកំពុងលូទឹកលិចផុតចុងអស់ កណ្តាប់ សំណាប ដែលអ្នកដឹកជញ្ជូនយកមកទុកពីល្ងាចរសាត់តាមទឹកហូរយ៉ាងលឿនរកតែចាប់មិនទាន់បានផង។ រវល់តែចាប់នេះខុសចាប់នោះខុសងាកមកខ្លួនឯងវិញទឹកឡើងដល់ត្រឹមទ្រូងស្រេច ទើបខ្ញុំស្រែកទៅមិត្តសាលីជាសន្តិសុខថាបង់ឡើងទៅដីទួលប្រយ័ត្នទៅមិនទាន់ហែលមិនរួចគ្រោះថ្នាក់ តោះយើងទៅ។ ខ្ញុំក៏ឡើងជិះក្របីមេបរនង្គ័លទៅគុកវិញដោយសុវត្ថិភាពឯក្រុមសន្តិសុខរត់ទៅរកទរទឹកដើរឡើងមកគុកយ៉ាងប្រញាប់។ ទៅដល់គុកត្រឹមតែ២ម៉ោងប៉ុណ្ណោះក្រឡេកមើលជុំវិញទឹកលិចវាលដូចសមុទ្រ ចុះពីគុក២០ម៉ែត្រទឹកលិចក្បាលបើមិនចេះហែលប្រាកដជាលង់ទឹកស្លាប់។

ថ្ងៃនេះពួកយើងខ្ញុំមិនបានធ្វើអីទៀតទេ ម្នាក់ៗសប្បាយនឹងរត់ដេញចាប់សត្វដែលលិចលង់រត់រកទីទួល ដូចជា ក្រួច មាន់ទឹក ដុំដោល។ល។ យកមកធ្វើម្ហូបស្ល ហូបជាមួយបបរវាវកក្លូកទៅ។ ពេលនេះយើងគិតថាបានរួចទោសពីទារុណកម្មព្យួររាស់ដកស្ទូងទៀតហើយតែអ្វីដែលយើងព្រួយនោះគឺគោ ក្របី រាប់រយក្បាលទៅស៊ីស្មៅឯណា បើទឹកជុំវិញគុកជម្រៅ៣ទៅ៤ម៉ែត្រឯណោះ។



កងចល័តកំពុងលើកទំនប់នៅក្នុងរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របមុខ ៖

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត អានសៀវភៅ «ព័ត៌មានអំពីការថែទាំសុខភាព» ដែលបោះពុម្ពដោយគម្រោងស្តីអំពី «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ ៖

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង ទទួលបានរទេះរុញពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 295, July 2024 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.